ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 09-Aug-2012, 15:46
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី៩២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក ម៉ាតេអូ គ្រីប៉ា
*(Mr. Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ ដារាវស្មី

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ *(Mr. Jasper PAUW)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី
*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្ដម

លោក ម៉ៃខល កាណាវ៉ាស
*(Mr. Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោក ហ្វែឌីណង់ ចាមិន ហ្សេប៉ា
*(Mr. Ferdinand DJAMMEN NZEPA)*

លោកស្រី ស៊ីន សុវ៉ន

លោកស្រី ម៉ុច សុវណ្ណារី

លោក ឡោ ជុនធី

លោកស្រី ម៉ារី ហ្គីរ៉ូដ
*(Ms. Marie GUIRAUD)*

លោកស្រី ជេត វណ្ណលី

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ហ្វែឌីណង់ ចាមិន ហ្សេប៉ា | បារាំង |
| លោក ហ្សាស្តើ ប៉ៅ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ស្បួង ស៊ីគឿន (TCW-694) | ខ្មែរ |
| លោក អុង ថុងហឿង (TCW-490) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក សួង ស៊ីគឿន ហៅ គង់ ឬ ធន** (TCW-694)

សួរបន្តដោយលោក ហ្វែឌីណង់ ចាមិន ហ្សេប៉ា ផ្តើមពី៖ ........ ទំព័រ ៤

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី៖........ ទំព័រ ៧

សួរដោយលោក គង់ សំអុន ផ្តើមពី៖........ ទំព័រ ២៧

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី៖ ........ ទំព័រ ៤១

**ការសួរសំណួរទៅសាក្សី÷ លោក អ៊ុខ ថុនហឿង** (TCW-490)

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី៖ ........ ទំព័រ ៤៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅក្នុងកិច្ចដំណើរការសវនាការនៅព្រឹកនេះ នឹងបន្តស្តាប់សក្ខីកម្មសាក្សី សួង ស៊ីគៀន ដែលដំបូង គឺចាប់នឹងបន្តដោយក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងបន្ទាប់ទៀតគឺ ដល់វេទិកាក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។ ហើយមុននឹងផ្តល់វេទិកាទៅភាគី ក្រឡាបញ្ជី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាននិងអវត្តមានភាគី ហើយនិងបុគ្គលដែលអង្គជំនុំជម្រះ កោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

[០៩:០២:១១]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្តីនេះមានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ។ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិ តាមរយៈមេធាវីរបស់គាត់ក្នុងការចូលរួមដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការសម្រាប់រយៈពេលពេញ១ថ្ងៃនៃថ្ងៃសវនាការនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដោយឡែកសាក្សីបម្រុងលោក អ៊ុង ថុងហឿង មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណ។

[០៩:០២:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

អង្គជំនុំជម្រះសម្រេចលើសំណើសុំចំនួនពីរ។ ទី១ គឺសំណើសុំរបស់ជនជាប់ចោទ អៀង សារី។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ

ដោយសុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។

[០៩:០៣:២៣]

លោកវេជ្ជបណ្ឌិត កឹម សមសាន្ត គ្រូពេទ្យទទួលពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក បានពិនិត្យសុខភាពលោក អៀង សារី នៅព្រឹកនេះ ហើយកត់សម្គាល់ឃើញថា លោក អៀង សារី មានអាការៈហត់ខ្លាំងពេលធ្វើចលនាដើរ និយាយដាច់ៗមិនបានវែង និងឈឺចង្កេះ និងបានផ្តល់អនុសាសន៍ថា អង្គជំនុំជម្រះគួរតែអនុញ្ញាតឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយ -- ពីបន្ទប់មួយនៅក្រោមសាលសវនាការនេះ។

អង្គជំនុំជម្រះ យល់ឃើញថា នាពេលនេះ លោក អៀង សារី ដែលបានលះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ ដោយគាត់មានបញ្ហាសុខភាពមិនអាចអង្គុយយូរបាន ដូចគ្រូពេទ្យបានកត់សម្គាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ ហើយក៏អាចសម្រួលទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់បានដែរ។

[០៩:០៤:២០]

ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលសូមលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញ១ថ្ងៃនេះ។

ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលធ្វើសវនាការពេញ១ថ្ងៃនេះ។

សេចក្តីសម្រេចទី២ គឺសេចក្តីសម្រេចលើសំណើដាក់ឯកសារថ្មីរបស់មេធាវីការពារក្តីជនជាប់ចោទ នួន ជា ឯកសារ E172/27/3។ អង្គជំនុំជម្រះបានទទួលសំណើមួយរបស់មេធាវីការពារក្តីជនជាប់ចោទ នួន ជា ដែលបានស្នើសុំប្រើប្រាស់ឯកសារថ្មីមួយ ក្នុងអំឡុងពេលខ្លួនសួរដេញដោលសាក្សីមួយ ដែលមានរហស្សនាម TCW-490 និងបានស្នើសុំដាក់ឯកសារនេះនៅចំពោះមុខ អង្គជំនុំជម្រះដែលអនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។

[០៩:០៥:៣៣]

ឯកសារ E172/27/3 អង្គជំនុំជម្រះធ្លាប់បានបញ្ជាក់ម្តងហើយម្តងទៀតថា សំណើសុំដាក់ភស្តុតាងថ្មីដែលអនុលោមតាមវិធាន៨៧(៤) ត្រូវធ្វើឲ្យបានទាន់ពេលវេលា នៅពេលដែលឯកសារថ្មីណាមួយមានពាក់ព័ន្ធទៅនឹងសាក្សីណាម្នាក់ ភាគីត្រូវតែស្នើសុំដាក់ឯកសារនេះឲ្យបានពីរសប្តាហ៍មុនពេលសាក្សីនោះផ្តល់សក្ខីកម្ម ដើម្បីឲ្យអង្គជំនុំជម្រះមានពេលវេលាពិចារណា ដូចដែលអង្គជំនុំជម្រះធ្លាប់បានបញ្ជាក់នៅក្នុងអនុស្សរណៈរបស់ខ្លួន ឯកសារ E128។

[០៩:០៦:១៣]

ឯកសារដែលមេធាវីការពារក្តីជនជាប់ចោទ នួន ជា បានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះគឺជាឯកសារដែលបានថិតនៅក្នុងមជ្ឈដ្ឋានសាធារណៈ ចាប់តាំងពីខែមេសា ឆ្នាំ២០០៩ មកម្ល៉េះ។ មេធាវីការពារក្តីជនជាប់ចោទ នួន ជា ទើបតែបានដាក់សំណើនេះនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១២ ពោលគឺមិនបានដល់១សប្តាហ៍ផង មុនពេលសាក្សីដែលមានរហស្សនាម TCW-490 គ្រោងនឹងមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។

មេធាវីការពារក្តីជនជាប់ចោទ នួន ជា មិនបានពន្យល់ថាតើពេល -- នៅពេលណា និងតាមមធ្យោបាយអ្វីដែលខ្លួនបានរកឃើញឯកសារនេះឡើយ ហើយក៏មិនបានវិភាគថាតើអ្វីដែលបានរារាំងដល់ការស្វែងរកឯកសារនេះ តាំងពីពេលដំបូងៗមកនោះទេ។

ហេតុដូច្នេះមេធាវីការពារក្តីជនជាប់ចោទ នួន ជា មិនបានបំពេញលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) ឡើយ។

អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងសម្រេចបដិសេធសំណើសុំរបស់មេធាវីការពារក្តីជនជប់ចោទ នួន ជា។

[០៩:០៧:២១]

បាទ ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលសិទ្ធិពីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។

មុននឹងផ្តល់វេទិកា អង្គជំនុំជម្រះសូមសួរទៅមេធាវី ថាតើលោកត្រូវការពេលវេលាប៉ុន្មានជាក់ច្បាស់នៅក្នុងការតាំងសំណួរចំពោះសាក្សី សួង ស៊ីគឿន នេះ?

**លោក ហ្វៃឌីណង់ ចាមិន ហ្សេប៉ា៖**

បាទ សូមអរគុណលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព។ ដូចដែលបានខ្ញុំជម្រាបកាលពីម្សិលមិញ ខ្ញុំមិនត្រូវលើសពី៣០នាទីនោះទេ ដើម្បីសួរទៅសាក្សីនេះ។ ខ្ញុំគិតថា ៣០នាទីនេះវាជាការគ្រប់គ្រាន់ហើយ។

[០៩:០៨:១៩]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរបន្តដោយលោក ហ្វៃឌីណង់ ចាមិន ហ្សេប៉ា៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំសូមអរគុណដែលបានមកទីនេះនៅព្រឹកនេះ ទោះបីជាលោកមានបញ្ហាសុខភាពផុយស្រួយក៏ដោយ។ យើងបន្តការពិភាក្សាគ្នាបន្តទៀត ដែលបានម្សិលមិញនេះគឺថា យើងមានការមិនសូវយល់គ្នាកាលពីម្សិលមិញ។ នៅពេលដែលលោកធ្វើការនៅក្រសួងការបរទេស តើលោកចាំថាកម្មាភិបាលមកពីខាងតំបន់ ឆ្លងកាត់តាមក្រសួងរបស់លោក តើលោកចាំទេ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** ជាបឋមសូមគោរពលោកប្រធាន សូមគោរពបងៗ សូមគោរពអង្គសវនាការទាំងមូល។ ចំពោះកម្មាភិបាលមូលដ្ឋានដែលឆ្លងកាត់ក្រសួងការបរទេស បាទ ខ្ញុំចាំបាទ។

**ស៖** បាទ សូមអរគុណលោកសាក្សី។ មិនមែនថា -- ខ្ញុំមិនដឹងចង់ពីការពោល -- ព័ត៌មានលម្អិតទេ គ្រាន់តែចង់ដឹងថាមានអ្នកមកឆ្លងកាត់តាមក្រសួងការបរទេស ឬក៏អត់? គឺថា យ៉ាងហោចណាស់ដឹងថាមានពីរបីនាក់។ តើៗហេតុអីបានពួកគាត់ទាំងអស់នោះ ត្រូវឆ្លងកាត់មកក្រសួងការបរទេសនោះ?

[០៩:០៩:៥៦]

**ឆ៖** មិនមានអ្នកណាប្រាប់ពីមូលហេតុយ៉ាងណាទេ ដែលពួកគាត់ឆ្លងកាត់តាមក្រសួងការបរទេសដល់ខ្ញុំទេ។ ប៉ុន្តែគ្រាន់តែថា ក្នុងចំណោមកម្មាភិបាលមកពីតំបន់នានានោះ មានមួយចំនួនត្រូវបានតែងតាំងឲ្យទៅបំពេញបេសកកម្មជាតំណាងកម្ពុជាប្រជាធិបតេយ្យនៅក្រៅប្រទេសបាទ។

**ស៖** លោកសាក្សី នឹងមានកម្មាភិបាលមួយចំនួន ដែលលោកមិនដឹងថា គាត់ត្រូវទៅណាទេ។ តើលោកដឹងថា អ្នកណាជាអ្នកសម្រេចលើជោគវាសនារបស់កម្មាភិបាលទាំងអស់នេះ ហើយដែលសម្រេចបញ្ជូនគាត់ចេញពីក្រសួងការបរទេសនេះ?

**ឆ៖** បាទ ខ្ញុំមិនបានដឹងទេ ព្រោះដូចខ្ញុំបានជម្រាបពីពេលមុនហើយគឺថា ចំពោះកម្មាភិបាលទាំងនោះ វាអត់ស្ថិតនៅក្នុងក្របខ័ណ្ឌភារកិច្ចរបស់ខ្ញុំទេបាទ។

**ស៖** បាទ ឥឡូវខ្ញុំសូមនិយាយពីប្រធានបទផ្សេងមួយទៀតលោកសាក្សី ទាក់ទងទៅនឹងស្ថានភាពកុមារ របស់អ្នកដែលធ្វើការនៅក្រសួងការបរទេស តើជាការញឹកញាប់ដែរឬទេ ដែលថាកុមារហ្នឹងត្រូវតែបំបែកចេញពីឪពុកម្ដាយរបស់ខ្លួន? គឺកូនៗរបស់បុគ្គលិកអ្នកធ្វើការនៅក្រសួងការបរទេសនោះ?

[០៩:១១:៥២]

**ឆ៖** បាទ ធម្មតាមិនមែនចំពោះតែបុគ្គលិកនៅក្រសួងការបរទេសទេ គឺថាជាវិធានការទូទៅ គឺកុមារត្រូវបែកចេញពីឪពុកម្ដាយឲ្យទៅនៅដូច -- ទៅនៅស្នូនកុមារ ឬនៅអង្គភាពផ្សេងបាទ។

**ស៖** លោកសាក្សី តើប្រព័ន្ធហ្នឹងចំពោះលោកនោះដែលធ្លាប់បានរស់នៅបរទេស តើប្រព័ន្ធបំបែកកូន ហើយយកទៅដាក់ក្នុងអង្គភាពមួយ លោកត្រូវបង្ខំខ្លួនទទួលយកប្រព័ន្ធហ្នឹង ឬក៏យ៉ាងម៉េច? តើលោកទ្រាំទ្រនឹងប្រព័ន្ធហ្នឹងយ៉ាងម៉េចដែរ ដែលគេបំបែកកូនពីឪពុកម្ដាយនេះ?

**ឆ៖** ខ្ញុំថាដូចជាមិនមានចោទអីទេ ព្រោះនៅក្នុងស្នូនកុមារដូចខ្ញុំនិយាយពីកូនខ្ញុំនៅស្នូនកុមារហ្នឹងការគ្រប់គ្រងក៏គេរៀបចំបានត្រឹមត្រូវ អ្នកដែលទទួលខុសត្រូវស្នូនកុមារហ្នឹងក៏ជាអ្នកដែលយកចិត្តទុកដាក់ស្រឡាញ់កូនក្មេងដែរ ហើយខ្ញុំអាច -- ទាំងភរិយាខ្ញុំអាចចេញចូលមើលបានទេ មិនមែនជាដូចថាជាតឹងរ៉ឹងអីណាស់ណាទេបាទ។

**ស៖** តើ -- ខ្ញុំគិតថាការអប់រំកុមារនោះ គឺថាដូចជាការអប់រំធម្មតាទេ ក៏ប៉ុន្តែតើយើង -- តើលោកមានអារម្មណ៍ថានេះជាការអប់រំកុមារ ដែលថាក្នុងគោលបំណងមួយ ដូចគោលបំណងរបស់បក្សដែលនៅសម័យនោះនុះ ដើម្បីគឺថាអប់រំបំពាក់បំប៉ននូវផ្នែកមនោគមន៍វិជ្ជាដល់កុមារ ឬក៏យ៉ាងម៉េច?

[០៩:១៤:២៥]

**ឆ៖** គឺការអប់រំគឺនៅ -- ខ្ញុំនិយាយនៅពេលនោះគឺថា ខ្លួនខ្ញុំផ្ទាល់មិនជាការចោទសួរ ឬបារម្ភអីទេ ព្រោះខ្ញុំមានជំនឿជឿជាក់លើបក្ស ហើយក៏ចង់ឲ្យកូនខ្ញុំដើរតាមគន្លងរបស់ខ្ញុំដែរ គឺស្រឡាញ់ប្រទេសជាតិ ស្រឡាញ់ប្រជាជន ហើយលះបង់អ្វីៗទាំងអស់ដើម្បីបុព្វហេតុជាតិ និងបុព្វហេតុប្រជាជន បុព្វហេតុបដិវត្តន៍ដែរបាទ។

**ស៖** ពេលដែលលោកពិចារណាពេលក្រោយមកនោះ តើលោកអាចចាត់ទុកថាការអប់រំនៅសម័យនោះមានលទ្ធផលវិជ្ជមានទៅលើក្មេងៗនៅជំនាន់នោះ។ តើអីចឹង លោកយល់ឃើញអីចឹងទេ?

**លោក សួង ស៊ីគឿន៖**

លោកប្រធាន តើខ្ញុំមានភារកិច្ចឆ្លើយនឹងសំណួរនេះទេ? ដូចឃ្លាតឆ្ងាយពីក្របខ័ណ្ឌហ្នឹងបន្តិចហើយបាទ។

[០៩:១៥:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ លោកត្រូវឆ្លើយតបនឹងសំណួរ!

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំ តាមខ្ញុំគិតហ្នឹងគឺថា ហើយខ្ញុំមិនបានគិតអីទេ ព្រោះរយៈកាលដូចថាកម្ពុជាប្រជាធិបតេយ្យរស់នៅហ្នឹងក៏ខ្លីដែរ ហើយការអប់រំតាមរបៀបនេះ ក៏មិនមានដូចថាពេលវេលា គ្រប់គ្រាន់ដើម្បីឲ្យចេញជាលទ្ធផលយ៉ាងណាទេ។ ដូច្នោះ ខ្ញុំមិនមានមតិអីថា ល្អ ឬមិនល្អទេបាទ។

**សួរដោយលោក ហ្វេឌីណង់ ចាមិន ហ្សេប៉ា៖**

**ស៖** សូមអរគុណ។ បាទ ឥឡូវខ្ញុំសូមចូលទៅនិយាយរដ្ឋកាល -- រយៈពេលកាលផ្សេងទៀតនៅតំបន់ផ្សេងទៀត។ យើងនៅក្នុងរយៈពេលដែលយើងបោះឆ្នោតនៅឆ្នាំ១៩៩៣ ហើយមានព្រឹត្តិការណ៍មួយដែលពាក់ព័ន្ធទៅនឹងបញ្ហាការនៅខែមិថុនា ឆ្នាំ១៩៩៤។ តើការបញ្ហាការខ្មែរក្រហមនៅសម័យនោះ គឺថានៅខែមិថុនា ឆ្នាំ១៩៩៤នោះយ៉ាងម៉េចដែរ? លោកមានគំនិតយោបល់អីលើការបញ្ជាកងទ័ពនៅសម័យនោះទេ?

[០៩:១៧:១៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព ភាគីទាំងអស់ជាទីគោរព។ ខ្ញុំក្រោកឡើងនេះ គឺដើម្បីធ្វើការជំទាស់មួយ ពីព្រោះខ្ញុំមិនគិតថាសំណួរនេះពាក់ព័ន្ធនឹងប្រធានបទនៃការជម្រះសេចក្ដីវគ្គទី១យើងនេះទេ។

**លោក ហ្វេឌីណង់ ចាមិន ហ្សេប៉ា៖**

ខ្ញុំពុំមានបញ្ហាអីទេ បើសិនជាសំណួរនេះវាប្រាសចាកពីវិសាលភាព ខ្ញុំត្រៀមរយៈពេល៣០

នាទី។ ឥឡូវ ខ្ញុំគិតថា ខ្ញុំចោទសំណួររបស់ខ្ញុំដែលទាក់ទងទៅនឹងមន្ទីរក្រសួងការបរទេសនេះ ចប់ត្រឹមហ្នឹងហើយ។ អ៊ីចឹងខ្ញុំសូមបញ្ចប់ត្រឹមហ្នឹងតែម្តងទៅ។

[០៩:១៨:២៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្តតើអស់លោក លោកស្រីចៅក្រមមានសំណួរអ្វីចង់សួរដល់សាក្សីរូបនេះទេ?

បើមាន សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ ខ្ញុំជាចៅក្រម ហ្សង់ម៉ាក ឡាវែន៍។ ជម្រាបសួរលោក សួង ស៊ីគឿន។ ខ្ញុំមានសំណួរមួយចំនួនសួរទៅលោក។ ខ្ញុំសូមសួរលោកទាក់ទងទៅនឹងបរិបទប្រវត្តិសាស្ត្រ គឺថាត្រឡប់មកនិយាយអំពីរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ លោកសាក្សីតើលោកអាចជម្រាបជូនបានទេ ថាមានមាគ៌ានយោបាយមួយច្បាស់លាស់ ហើយនិងរួមរវាងក្រុមជាច្រើនដែលផ្សំ -- ដែលជាធាតុផ្សំនៃរាជរដ្ឋាភិបាលកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា ឬក៏គ្រាន់តែជាសម្ព័ន្ធភាពទាញយកប្រយោជន៍រៀងៗខ្លួន មិនស៊ីគ្នា? តើក្រុមផ្សេងៗនេះមានចំណុចរួមដែរឬទេ ដែលថាក្រុមបង្កើតជាសម្ព័ន្ធភាពនេះ?

[០៩:១៩:៤០]

**លោក សួង ស៊ីគឿន៖**

**ឆ៖** រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែលមានសម្តេចព្រះនរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៅពេលនោះជាប្រធាន គឺមានកម្មវិធីច្បាស់លាស់របស់វា។ គឺទី១ ខាងផ្នែកក្នុងប្រទេស រំដោះប្រទេសចេញពីអន្តរាគមន៍របស់ចក្រពត្តិអាមេរិក ហើយនិងរបបអាយ៉ងជាសាធារណរដ្ឋខ្មែរនៅពេលនោះ។ ខាងផ្នែកកសាងប្រទេស គឺមានការជជែកពិភាក្សាគ្នា ខាងសម្តេចព្រះនរោត្តម សីហនុ គាត់ លោកចង់ឲ្យដាក់កសាងសង្គមនិយម។ អានេះ ខ្ញុំសូមជម្រាបលោកចៅក្រម ខ្ញុំនិយាយពីប្រវត្តិសាស្ត្រទេ ខ្ញុំអត់មាននិយាយអីលើសពីហ្នឹងទេ គឺគាត់ចង់ដាក់កសាងសង្គមនិយមអី

អ៊ីចឹង។ ប៉ុន្តែកាលពេលនោះ ពេលដែលជជែកពិភាក្សាពីកម្ពុជារណសិរ្សនេះគឺថា លោក ប៉ុល ពត ពេលនោះ គាត់នៅទីក្រុងប៉េកាំង ហើយតាមរយៈផ្នែកចិន ក៏គាត់ជំទាស់នឹងការដាក់ពាក្យ "សង្គមនិយម" នេះ។ គាត់ដាក់ថា គឺថាធម្មតាកសាងប្រទេសកម្ពុជាមួយអព្យាក្រឹត្យ សន្តិភាព ឯករាជ្យ ក្នុងបូរណភាពដែនដី។ ហើយក្រៅប្រទេសគឺ ប្រកាន់យកនយោបាយមិនចូលបក្សសម្ព័ន្ធ គឺមិនចូលខាងប្លុកសង្គមនិយម ដែលមានសហភាសូវៀត ជាមេខ្លោង និងប្លុកប្រទេសខាងលិច ពេលនោះគឺថា មានអង្គការមួយនៅអាស៊ីអាគ្នេយ៍ ហៅថា អង្គការ សេ.អា.តូ។ អង្គការ សេ.អា.តូ គឺថាមានប្រទេសដូចជា ថៃឡង់ដ៍ បាគីស្ថាន ហ្វីលីពីន អីអ៊ីចឹងគឺថា ដែលមានសហរដ្ឋអាមេរិក ជាដឹកនាំដែរ។ ដូច្នោះនៅកណ្តាល ជានយោបាយអព្យាក្រឹត្យ នេះបើតាមខ្ញុំចាំជារួមៗប៉ុណ្ណោះបាទ។

[០៩:២២:១៥]

**សៈ** តើលោកយល់ឃើញថា ទស្សនៈរបស់ នរោត្តម សីហនុ គឺជាទស្សនៈ ដូចទស្សនៈ ប៉ុល ពត និង បក្ខជនរបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ ចំពោះអនាគតរបស់ប្រទេសកម្ពុជា?

**ឆៈ** ខ្ញុំមិនបានដឹងអីច្បាស់លាស់ទេ ប៉ុន្តែតាមខ្ញុំសង្កេតមើលជាប្រវត្តិសាស្ត្រគឺ ក្នុងឋានៈខ្ញុំជាកូនខ្មែរមួយរូប ខ្ញុំយល់ថា ឲ្យយើងកើតមកជាខ្មែរ សាច់សជាខ្មែរ យើងមានមោទនភាពណាស់ ចំពោះប្រទេសជាតិយើង ចំពោះអតីតកាលដ៏រុងរឿងរបស់យើង ហើយយើងតែងតែគិតថា រួមកម្លាំងគ្នា មិនបែងចែកវណ្ណៈ មិនបែងចែកពូជសាសន៍ មិនបែងចែកសាសនាអីទាំងអស់ ដើម្បីធ្វើយ៉ាងណាឲ្យប្រទេសយើងថ្កុំថ្កើងរុងរឿង ឯករាជ្យ ប្រជាធិបតេយ្យ ក្នុងក្របខ័ណ្ឌព្រំដែនកម្ពុជាយើងបច្ចុប្បន្ននេះ។ ខ្ញុំគិតថាអ្នកដឹកនាំកម្ពុជាគ្រប់សម័យ ហើយការគិតគូរនេះ ខ្ញុំឃើញថា ការគិតគូរពេលនេះ ខ្ញុំថា គ្រប់សម័យគឺថា តែងតែស្រឡាញ់ជាតិ តែងតែស្រឡាញ់ប្រទេសជាតិ។ ដូច្នោះ អ្វីៗដែលកើតក្រោយឡើងនេះគឺថាមិនមែនជាឆន្ទៈផ្ទាល់របស់អ្នកដែលជា -- អ្នកសមាជិករណសិរ្សរួបរួមជាតិកម្ពុជាទេ ដែលខ្ញុំបាននិយាយ។ ហើយចំពោះសម្តេចព្រះ នរោត្តម សីហនុ ខ្ញុំយល់ឃើញថា ព្រះអង្គប្រកាន់នូវស្មារតីនេះខ្ពង់ខ្ពស់ណាស់ ហើយខ្ញុំសូមឆ្លៀតឱកាសនេះ ថ្វាយបង្គំគោរពចំពោះព្រះអង្គ ហើយសូមទោសព្រះអង្គចំពោះអ្វីៗ ដែលកន្លងមក ខ្ញុំបានមានមតិចំពោះព្រះអង្គ មិនមែនមតិផ្ទាល់ទេ ចំពោះដូចថា វណ្ណៈសក្តិភូមិជិះជាន់អីបរិវារ អាណានិគមនិយមបាំងអីនេះគឺថា ខ្ញុំសូមអភ័យទោសចំពោះព្រះអង្គ ហើយជូនពរព្រះអង្គបាទ ជូនពរព្រះអង្គឲ្យមានព្រះជន្មាយុយឺនយូរ ដើម្បីជាម្លប់ដ៏ត្រជាក់របស់ប្រទេសជាតិយើង របស់ប្រជាជនយើងទាំងមូល។ បាទ សូមចប់។

[០៩:២៥:២៣]

**ស៖** បាទ លោកសាក្សី តើខ្ញុំត្រូវយល់ថា លោកបញ្ជាក់ថា នរោត្តម សីហនុ ហើយនិង ប៉ុល ពត មានទស្សនវិស័យដូចគ្នា នៅចន្លោះឆ្នាំ -- នៅឆ្នាំ១៩៧០ នៅពេលដែលគេធ្វើរដ្ឋប្រហារទម្លាក់ នរោត្តម សីហនុ ឬក៏យ៉ាងម៉េច? ព្រោះថា អ្វីដែលលោកនិយាយហាក់ដូចថា ធ្វើឲ្យខ្ញុំទាញការសន្និដ្ឋាន យ៉ាងដូច្នេះ។ មានមនុស្សបួននាក់សំខាន់ នៅក្នុងរណសិរ្សរួបរួម តុង ស៊ិន, សីហនុ, ប៉ែន នុត ហើយនិង អៀង សារី ហើយមួយទៀត នៅប្រទេសខ្មែរនោះគឺ ខៀវ សំផន នៅសម័យនោះ គឺថាសាធារណជន ទាំងអស់ហ្នឹង យល់ឃើញថា មនុស្សទាំងបួនរូបនេះ ជាមនុស្សសំខាន់។ តើអ៊ីចឹងមែនទេ?

[០៩:២៦:១៩]

**ឆ៖** បាទ លោកចៅក្រមបញ្ជាក់ពីឈ្មោះទី១ ខ្ញុំស្តាប់មិនបានបាទ។

**ស៖** ខ្ញុំនិយាយថា ចំពោះសាធារណជននោះ ទំនងជាមានមនុស្សបួននាក់សំខាន់នៅក្នុង ហ្វុង រណសិរ្សរួបរួមជាតិ ថាមួយនៅប្រទេសចិន គឺថា សីហនុ, ប៉ែន នុត និង អៀង សារី ហើយមួយទៀត នៅប្រទេសខ្មែរ គឺ ខៀវ សំផន តើអ៊ីចឹងមែនទេ?

**ឆ៖** ក្នុងពេលនោះ ជារណសិរ្សមនុស្សសំខាន់ មែនទែន មានតែម្នាក់ គឺសម្តេចព្រះ នរោត្តម សីហនុ ជាប្រមុខរដ្ឋតែម្នាក់ទេ មិនមានបុគ្គលអីច្រើននាក់។ បើបន្ទាប់មក អាហ្នឹងមានដែរ មានដូចថា សម្តេច ប៉ែន នុត លោកជាសហការីយូរអង្វែង ស្មោះត្រង់ ហើយជាជនស្នេហាជាតិដ៏ឆ្នើមមួយរូប ដែលខ្ញុំសូមគោរព ហើយដែលខ្ញុំមានកិត្តិយស និងបានស្គាល់គាត់ផ្ទាល់ ធ្វើ -- ហើយនៅក្នុងប្រទេស ដូចខ្ញុំបានជម្រាបហើយ នៅក្នុងប្រទេស គឺថាមានបីនាក់ ដែលប្រជាជាជនកម្ពុជាជាទូទៅ ហើយជា ពិសេសយុវជនគោរពស្រឡាញ់ គឺមានលោក ខៀវ សំផន, លោក ហ៊ូ យន់ និងលោក ហ៊ូ នឹម បាទ។ ចំណែកលោក អៀង សារី ក៏ប្រជាជនមិនសូវស្គាល់ទេ ព្រោះគាត់ នែ៎ គេស្គាល់គាត់តែក្នុងមជ្ឈដ្ឋាន បញ្ញាជនមួយចំនួនប៉ុណ្ណោះបាទ។

[០៩:២៨:២៥]

**ស៖** លោកអាចនិយាយយ៉ាងដូចម្តេចដែរ ពីទំនាក់ទំនងរវាង អៀង សារី និងព្រះអង្គម្ចាស់ នរោត្តម សីហនុ តើជាទំនាក់ទំនងដែលមានការលំបាក ឬក៏ឧបទ្ទវហេតុអ្វីមួយដែលលោកធ្លាប់ឃើញ ឬក៏ជាការទាក់ទងគ្នាដ៏រលូន តាំងពីដើមមករហូត?

**ឆ៖** ខ្ញុំមិនបានដឹង ដូចថា ឲ្យចូលល្អិតអំពីការទាក់ទងរវាងឥស្សរជនទាំងពីររូបនេះទេ។ ខ្ញុំគិត

ថា សម្តេចព្រះ នរោត្តម សីហនុ លោកមានទស្សនៈច្បាស់លាស់ ហើយលោកធ្លាប់បានដឹកនាំគ្រប់គ្រងប្រទេស រក្សាបាននូវឯករាជ្យភាព សន្តិភាព ១៥ឆ្នាំ ក្នុងកាលៈទេសៈប្រវត្តិសាស្ត្រមួយដ៏សែនលំបាកដ៏សែនស្មុគស្មាញ ហើយក្នុងក្របខ័ណ្ឌនៃភូមិសាស្ត្រនយោបាយមួយ ដ៏សែន ដ៏មានគ្រោះថ្នាក់។ ដូច្នោះជាមហាស្នាដៃដ៏អស្ចារ្យណាស់ ដែលរក្សាប្រទេសយើងបាន១៥ឆ្នាំ ក្នុងសភាពការណ៍ដែលយើងទទួលការគាបសង្កត់នៅកណ្តាលគេ ឃើញទេ! នៅកណ្តាល--

[០៩:៣០:០៥]

**ស៖** លោកសាក្សី តើលោកអាចឆ្លើយតបនឹងសំណួរខ្ញុំដែរឬទេ? សំណួរខ្ញុំច្បាស់លាស់ណាស់អម្បាញ់មិញនេះ គឺថាខ្ញុំចង់ដឹងថា តើធ្លាប់មានឧបទ្ទវហេតុ ឬក៏ជម្លោះរវាងសម្តេច សីហនុ ហើយនិងអៀង សារី ដែរឬទេ នៅពេលដែលលោកទាំងពីរនៅទីក្រុងប៉េកាំង? តើលោកមានចាំទេ អំពីការទស្សនកិច្ចដែលដឹកនាំដោយសម្តេច សីហនុ នៅក្នុងប្រទេសអឺរ៉ុបមួយចំនួន ហើយនិងប្រទេសអាហ្វ្រិកមួយចំនួននៅឆ្នាំ៧៣? តើទស្សនកិច្ចនេះបានប្រព្រឹត្តទៅក្នុងលក្ខខណ្ឌល្អរវាងបុគ្គលទាំងពីររូបនេះដែរឬទេ?

**ឆ៖** ខ្ញុំអាចឆ្លើយបាន ថាហួសពីក្របខ័ណ្ឌហ្នឹងទៅទៀត។ ឧបមាថាខ្ញុំមិនចូលល្អិតអំពីការដែលដូចថាចរិត ការរស់នៅ លក្ខណៈសម្បត្តិផ្ទាល់ខ្លួនទេ ព្រោះអាហ្នឹងខ្ញុំមិនសូវបានចូលល្អិត ខ្ញុំមិននេះទេ។ ប៉ុន្តែខ្ញុំលើកឧទាហរណ៍មួយដូចថា នៅទស្សនកិច្ចនៅប្រទេសទាំងអស់នេះ តាម -- ព្រោះខ្ញុំបានចូលរួមចំណែកក្នុងការចូលរួមដំណើរនេះខ្លះដែរ មិនមានជាបញ្ហាអីទេ ពីព្រោះខ្ញុំនិយាយមិនមានបញ្ហាអីទេ។

[០៩:៣១:៣៤]

បញ្ហាមួយដែលអាចមានជាបញ្ហា ហើយវាជាប់ទាក់ទងទៅនឹងសំណួររបស់លោកចៅក្រម គឺនៅឆ្នាំ១៩៧៣ លោកចៅក្រមដឹងហើយថាមានសន្និសីទនៅទីក្រុងប៉ារីសក្នុងពេលនោះ គេនិយាយអំពីរវាងសហរដ្ឋអាមេរិក និងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ដើម្បីមានការចរចាសន្តិភាពនៅទីក្រុងប៉ារីស។ ពេលនោះ គឺថាវៀតណាម ទាំងវៀតណាម ទាំងសហរដ្ឋអាមេរិកក៏ចង់ឲ្យខាងផ្នែករណសិរ្សរួបរួមជាតិកម្ពុជាចូលរួមសន្និសីទនេះ ហើយមានការសម្របសម្រួលជាមួយនឹងសាធារណរដ្ឋខ្មែររបស់សេនាប្រមុខ លន់ នល់។

គោលជំហររបស់ផ្នែកតស៊ូ ផ្នែកក្នុងប្រទេសនៃរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជាដែលមានលោក អៀង សារី ជាតំណាង គឺថាជំទាស់នឹងការចរចា ហើយនិងការសម្រុះសម្រួល

រវាងរណសិរ្ស ហើយនិងសាធារណរដ្ឋខ្មែររបស់លោកសេនាប្រមុខ លន់ នល់។ ហើយខ្ញុំចាំច្បាស់ថា សម្តេចព្រះនរោត្តម សីហនុ ព្រះអង្គក៏ឯកភាពនឹងជំហរនេះដែរ។ ដូច្នោះលើបញ្ហាធំដែលជាអាយុជីវិតរបស់ប្រទេសជាតិនេះ គឺភាគីទាំងពីរគឺយល់ឯកភាពគ្នាបាទ។

[០៩:៣៣:១៩]

ពិតមែនហើយ មានការដូចថារកាំរកូស អាហ្នឹងជាបញ្ហាផ្ទៃក្នុង យើងមិនអាចបដិសេធបានទេបាទ។ ប៉ុន្តែចលនាតស៊ូ ជារួមនៅពេលនោះ ចលនាតស៊ូឯកភាពគ្នាថា នឹងបន្តការតស៊ូដោយមិនមានការចរចា មិនមានការសម្រុះសម្រួលជាមួយសាធារណរដ្ឋរបស់សេនាប្រមុខ លន់ នល់ ទេបាទ។

**ស៖** ការព្រមព្រៀងហ្នឹងគឺថា មិនទទួលបានក្នុងរយៈពេលវែងទេមែនទេ គឺថាមានការមិនទុកចិត្តគ្នា ចួនកាលទៅសម្តេចសីហនុ គាត់គិតថាដើម្បីជាផលប្រយោជន៍ទាំងអស់គ្នានោះ គឺថាត្រូវតែមានការសម្រុះសម្រួលគ្នា ឬក៏យើងអាចនិយាយបានថា វាមាននិន្នាការរឹងត្អឹងដែលសម្រាប់តម្រង់ទិសអ្វីៗនោះ?

[០៩:៣៤:៤១]

**ឆ៖** ខ្ញុំគិតថាខ្ញុំមិនអាចនឹងដឹងបានទេ ព្រោះពេលនោះខ្ញុំមិនមែនជា នៅក្នុងក្រុមអ្នកដឹកនាំកិច្ចការនយោបាយទេ អ្វីដែលខ្ញុំអាចដឹង ហើយខ្ញុំអាចជម្រាបលោកចៅក្រម និងសវនាការទាំងមូលចំពោះទស្សនៈរបស់ក្រុមដែលខ្ញុំស្ថិតនៅ ខ្ញុំយល់ថា ទស្សនៈជារួមគឺ ដើម្បីឲ្យប្រទេសជាតិបានរក្សាឯករាជ្យមានអធិបតេយ្យភាព ហើយប្រជាជនមានជីវភាពរុងរឿង ថ្កុំថ្កើង ប្រទេសជាតិបានរីកចម្រើន ត្រូវប្រកាន់យកលទ្ធិសង្គមនិយម និងកុម្មុយនីស្តនិយម។ ដូច្នោះ លទ្ធិនិយម -- កុម្មុយនីស្តនិយម និងសង្គមនិយមគ្រាន់តែជាមធ្យោបាយទេ មិនមែនជាទិសដៅទេ។ ណេះ អាហ្នឹងដែលច្បាស់លាស់។ ដូច្នោះហើយដល់ការពិសោធក្រោយៗមកឃើញថា បញ្ហានេះ ផ្លូវដើរនេះវាទៅមិនរួចបានជាយើងទាំងអស់គ្នាឯកភាពថា ធ្វើសង្គមនិយម ធ្វើកុម្មុយនីស្តនិយម តាមរបៀបដែលកន្លងមកនេះគឺផ្លូវមួយដែលយើងទៅមិនរួចទេ។ នាំឲ្យបែកបាក់កម្លាំង នាំឲ្យប្រទេសជាតិយើងទន់ខ្សោយ នាំឲ្យអន្តរាយដល់ទិសដៅសំខាន់របស់អ្នកស្នេហាជាតិនីមួយៗ។

[០៩:៣៦:២៩]

ខ្ញុំយល់ថា យើងឯកភាពគ្នាមិនប្រកាន់យកផ្លូវដើរនេះទៀតទេ ហើយតាមខ្ញុំដឹងច្បាស់ សូមអស់លោកកុំខ្លាចថា ខ្មែរក្រហមវិលមកវិញនោះ កុំខ្លាចអី មិនមានទេ។ ព្រោះខ្មែរក្រហមឆ្អិនឆ្អៅ មោះមុត

មិនមានៗគិតដូច្នោះទេ ព្រោះអី ព្រោះផ្លូវដែលដើរមកនេះវាខ្លោចផ្សា ឈឺចាប់ណាស់ ហើយមនុស្ស ដូចថា ឆ្នាំដែលត្រូវលោកទឹកក្តៅម្តងហើយ គ្រាន់តែទឹកត្រជាក់ក៏វាខ្លាចដែរ អាហ្នឹងលោកចៅក្រមដឹង ភាសិតបារាំងថា អ៊ីចឹងហើយបាទ។ គឺថាអ៊ីចឹង ដូច្នោះ សូមកុំបារម្ភមិនមានអីអ៊ីចឹងទេ។ បញ្ហាខ្មែរ សព្វថ្ងៃនេះ គឺយើងទាំងអស់គ្នា គោរព ហើយមិនមែនគោរពហើយ សុខចិត្ត សុខថ្លើមរស់នៅក្រោម របបបច្ចុប្បន្ននេះ ជារបបមួយដែលប្រទេសជាតិយើងស្តារសភាពការណ៍បច្ចុប្បន្ននេះ គឺជាមោទនភាព របស់ជាតិយើង។ របស់ខ្មែរ ព្រោះអ្វីដែលកើតឡើង ហើយអ្វីដែលបានកើតនៅបច្ចុប្បន្ននេះ គឺយើងដើរ ផ្លូវដែលយើងដើរមកនេះវាត្រឹមត្រូវហើយ ដូច្នោះមានតែម្នាក់ៗខំប្រឹងប្រែងបន្តផ្លូវនេះតទៅទៀតទេ។ កុំចង់ឆ្លីះជើងគ្នា កុំចង់ -- ហើយសូមកុំធ្វើម៉េចឲ្យមានសង្គ្រាមឡើងវិញ។ ព្រោះខ្មែរយើងតែមានសង្គ្រាម ឡើងវិញ ទុកតែសង្គ្រាមផ្ទៃក្នុងគឺយើងហិនហោចហើយបាទ។ ខ្ញុំសូមចប់។

[០៩:៣៨:៤៧]

**ស៖** លោកសាក្សីអម្បាញ់មិញនេះ ខ្ញុំមិនចង់កាត់លោកទេ ខ្ញុំចង់ឲ្យលោកឆ្លើយត្រង់ៗទៅនឹង សំណួររបស់ខ្ញុំ ហើយសូមចៀសវាងការធ្វើអត្ថាធិប្បាយផ្ទាល់ខ្លួន ព្រោះថាវាមិនពាក់ព័ន្ធអ្វីដែលខ្ញុំចង់សួរ នោះទេ។ ឥឡូវនេះ ខ្ញុំចង់និយាយអំពីតួនាទីរបស់លោកនៅក្នុងផ្នែកព័ត៌មាននៃក្រសួង តើលោកអាច ប្រាប់បានទេ ថាលោកទទួលព័ត៌មានប្រភេទណាខ្លះ? ហើយទទួលពីប៉ុស្តិ៍ណាខ្លះ? ខ្ញុំចង់សំដៅទៅលើ ព័ត៌មានពីខាងក្រៅ ឬក៏ព័ត៌មានដែលទទួលបានពីកម្ពុជា។

**ឆ៖** ពេលដែលខ្ញុំទទួលខាងផ្នែកឃោសនា និងព័ត៌មាននៅក្នុងក្របខ័ណ្ឌរណសិរ្សរួបរួមជាតិ កម្ពុជា នៅប្រទេសចិន នៅប្រទេស -- នៅទីក្រុងប៉េកាំង ខ្ញុំបានទទួល គឺថាវាមានព័ត៌មានផ្សេងៗពីសារ -- ទីភ្នាក់ងារសារព័ត៌មានបរទេស គឺប្រភពដែលខ្ញុំទទួលបានហ្នឹងគឺថា មានបីប្រភព។ ទី១ អា.អេហ្វ. ប៉េ គឺថាទីភ្នាក់ងារសារព័ត៌មានបារាំង។ ទី២ ទីភ្នាក់ងារសារព័ត៌មានស៊ីនហួរនៅប្រទេសចិន វានៅស្រុក ចិនស្រាប់ហើយបាទ។ ហើយទី៣ គឺទាក់ទងនឹងដំណឹងពីខាងក្នុង ដំណឹងពីសមរភូមិ គឺខ្ញុំទទួលព័ត៌មាន ពីទីភ្នាក់ងារព័ត៌មានវៀតណាមបាទ។

**ស៖** ច្បាស់ជាងនេះទៅទៀត ពាក់ព័ន្ធនឹងព័ត៌មានមកពីសមរភូមិ តើលោកដឹងអំពីការវិវត្តន៍នៃ ស្ថានការណ៍យោធានៃកម្ពុជាដែរឬទេ? ឬក៏ការវិវត្តន៍នៃស្ថានភាពប្រយុទ្ធគ្នាពីតំបន់រំដោះ តើលោកបាន ដឹងពីអ្វីខ្លះ? លោកទទួលបានព័ត៌មានអ្វីខ្លះដែរ? តើព័ត៌មានយោធាលោកទទួលបានទេ?

[០៩:៤១:១៨]

**ឆ៖** ព័ត៌មានយោធាពីក្នុងប្រទេស ខ្ញុំទទួលតាមរយៈសំឡេងវណសិរ្សរួបរួមជាតិកម្ពុជា ដែលផ្សាយពីទីក្រុងហាណូយបាទ។ អាហ្នឹងដំណឹងក្នុងប្រទេស ខ្ញុំមិនបានទទួល ហើយនិងទីភ្នាក់ងារព័ត៌មាន អា.កា.អ៊ី។ ទីភ្នាក់ព័ត៌មាន អា.កា.អ៊ី នេះគឺថា កាលនោះគឺធ្វើតាមរយៈទីក្រុងហាណូយបាទ។

**ស៖** តើចេញពីព័ត៌មានទាំងអស់នេះ យើងអាចយល់បានថា នៅពេលដែលក្រុងស្ថិតនៅក្នុងកណ្ដាប់ដៃរបស់តំបន់រំដោះនោះ គឺថាមានការជម្លៀសប្រជាជន តើមែនទេ?

**ឆ៖** ពេលនុ៎ង សូមជម្រាបទៅ ខ្ញុំមិនបានដឹងទេ ថាមានការជម្លៀសប្រជាជននៅពេលដែលកងទ័ពតស៊ូរំដោះបានទឹកដីមួយចំនួននោះ។ ខ្ញុំដឹងពីការជម្លៀសនេះ ពេលដែលខ្ញុំត្រឡប់ចូលទៅក្នុងប្រទេសវិញ ខ្ញុំឃើញនៅទន្លេសេសាន ប្រជាជនដែលជម្លៀសចេញពីទីក្រុងភ្នំពេញ មានជាពិសេសគឺថាពួកជនជាតិដែល -- ពួកអ្នកដែលនៅផ្សារមានភាព សៗ។ ពេលដែលខ្ញុំត្រឡប់ពីហាណូយវិញ បានខ្ញុំដឹងថាមានការជម្លៀសបាទ។

[០៩:៤៣:០៣]

ហើយខ្ញុំសូមបញ្ជាក់ទៀត ព្រោះអាហ្នឹងវាចូលទៅដើម្បីជាការយល់រួម ខ្ញុំមិនដឹងថាតើលោក អៀង សារី គាត់ដឹង ឬមិនដឹងទេ ពីផែនការជម្លៀសនេះ ប៉ុន្តែបើតាមខ្ញុំចាំពេលដែលខ្ញុំនៅទីក្រុងហាណូយ នៅបំពេញភារកិច្ចនៅទី -- នៅវិទ្យុ នៅស្ថានីយវិទ្យុសំឡេងវណសិរ្សរួបរួមជាតិកម្ពុជា លោក អៀង សារី បានបើកវគ្គអប់រំពួកយើងខ្ញុំដែលធ្វើការទីនោះ ហើយគាត់បានណែនាំអំពីការដែលប្រទេសរំដោះ -- កម្ពុជារំដោះទៅ យើងជាអ្នកតស៊ូ យើងត្រូវរស់នៅលាយឡំគ្នាក្នុងចំណោមប្រជាជនចាស់នៅទីក្រុងភ្នំពេញ។ ថាយើងត្រូវមានគោលជំហរ ត្រូវមានអាកប្បកិរិយាយ៉ាងណា ត្រូវប្រកាន់នូវសីលធម៌ ហើយនិងមានជីវភាពរស់នៅបែបណា។

ដូច្នោះក្នុងការអប់រំនេះ មិនមានគឺថា គិតថានឹងជម្លៀសប្រជាជនចេញពីភ្នំពេញនោះទេបាទ។ អាហ្នឹងខ្ញុំសូមជម្រាបជាក់ស្តែងបានប៉ុណ្ណឹងបាទ។

[០៩:៤៤:៤៥]

**ស៖** ប្រសិនបើខ្ញុំច្រឡំ សូមលោកប្រាប់ខ្ញុំ ខ្ញុំសន្និដ្ឋានថា ព័ត៌មានទាំងអស់ដែលលោកទទួលបានទាំងពីប៉េកាំង ឬក៏ហាណូយនោះ គឺអាចឲ្យ -- មិនអាចឲ្យគេគិតថាទីក្រុងដែលយកបានដោយតំបន់រំដោះនុ៎ង គឺថាមិនមាន -- មិនដឹងថាមានការជម្លៀសឬក៏អត់ទេ មែនទេ? គឺមានន័យថា មិនអាចដឹងអំពីព័ត៌មានបែបនេះទេ មែនទេ?

**ឆ៖** បាទ គឺដូច្នេះ គឺថា តាមព័ត៌មានទាំងនោះ គេមិនអាចដឹងថា មានការជម្លៀសប្រជាជនចេញពីទីក្រុងទេបាទ។

**ស៖** ខ្ញុំចង់ទៅឲ្យលឿនបន្តិច ឥឡូវនេះខ្ញុំចង់ត្រឡប់មកនិយាយអំពីរយៈពេលដែលលោកផ្ទាល់ត្រឡប់ចូលមកកម្ពុជា។ លោកបានឆ្លើយថា លោកបានស្នាក់នៅកន្លែងមួយដែលគេហៅថាមន្ទីរប-២០។ ប្រសិនបើខ្ញុំមិនច្រឡំទេ លោកឆ្លើយថានៅទីនោះលោកទទួលបានការអប់រំ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** នៅប-២០ មិន -- ខ្ញុំគ្រាន់តែឆ្លងកាត់ទេ ហើយឥឡូវខ្ញុំនឹកឃើញអ្នកដែលទទួលខុសត្រូវហើយ គឺថាគាត់ទទួលខុសត្រូវជិះរំហ្នឹងឈ្មោះ ភុំ។ ភុំ នេះ បើតាមព័ត៌មានក្រោយមក ពេលនោះខ្ញុំអត់ដឹង គឺថាគាត់ជាប្អូនបង្កើតរបស់នៃ ដូចអ្នកដឹកនាំចាស់ម្នាក់ ប៉ុន្តែខ្ញុំមិនច្បាស់ឈ្មោះទេ ដូចថា ដូចលោក កែវ មុនី ឬលោក ចិន្តា ទេ ខ្ញុំមិនច្បាស់។ ប៉ុន្តែអ្នកហ្នឹងឈ្មោះ ភុំ។ មិនមានការអប់រំអីទេ ព្រោះមិនមាន -- ខ្ញុំបាន -- អានេះខ្ញុំបានសរសេរក្នុងសេចក្តីព្រាងអត្តបទ -- អំ! សេចក្តីព្រាងនិក្ខេបបទរបស់ខ្ញុំហើយ គឺគ្រាន់តែប្រជុំ ៗការងារស្រាល។ ហើយពួកខ្ញុំហ្នឹងទទួលបន្ទុកដាំចេកបាទ។

[០៩:៤៧:២៤]

**ស៖** ដូច្នេះមិនមែនជាការអប់រំកែប្រែទេមែនទេ?

**ឆ៖** បាទៗ ខ្ញុំផ្ទាល់អត់មានទទួលការអប់រំកែប្រែនៅទីនោះទេបាទ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញជូនសាក្សីនូវឯកសារមួយ ដែលមាននៅក្នុងសំណុំរឿង ហើយមានលេខ IS6.9។ ឯកសារនេះមានចំណងជើងជាភាសាបារាំងថា "ពាក់ព័ន្ធទៅនឹងការអនុវត្តនយោបាយបង្រួបបង្រួមបក្ស"។ ឯកសារនេះមានលេខ ERN ភាសាខ្មែរ 00072400 រហូតទៅដល់ 407, ជាភាសាបារាំង 00611566 ទៅដល់ 70, ជាភាសាអង់គ្លេស 00244274។ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញឯកសារនេះជាភាសាខ្មែរជូនសាក្សី។

**ប្រធានអង្គជំនុំ៖**

បាទសូមអញ្ជើញ!

មន្ត្រីរដ្ឋបាលតុលាការទទួលយកឯកសារជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[០៩:៤៩:៤៤]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ខ្ញុំសូមបញ្ជាក់ថា ឯកសារនេះគឺជាសេចក្ដីណែនាំ ហើយឯកសារនេះមានបញ្ជាក់នៅក្នុងជើងទំព័រជាច្រើននៃដីកាដំណោះស្រាយ ជាពិសេសនៅក្នុងជើងទំព័រ៤៤៥៦ និង៤៤៥៧។ លោកសាក្សី អ្វីដែលខ្ញុំចាប់អារម្មណ៍នោះ គឺឃ្លាដំបូង គឺនៅទំព័រទី២ ជាភាសាបារាំង គឺនៅ ERN 00244275 ទៅដល់ 00244276 ជាភាសាអង់គ្លេស, ហើយជាភាសាខ្មែរ 00072402 ទៅដល់ 4023។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកប្រធាន តើយើងអាចបង្ហាញឯកសារនេះនៅលើអេក្រង់បានដែរឬទេ?

**ប្រធានអង្គជំនុំ៖**

បាទ មានបង្ហាញរួចហើយ បាទ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទាងឈេ៖**

សូមអរគុណលោកប្រធាន។ លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ អ្វីដែលយើងមាននៅក្នុងអេក្រង់នេះគឺលេខ IS6.2 ទេ។ ហើយខ្ញុំគិតថា 6.9 អម្បាញ់មិញនេះគឺខុសហើយ។ អ៊ីចឹងសូមឲ្យលោកចៅក្រមកែ។

[០៩:៥១:៥២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំសុំទោស គឺតាមពិតទៅ គឺ 6.2 ទេ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ខ្ញុំសូមអានឃ្លាដំបូងដែលបានសរសេរដូចតទៅនេះ "ពាក់ព័ន្ធទៅនឹងខាងក្រៅ តើមានអ្វីខ្លះប្ដូរខ្លះ? នៅខាងក្រៅប្រទេសមានការផ្លាស់ប្ដូរជាច្រើន ដែលមានចរិតលក្ខណៈដូចតទៅនេះ៖ ទី១ រណសិរ្សខាងក្រៅត្រូវចូលមកក្នុងប្រទេស គ្មាននៅក្រៅទៀតទេ។ ពោលគឺយើងបានបញ្ចប់អង្គការដឹកនាំក្រៅប្រទេសនេះហើយ បានដោយស្រួល និងដោយគ្មានឥទ្ធិពលអាក្រក់ទៅលើសកលលោកទេ។ ផ្ទុយទៅវិញ ឥទ្ធិពលនៅក្នុងពិភពលោកនេះ គឺថាមានភាពខ្លាំងក្លា។ ឥទ្ធិពលយើង គឺថាត្រូវបានបង្កើនថែមទៀត។ សកលលោកមិននឹកស្មានថា យ៉ាងនេះទេ។ ទី២ យកមកក្នុងប្រទេសហើយ យើងក្ដាប់នៅក្នុងដៃបានទាំងអស់ទៀត តាំងពី ប៉ែន នុត រហូតដល់ក្រោម។ កម្លាំងរណសិរ្សក្រៅប្រទេសនេះ មិនទាន់

ទាំងអស់ចេះតែ -- តែចេះតែមក។ សីហនុ ក៏យើងក្ដាប់បាន ដោយគាត់គ្មានអ្វីទាំងអស់ ទាំងសេដ្ឋកិច្ច ទាំងអំណាច។ ដូច្នេះត្រូវរណបយើងទាំងស្រុង ទាំងសម្ភារៈ ទាំងនយោបាយ។ បើប្រៀបធៀប គាត់នៅមានឥទ្ធិពលជាងអ្នកដទៃទៀត។ ពីមុនយើងប៉ានថា បើចេញពីយើងគាត់ត្រូវស្លាប់។ ដល់ឥឡូវ យើងក្ដាប់គាត់បានច្រើនជាងមុន ដោយយើងឈ្នះខ្លាំង។ យើងមានអ្វីៗទាំងអស់ អ្វីៗនៅលើយើង រហូតដល់វាំង ក៏ជាវាំងយើង។

[០៩:៥៣:៥៥]

ក៏ប៉ុន្តែយើងដំណើរការជាមួយគាត់បានស្រួល។ បច្ចុប្បន្ន គាត់ឃើញថា គាត់នៅជាមួយយើងបាន បើបានប៉ុណ្ណឹងគាត់ពេញចិត្តហើយ។ ឲ្យតែគាត់បាននៅក្នុងប្រទេសខ្លះ ទៅក្រៅប្រទេសខ្លះ។ នេះជាសភាពការណ៍ដែលពន្យារពេលឲ្យយើងពង្រឹង និងពង្រីកកម្លាំងយើងបាន។ បើថ្ងៃក្រោយ គាត់ប្រែប្រួលយើងប្រដូចគាត់បានទៅនឹងក្រម៉ គឺជ្រុះឯង គ្មាននរណាធ្វើអីទេ ដោយគ្មានការឈឺចាប់។ មិនមែនបូស ឬដំបៅទេ យើងគ្មានការព្រួយបារម្ភទេ មានតែចំណេញឲ្យយើងជាអតិបរមា។ ដូច្នេះ ធ្វើរណសិរ្សជាមួយពួកនេះ គ្មានអ្វីជាការលំបាកទេ ចាប់ពី ប៉ែន នុត មក។ ឯជាមួយសីហនុ ត្រូវមាននយោបាយបត្ថិច ប៉ុន្តែមិនលំបាកទេ ចាប់ពី ប៉ែន នុត មក។ ឯ សីហនុ ត្រូវមាននយោបាយបត្ថិច ប៉ុន្តែមិនលំបាកទេ ដូចនៅក្រៅប្រទេស សព្វថ្ងៃយើងចិញ្ចឹមគាត់ ចិញ្ចឹមបាយគាត់ទៀត”។ លោកសាក្សីតើលោកធ្លាប់ឃើញឯកសារនេះទេ? ហើយលោកអាចនិយាយបានអ្វីខ្លះពីឯកសារនេះ?

[០៩:៥៥:២២]

**ឆ៖** ខ្ញុំមិនដែលឃើញឯកសារបែបនេះទេ។ ដូច្នេះ ខ្ញុំមិនមានមតិអីទេ ចំពោះឯកសារដូច្នេះបាទ។ ក៏ប៉ុន្តែខ្ញុំអាច អឺ! អាចនឹងជម្រាបបាន គឺថានេះជានយោបាយនៅពេលនោះ។

**ស៖** ដូច្នេះ បើតាមលោកនោះគឺថា សេចក្ដីណែនាំនេះ វាត្រូវទៅនឹងតថភាពនយោបាយពិតប្រាកដនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើមែនទេ?

**ឆ៖** បាទ គឺខ្លឹមសារវាមិនខុសអី ពីនយោបាយជាក់ស្ដែងនៅពេលនោះទេបាទ។

**ស៖** ខ្ញុំសូមអាននូវសម្រង់មួយទៀត នៅទំព័រ៤ ជាភាសាបារាំង ខ្ញុំគិតថា ភាសាអង់គ្លេស ក៏ប្រហែលជាទំព័រ៤ដែរ ហើយក្នុងនោះនិយាយថា “ចំពោះខាងក្រៅ នៅពេលដែលគេនិយាយអំពីអ្នកដែលនៅក្រៅប្រទេស អ្នកដែលសុំចូលមកប្រទេសវិញ ពួកគេរស់នៅអឺរ៉ុបខាងកើត នៅសហរដ្ឋអាមេរិក ដែលពីដើមមក -- ដែលពួកគេសុទ្ធតែជាបញ្ញាជន គោលការណ៍របស់យើង គឺថាយើងប្រមូល

ឲ្យបាន មកជួបជុំគ្នាជាអតិបរិមា ប៉ុន្តែតាមមធ្យោបាយអីដែលពួកគេមក គឺស្រេចតែលើពួកគេទៅ។ យើងប្រមូលពួកគេ ដើម្បីកុំឲ្យពួកគេនៅបរទេស គឺធ្វើឲ្យយើងបាត់បង់ខាងផ្នែកនយោបាយ។ ប្រសិនបើយើងមិនប្រមូលទេ គឺថាពួកអាមេរិកហ្នឹង អាចប្រមូលយកមួយចំនួនហើយ ប្រសិនបើពួកគេមក ប៉ុន្តែយើងត្រូវប្រាប់ឲ្យពួកគេធ្វើអ្វី ពួកគេនឹងធ្វើការដោយប្រើកម្លាំងកាយ ប្រសិនបើមកឆ្នាំ៧២ ឆ្នាំ៧៣ ឆ្នាំ៧៤ ពួកគេត្រូវតែធ្វើពលកម្មដូចគ្នា បើមកឥឡូវរឹតតែធ្វើពលកម្មទៀត។ កម្លាំងនេះជាកម្លាំងបន្ទាប់បន្សំទេ ក៏ប៉ុន្តែយើងត្រូវហ្វឹកហ្វឺនពួកនេះ ដើម្បីកសាងពួកគេនៅក្នុងសង្គមថ្មី នៅក្នុងចលនាថ្មី"។ លោកសាក្សី នេះមានន័យថា អ្នកដែលមកពីក្រៅនោះ ត្រូវតែធ្វើការកសាងលត់ដំខ្លួន ហើយការអប់រំកសាងខ្លួននេះ គឺត្រូវតែឆ្លងតាមរយៈការធ្វើពលកម្ម។ តើអ៊ីចឹងមែនទេលោកសាក្សី?

[០៩:៥៨:៥០]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការដកឯកសារអំមិញនេះ ពីសាក្សី ហើយនិងដកចេញពីក្នុងកុំព្យូទ័រ!

**លោក សួង ស៊ីគឿន៖**

**ឆ៖** បាទ គឺអ៊ីចឹង គឺថា បញ្ញាជន គឺត្រូវឆ្លងកាត់តាមការលត់ដំខាងការងារពលកម្ម បង្កបង្កើនផល។ ហើយទន្ទឹមគ្នានឹងការអប់រំ បំពាក់បំប៉ន ខាងផ្នែកនយោបាយ ខាងផ្នែកសតិអារម្មណ៍។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** តើភាពចាំបាច់ក្នុងការបង្កើនសតិអារម្មណ៍ តាមរយៈការងារពលកម្មនេះមានការពន្យល់ទៅដល់បញ្ញាជនដែលគ្រោងចង់មកប្រទេសកម្ពុជាដែរឬទេ? ឬក៏គេប្រាប់ពួកគាត់អំពីថា -- គឺថាជាការងារដ៏អស្ចារ្យ យើងមិនបាច់ចាំបាច់មានប្រើកម្លាំងកាយអី ដើម្បីមកទេ?

**ឆ៖** ខ្ញុំមិនបានដឹងថា តើមុនពួកទាំងនោះ ត្រឡប់ចូលមកក្នុងប្រទេសវិញ អ្នកទទួលខុសត្រូវខាងរណសិរ្ស ឬខាងបក្ស បានប្រាប់គេយ៉ាងម៉េចទេបាទ។ ខ្ញុំមិនបានដឹងច្បាស់ទេបាទ។ ប៉ុន្តែខ្ញុំនៅប៉េកាំង ខ្ញុំត្រៀមត្រឡប់មកប្រទេសជាតិវិញដែរ ហើយពួកខ្ញុំជាបញ្ញាជនប៉ុន្មាននាក់ហ្នឹង ក៏ខំហាត់ហ្វឹកហ្វឺនជាកម្លាំងពលកម្ម ដូចថារត់ហាត់ប្រាណ ដើម្បីនឹងទម្លាប់ ដូចថា ដើរផ្លូវឆ្ងាយ ទម្លាប់ធ្វើការងារដោយនឿយហត់ដែរបាទ។ ព្រោះខាងស្មារតី ខាងសតិអារម្មណ៍អី ពួកយើងបានត្រៀមអស់ហើយ ប៉ុន្តែខាងកម្លាំងកាយ -- ខាងកម្លាំងពលកម្ម ពួកយើងមិនមានទម្លាប់ទេ។ ដូច្នោះ ត្រូវតែទម្លាប់ធ្វើការងារឲ្យនឿយ ឲ្យធ្ងន់ ដើម្បីនឹងដល់ចូលមកក្នុងប្រទេស យើងគឺថាមានទុនខ្លះៗ ដើម្បីប្រឈមមុខនឹង

សភាពការណ៍ជាក់ស្តែងនៅក្នុងប្រទេសបាទ។

[១០:០២:០៣]

**ស៖** ខ្ញុំសូមបញ្ជាក់ថា សេចក្តីណែនាំនេះ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥ ហើយនៅក្នុងខែដដែលនេះ លោក អៀង សារី បានស្នាក់នៅទីក្រុងប៉ារីស និងនៅទីក្រុងញូវយ៉ក ដែលនៅទីនោះ គាត់ចូលរួមក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ។ ហើយគាត់ទំនងជាធ្វើសេចក្តីថ្លែងការណ៍មួយចំនួន តើលោកអមដំណើរគាត់ទេ នៅបារាំង ហើយនៅអាមេរិកនោះ? តើលោកមានចាំទេថា លោក អៀង សារី បាននិយាយអំពីយថាភាព -- យថាហេតុនៃការងារធ្វើពលកម្មរបស់បញ្ញាជនដែលត្រូវត្រឡប់ចូលក្រុង -- ស្រុកវិញនេះ?

**ឆ៖** បាទ នៅពេលនោះ ខ្ញុំបានចូលរួមដំណើរគាត់ ទៅឆ្លងកាត់តាមប៉ារីស ហើយទៅចូលរួមមហាសន្និបាតអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក។ ប៉ុន្តែ ខ្ញុំមិនបានចាំខ្លឹមសារដែលគាត់ ពេលដែលគាត់ជួបជាមួយនិស្សិតនៅ -- ជាពិសេសនៅទីក្រុងប៉ារីស ខ្ញុំមិនចាំខ្លឹមសារណែនាំអីច្បាស់លាស់ទេបាទ។

[១០:០៣:២៧]

**ស៖** តើលោកបាត់បង់ការចងចាំ ឬក៏លោកមិនបាននៅទីនោះទេ នៅពេលនោះ? ឬក៏លោកមិនចង់នឹកឃើញ?

**ឆ៖** ខ្ញុំថា លោកចៅក្រមនិយាយអ៊ីចឹង គឺមានន័យថា ខ្ញុំមិនចង់និយាយ។ ខ្ញុំ តាមដែលខ្ញុំដឹងអ្នកដែលនិយាយច្រើនជាងគេ គឺខ្ញុំហើយ។ និយាយពីខ្មែរក្រហម មានអ្នកណា បញ្ញាជនណាគេនិយាយហូរហែដូចខ្ញុំ។ ហើយខ្ញុំមិនមានអីខាត ឬចំណេញនិយាយទេ ខ្ញុំនិយាយនេះ ដើម្បីឱ្យយល់។ អ្វីដែលខ្ញុំនិយាយ ខ្ញុំមិនចង់សម្រាលទោសអ្នកណាអីទេ ព្រោះ បើស្គាល់ខ្ញុំច្បាស់ ស្គាល់ប្រវត្តិខ្ញុំច្បាស់ ហើយខ្ញុំមិនចង់លាតត្រដាងនៅកន្លែងនេះទេ ព្រោះវាមិនមែនជាកន្លែងដែលខ្ញុំលាតត្រដាង។ បើខ្ញុំដឹង ខ្ញុំជម្រាបហើយ បើខ្ញុំមិនចងចាំ ហើយខ្ញុំមិនមែនមិនចាំ មិនចងចាំទេ -- មែនថាខ្ញុំមិនចង់ទេ ប៉ុន្តែ ខ្ញុំវាយូរឆ្នាំហើយ មើលយើងគិតមើល៍ ៣០, ៤០ ឆ្នាំហើយ ហើយខ្ញុំមិនចាំមែន។

ខ្ញុំចាំបានថាគាត់ប្រជុំនៅទីក្រុងប៉ារីស ប្រជុំហើយខ្ញុំបានចូលរួម។ ណោះ គាត់នេះ -- ក៏ប៉ុន្តែដូចខ្ញុំបានបញ្ជាក់អ៊ីចឹងគឺថាអ្នកដែលចូលរួមប្រជុំហ្នឹង គាត់មិនបាននិយាយក៏ពួកហ្នឹងគេមកដែរ។ ពេលហ្នឹងចលនានិស្សិតបញ្ញាជនចូលរួមប្រទេសសន្ធោសន្ធៅណាស់ ឃើញណោះ។ ហើយចួនកាលខ្ញុំគ្រាន់តែចាំ

បានប៉ុណ្ណឹង ហើយការចូលមកប្រទេស ខ្ញុំគិតថាបងប្អូនមិនគិតថាមានការលំបាកដល់ការជាក់ស្ដែងពេកទេ ក៏ប៉ុន្តែមានអ្នកមិនមកដែរ។ មានអ្នកមិនព្រមមកដែរ។ ហើយខ្ញុំស្គាល់ច្បាស់ ព្រោះខ្ញុំធ្លាប់ -- ខ្ញុំនៅប៉ារីស ខ្ញុំស្គាល់ច្បាស់។ ព្រោះអ្នកមិនមកហ្នឹងគឺ ថាខ្ញុំមើលសម្ដេចនាយករដ្ឋមន្ត្រីគាត់អញ្ជើញទៅណា អ្នកដែលអង្គុយជុំវិញគាត់នៅស្រុកបារាំងហ្នឹង ពួកហ្នឹងវាមក ពួកហ្នឹងអត់មកវិញទេ ពួកហ្នឹងមិនមក ពួកហ្នឹងបានរស់ទៅ ពួកហ្នឹងបានជួយៗចូលរួមចំណែកកសាងប្រទេសសព្វថ្ងៃហ្នឹងទៅ ឃើញទេ! ហើយព្រោះខ្ញុំស្គាល់ទាំងអស់។ ហើយដូចថាលោកចៅក្រមចង់ដឹងគេថា ខ្ញុំយ៉ាងម៉េចដែរ គេថាអ៊ីចេះ គេថា "អញមិនរវល់ទេ ក្រហម, ស, ខៀវ អញមិនរវល់ អញគិតថា បើថាអញរៀនវិស្វកម្មខាងផ្លូវថ្នល់ ខាងសង់ស្ពាន ខាងកសិកម្ម អញគិតតែរៀនហ្នឹងឲ្យចេះ ចេះទៅរបបណាក៏យកអញធ្វើការដែរ។

[១០:០៦:៥១]

ហើយពេលហ្នឹង គឺថាទស្សនៈរបស់យើងអត់ទេ ឮតែអ៊ីចឹងអូ! អត់បានទេ គឺថាទស្សនៈរបស់យើងគឺថា ទី១ គឺក្រហម, ទី២ គឺជំនាញការ រ៉ូល អ៊ិចស្ពែរ។ ណេះ ឈ្លោះគ្នាមើលមុខគ្នាមិនត្រង់ទេ។ ប៉ុន្តែខ្ញុំសូមជម្រាបលោកចៅក្រម ព្រោះរឿងហ្នឹងរឿងផ្ទាល់ខ្លួន ប៉ុន្តែអស់លោកចងចាំ។ ខ្ញុំរស់រាននេះមានជីវិតដែលរះរបេះដូងនេះ ដោយសារនរណាទេលោកចៅក្រម? លោកចៅក្រមស្គាល់ហើយឌុកទ័រ គីម វឿន លោកចៅក្រមស្គាល់ហើយ។ លោកឌុកទ័រ គីម វឿន គាត់រស់នៅវៀតណាមខាងត្បូង ដូចដែលលោក អៀង សារី។ ហើយខ្ញុំហើយគាត់ហ្នឹងអត់ត្រូវគ្នាទេ ព្រោះគាត់ខាងលោក លន់ នល់។ ក្រោយមកអីអ៊ីចឹង អត់ត្រូវគ្នាទេ។ ក៏ប៉ុន្តែពេលដែលខ្ញុំអស់សង្ឃឹមនៅម៉ាឡៃ ព្រោះពេទ្យគេថាឲ្យខ្ញុំទៅវះនៅបាងកក ស្រាប់តែថ្ងៃមួយគាត់ទូរស័ព្ទមកខ្ញុំ។ ខ្ញុំនៅម៉ាឡៃហ្នឹង ល្ងាចហើយគាត់ថា យើងទាំងពីរនរណាបង? គាត់នៅប៉ារីសនោះទេ។ ប៉ុន្តែខ្ញុំមិនដឹងថាគាត់អញ្ជើញមកកន្លែងនេះទេ--

[១០:០៨:០៨]

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** --មកភ្នំពេញទេបាទ។ ខ្ញុំចង់ឲ្យលោក -- ខ្ញុំសុំលោកប្រធាន ខ្ញុំចង់ឲ្យដឹងថា គឺថា អ្នកដែលសង្គ្រោះខ្ញុំបេះដូងខ្ញុំមិនមែនជាខ្មែរក្រហមទេ។ អ្នកដែលពេល -- អ្នកពេលនោះដែលជា -- បើថាយើងនិយាយនេះហៅថា "សត្រូវនយោបាយ" ដូច្នោះវាហេតុអ្វី? ហើយអ្នកដែលធ្វើការទាក់ទងឲ្យខ្ញុំដឹងនោះគឺថាជាមិត្តភក្តិខ្ញុំម្នាក់ គឺជាបារាំង។ ដូច្នោះឃើញទេ! លោកចៅក្រមក៏ជាបារាំងដែរ ហើយអ្នកដែលសង្គ្រោះខ្ញុំវាអ៊ីចឹង។ ដូច្នោះមិនមែនជាអ្នកណាដូចថាខ្ញុំធ្លាប់រួមជីវិត ខ្ញុំអត់ទោស ខ្ញុំមិនចង់និយាយបើក

កកាយ ប៉ុន្តែឲ្យយល់។ យល់ថាខ្មែរយើងដែលសព្វថ្ងៃ ដែលយើងរស់នៅសព្វថ្ងៃហ្នឹងដោយសារយើងអ៊ីចឹង។ គឺថាសរសៃរញ្ញាក់របស់យើង គឺថាឲ្យជាខ្មែរ យើងគឺត្រូវគិតថាយើងជាខ្មែរ។ ដែលការដែលខ្មែរក្រហមធ្វើខុស ហើយជាពិសេស ប៉ុល ពត គាត់ធ្វើខុស គឺថាខ្មែរ ហើយនិងក្រហម។ មានពីរពាក្យអ៊ីចឹង គឺថាយើងយកអាណាធំ? យើងយកខ្មែរធំសិន អាក្រហមដើម្បីផ្គុំផ្សំជាមួយខ្មែរទេ។ ណេះត្រូវគិតត្រូវយើង ខ្មែរយើងត្រូវចាំអាហ្នឹងឲ្យច្បាស់ ហើយឆ្លងកាត់ប្រវត្តិសាស្ត្រ ខ្ញុំសុំគឺថា ខ្ញុំមិនដឹងជាចេញពីពេលហ្នឹងទៅខ្ញុំរស់នៅបានប៉ុន្មានទេ។ ហើយការដែលសរសេរសៀវភៅ ការដែលខ្ញុំធ្វើ--

[១០:០៩:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ បានហើយសាក្សី។ យើងសូមរំឭកម្តងទៀត សូមសាក្សីរៀបចំនូវការស្តាប់នូវសំណួរឲ្យបាន ហើយឆ្លើយតបកម្រិតនឹងការតាំងសំណួរបានហើយ។ កាលណា លោកអត្ថាធិប្បាយចាកចេញពីវិសាលភាពនៃគោលបំណងនៃការតាំងសំណួរនីមួយៗចំពោះលោកនោះ អ្នកដែលលំបាក គឺនឹងប្រឈមខ្លាំង គឺលោកទេ ដែលនឹងប្រឈមនឹងតាំងសំណួរជាច្រើនទៀត។ ឥឡូវមិនទាន់ចប់ ទើបចប់ភាគីមួយទេ ហើយនៅភាគីមួយទៀត។ ឥឡូវគ្រាន់តែអង្គជំនុំជម្រះមិនទាន់ចប់ផង។

ទីពីរ គឺអង្គជំនុំជម្រះប្រើពេលវេលាឲ្យមានប្រសិទ្ធភាព អ្វីដែលចាកចេញពីសំណួរ គឺជាលទ្ធភាពដែលអង្គជំនុំជម្រះនឹងមិនអាចយកមកពិចារណាធ្វើជាភស្តុតាងនៅក្នុងដំណើរការសវនាការនេះបានទេ។ បានន័យថា ការផ្តល់ហ្នឹងវាមិនៗរួមវិភាគទានអ្វីនៅក្នុងការស្វែងរកការពិតទេ។ វាជាទស្សនៈផ្ទាល់ខ្លួនជាការយល់ដឹងផ្ទាល់ខ្លួន វាខុសពីគោលបំណងនៃការសួរដេញដោលតាមផ្លូវតុលាការ ភាគីនីមួយៗសុទ្ធតែប្រឹងដើម្បីបង្ហាញនូវគោលបំណងរបស់ខ្លួនទៅតាមមុខងារភារកិច្ចខ្លួនចូល -- ខ្លួនគាត់ចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការ។ លើកលែងតែអង្គជំនុំជម្រះទេ ដែលមានភារកិច្ចទាំងសងខាង ទាំងភស្តុតាងដាក់បន្ទុក ទាំងភស្តុតាងដោះបន្ទុក ដើម្បីស្វែងរកការពិត។

ដូច្នេះ សូមលោកកំហិតនៃចម្លើយរបស់លោកត្រឹមវិសាលភាព ឬក៏សារៈចាំបាច់នៅក្នុងការឆ្លើយតបទៅនឹងសំណួរដែលសួរបានហើយ។

[១០:១១:៥៣]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ លោកសាក្សី ខ្ញុំមានសំណួរមួយចំនួនទៀត ចោទទៅលោក សូមឲ្យលោកឆ្លើយដោយ

សង្ខេបបំផុត ហើយនិងដោយផ្ទាល់បំផុត។ បើតាមលោក តើមានប្រជាជនប៉ុន្មាននាក់ដែលរស់នៅភ្នំពេញនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** តាម គឺថាមិនមានឯកសារណាប្រាប់ខ្ញុំទេ គឺតាមដែលឮតៗគ្នាអីហ្នឹង មានប្រហែល ២០.០០០នាក់បាទ។

**ស៖** ខ្ញុំគិតថា ប្រហែលជាមានបញ្ហាបកប្រែហើយ ព្រោះថា តួលេខ ២លាននាក់នេះ គឺជាចំនួនប្រជាជនដែល -- ពេលដែលភ្នំពេញរំដោះបែក។ អ្វីដែលខ្ញុំចង់ដឹងនោះ គឺថាចំនួនប្រជាជននៅភ្នំពេញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីពេលពួកខ្មែរក្រហមដណ្តើមបានទីក្រុងភ្នំពេញ រំដោះបានទីក្រុងភ្នំពេញ។

**ប្រធានអង្គជំនុំ៖**

នេះមានបញ្ហាបកប្រែភាសាទេ សាក្សីបានឆ្លើយច្បាស់លាស់ណាស់ថា ប្រហែល ២០.០០០នាក់។ អ៊ីចឹងអ្នកបកប្រែបកប្រែជាភាសាអង់គ្លេស និងភាសាបារាំងឲ្យត្រឹមត្រូវ ២០.០០០នាក់ និង ២លាននាក់ ខុសគ្នាឆ្ងាយណាស់។

សាក្សីមិនបាច់ឆ្លើយទៀតទេ។ គឺសាក្សីឆ្លើយច្បាស់ហើយជាភាសាខ្មែរ គឺ២០.០០០នាក់ ប្រហែល ២០.០០០នាក់។

[១០:១៣:៣១]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី តើលោកអាចនិយាយឲ្យបានច្រើនជាងនេះបន្តិចទាក់ទងនឹងបរិយាកាសដែលមាននៅក្រសួងការបរទេស នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ? លោកបាននិយាយច្រើនមកហើយអំពីអ្នកដែលបាត់ខ្លួន ហើយនិងចាប់ខ្លួន តើលោកមានដឹងអំពីករណីរបស់អ្នកដែលធ្វើអត្តឃាតខ្លួនឯងដែរឬទេ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** តាមខ្ញុំចាំ មានករណីមួយដែលគេប្រាប់ថា ធ្វើអត្តឃាត អ្នកហ្នឹងក៏គាត់ជា ដូចជាជនជាតិ

ចារ៉ាយអ្អេ! ហ្នឹងបាទ គាត់ជាប្រធានមន្ទីរ គាត់ជិតស្និទ្ធរបស់លោក កុយ ធួន ប្រធានភូមិភាគឧត្តរ ហើយលោក កុយ ធួន បាន -- គាត់បានត្រូវកម្ទេចចោលហើយ។ ហើយខ្ញុំមិនចាំឈ្មោះគាត់ទេបាទ ប៉ុន្តែខ្ញុំ -- ហើយគាត់បានមកធ្វើការនៅក្រសួងការបរទេស ពេលនុ៎ងគឺក៏ខ្ញុំមិនដឹងថា គាត់ធ្វើអីដែរបាទ។ ប៉ុន្តែខ្ញុំគ្រាន់តែបានចូលរួមប្រជុំ អាហ្នឹងខ្ញុំចាំច្បាស់។ ចូលរួមប្រជុំ អ្នកទទួលខុសត្រូវបក្សមិនមែនប្រជុំបក្ខជននៅក្រសួងការបរទេសទាំងអស់ទេ។ ខ្ញុំចាំច្បាស់ថា អ្នកដែលបានចូលរួមប្រជុំ ខ្ញុំចាំអ្នកបីនាក់ ខ្ញុំចាំច្បាស់ គឺថាទី១ លោក អៀង សារី, ទី២ លោក សួរ ហុង, ទី៣ លោក ភី ភួន។ ហើយអាច គឺថាអ្នកស្រី សួរ សែ ដែរ ព្រោះគាត់ជាលេខាបាទ អាច។ ហើយពេលនោះឈ្មោះនោះត្រូវបានទិតៀនយ៉ាងខ្លាំង ដោយសារគាត់ជិតស្និទ្ធជាមួយលោក កុយ ធួន ដែលគេកម្ទេចហើយ។

[១០:១៥:៥៦]

អ្នកដែលទិតៀនខ្លាំងហ្នឹង មិនមែនខ្ញុំ ឬក៏លោក អៀង សារី ព្រោះខ្ញុំអត់ស្គាល់ គឺថាពួកម៉ាកគាត់ហ្នឹង គឺថាអ្នកដែលជិតស្និទ្ធ ខ្ញុំមិនបានដឹងថាអ្នកណាទិតៀនខ្លាំង ព្រោះ -- ប៉ុន្តែដូចថាអ្នកសុំឱ្យគាត់ដូចថាធ្វើស្វ័យទិតៀនឱ្យបានច្បាស់លាស់ ហើយគាត់មិនបានឆ្លើយតប ឬនិយាយអ្វីទេ។ ហើយដល់ក្រោយមកគេបានប្រាប់ថា គាត់ធ្វើអត្តឃាតហើយបាទ គាត់ -- ហើយការដែលគេប្រាប់ខ្ញុំនេះអាចសមស្របដែរ។ ពីព្រោះគាត់ជាជាតិភាគតិច ជាជនជាតិចារ៉ាយ សុទ្ធតែអ្នក គឺចិត្ត។ ចិត្តខ្លាំងណាស់ដូចថាគេទិតៀននេះល្មមនេះដែរ បើទិតៀនតាមដែលខ្ញុំបានឮហ្នឹង ខ្លួនខ្ញុំផ្ទាល់ហ្នឹងក៏អាចមានប្រតិកម្មដូចនេះដែរ។ ព្រោះអ្នកដែលយើងស្រឡាញ់ យើងរាប់អាន យើងធ្លាប់រស់នៅជាមួយគ្នា ដូចថាយើង -- គេបដិសេធមកយើង យើងរស់នៅធ្វើអីទៀតបាទ។ មានករណីតែមួយគត់ ដែលបានខ្ញុំដឹង។ ករណីឯទៀតខ្ញុំមិនបានដឹងទេបាទ។

[១០:១៧:២៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឱ្យមានការបំភ្លឺ យើងបានស្តាប់ភាសាអង់គ្លេស គឺថា២០០ពាន់ អ្វីដែលខ្ញុំយល់ គឺថាសាក្សីនិយាយថាតែ២០.០០០ទេ បាទ មិនមែន២០០.០០០ ទេ បាទ។ នេះសំណួរពីមុនសំណួរនេះ យើងឮថាដំបូងថា២លាន ក្រោយមកកែថាឃើញថា ២០០ពាន់ ដែលមានន័យ

ថា២០០.០០០ ហើយលោកប្រធានបានកែថា ប្រហែលជា២០.០០០។ ហើយថាភាសាខ្មែរឮច្បាស់ថា គឺ២០ពាន់ បានន័យថា ២០.០០០។ ដូច្នេះ សូមឲ្យមានការបំភ្លឺដើម្បីកំណត់ត្រាតុលាការឲ្យត្រឹមត្រូវ។ ដូចថា បើមិនដូច្នោះទេ គឺហាក់ដូចជាសាក្សីគាត់ឆ្លើយមិនច្បាស់បាទ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោកសាក្សី បាទដើម្បីបំភ្លឺទាក់ទងទៅនឹងចំណុចនេះ ពីព្រោះខាងភាសាបារាំង យើងមិនបានឮថាប្រជាជននោះ វាមាន២០.០០០នាក់ទេ។ តើលោកអាចបញ្ជាក់ពីចំនួនមនុស្ស ដែលរស់នៅទីក្រុងភ្នំពេញក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

[១០:១៨:៥១]

**លោក សួង ស៊ីគឿន៖**

**ឆ៖** បាទ ខ្ញុំបានជម្រាបថា ប្រហែល២០.០០០នាក់ ហើយយើងខ្ញុំសូម -- សូមបន្ថែមថា មិនមែនជាប្រជាជនធម្មតាទេនេះ គឺសុទ្ធតែជាដូចថាបុគ្គលិកក្រសួង កងទ័ពអីអ៊ីចឹងបាទ។ សុទ្ធតែអ្នក ដូចថារាជការយើង យើងថាអ្នករាជការចុះបាទ។

**ស៖** ទាក់ទងនឹងចំនួនអ្នកដែលរស់នៅទីក្រុងភ្នំពេញ តើលោកដឹងថាអាជ្ញាធរកម្ពុជាប្រជាធិប-តេយ្យបានធ្វើការជំរឿនដែរឬទេ? តើគេមានបានសូមឲ្យភូមិភាគ ឬក៏សហករណ៍សួរឲ្យដឹងជំរឿន ដើម្បីឲ្យដឹងចំនួនប្រជាជននៅតាមតំបន់របស់ខ្លួនដែរឬទេ?

**ឆ៖** មិនមានធ្វើជំរឿនដូចគេធ្លាប់បានធ្វើទេ ប៉ុន្តែជំរឿនហ្នឹងគឺថាតាមរយៈសរសេរប្រវត្តិរូបម្នាក់ៗត្រូវបំពេញប្រវត្តិរូបបាទ។

[១០:២០:២៤]

**ស៖** ប្រធានបទថ្មីមួយទៀត លោកសាក្សី នៅពេលដែលលោកធ្វើការនៅក្រសួងការបរទេស តើគេមានបានប្រាប់លោកអំពីអ្វី ដែលថាប្រទេសបរទេសមួយចំនួន ឬក៏ស្ថាប័នអន្តរជាតិមួយចំនួន ប្រហែលជាបានផ្តល់ដល់អ្នកតំណាងឲ្យកម្ពុជាប្រជាធិបតេយ្យជាជំនួយហិរញ្ញវត្ថុ ឬក៏ស្បៀងអាហារ ដើម្បីជួយដល់ប្រជាជនកម្ពុជា តើលោក -- មានគេប្រាប់លោកដែរឬទេ អំពីជំនួយទាំងអស់នេះ?

**ឆ៖** ខ្ញុំអាច -- ខ្ញុំអាចជម្រាបថា នៅឆ្នាំ ដូចនៅឆ្នាំ១៩៧៥ គឺអង្គការផលិតប្រេងកាត អូប៉ិច គាត់បានសុំជួយកម្ពុជាប្រជាធិបតេយ្យលុយប្រាំលានដុល្លារអាមេរិក ជួយៗគ្មាន -- អត់មានចំណងអីទេ។ ហើយខ្ញុំចាំមិនច្បាស់ទេ ខាងក្រសួងការបរទេស ពិសេសលោក អៀង សារី គាត់ថា បើជំនួយ

អូប៉ិចហ្នឹងវាមាន -- អត់មានអី នយោបាយអី -- អើប្រទេសអូប៉ិចដឹងស្រាប់ ប្រទេសផលិតប្រេងច្រើន នៅមជ្ឈិមបូព៌ាណ៎ះ ដូច្នោះគេជួយហ្នឹងដូចជាគ្មានចំណងអីទេ។ អាចទទួលយកបានតើ! ក៏ប៉ុន្តែកាលនោះ គឺកម្ពុជាប្រជាធិបតេយ្យមិនបានទទួលទេ។ តាមដែលខ្ញុំដឹងមានៗករណីមួយដែលច្បាស់ ចំពោះករណីឯទៀតខ្ញុំមិនបានដឹងទេបាទ។

[១០:២២:១៦]

**ស៖** ហើយជំនួយនោះត្រូវបានទទួលដែរឬទេ -- យល់ព្រមទទួលទេ?

**ឆ៖** បាទ ខ្ញុំបានជម្រាបហើយថា អត់យល់ព្រមទេបាទ។ ប៉ុល ពត គាត់មិនទទួលទេបាទ មិនទទួលយកទេ។

**ស៖** លោកសាក្សី តើលោកដឹងដែរឬទេ ថានៅក្នុងរយៈកាលនេះ អង្គការការពារសិទ្ធិមនុស្ស ដូចជា អាំណេស្ទី អ៊ីនធឺណាស្យូណាល់ ត្រូវមកទាក់ទងជាមួយអ្នកទំនួលខុសត្រូវនយោបាយ នៃរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេ ព្រោះអាច -- បើទាក់ទងអាចតាមតំណាងនៅប៉ារីស ឬនៅញូវយ៉ក ឬនៅកន្លែងណាទៀត ប៉ុន្តែ -- បើសិនជាគេទាក់ទងមែន ក៏ខ្ញុំមិនបានដឹងបញ្ហាទាំងនេះទេ ព្រោះមិនមែននៅក្នុងក្របខ័ណ្ឌភារកិច្ចរបស់ខ្ញុំបាទ។

**ស៖** នៅក្នុងក្របខ័ណ្ឌនៃទំនួលខុសរបស់ -- ទំនួលខុសត្រូវរបស់លោក តើលោកមានទំនាក់ទំនងជាមួយការិយាល័យ៧៧០ (ស៊ីក) ដែរឬទេ? ហើយៗបើសិនជាលោកមានទំនាក់ទំនងជាមួយមន្ទីរ ៨៧០នេះ តើអ្នកណាជាអ្នកដែលលោកទាក់ទង?

[១០:២៣:៥៧]

**ឆ៖** មិនមានការទាក់ទងទេ ព្រោះវាផ្នែកពីរខុសគ្នាបាទ។ មួយផ្នែកបក្ស មួយផ្នែករដ្ឋបាលបាទ។

**ស៖** លោកមិនដែលធ្លាប់ផ្ញើឯកសារទៅមន្ទីរ៨៧០នេះទេឬ? លោកមិនដែលផ្ញើអត្ថបទទៅមន្ទីរ ៧៧០ (ស៊ីក) -- លោកមិនដែលធ្លាប់ផ្ញើឯកសារបកប្រែទៅមន្ទីរ ៨៧០ អ៊ីចឹងមែនទេ?

**ឆ៖** ឯកសារអាចគេផ្ញើទៅមន្ទីរ៨៧០ ពីខាងផ្នែកដែលខ្ញុំទទួលខុសត្រូវ អាហ្នឹងអាចមាន។ ប៉ុន្តែមិនមែនខ្ញុំផ្ញើផ្ទាល់ទេ គឺខាងអ្នកទទួលខុសត្រូវខ្ញុំផ្ញើបាទ។ ខ្ញុំផ្ញើតាមខ្សែរយៈមិនមែនផ្ញើត្រង់ទេបាទ។

**ស៖** ហើយលោក លោកសាក្សី តើលោកប្រគល់ការងាររបស់លោកទៅអ្នកណា? អ្នកណាជា

មេរបស់លោក?

**ឆ៖** មេរបស់ខ្ញុំគឺលោក អៀង សារី បាទ។

**ស៖** ដូច្នេះ ការងារដែលលោកធ្វើទាំងប៉ុន្មាននោះ ត្រូវតែបញ្ជូនឲ្យលោក អៀង សារី តើអីចឹងមែនទេ ហើយមិនបញ្ជូនឲ្យអ្នកផ្សេងទៀតទេ? អីចឹងមែនទេ?

**ឆ៖** នេះវាអាស្រ័យតាមការងារជាក់ស្តែងនីមួយៗ ការងារខ្លះគឺ ប៉ុល ពត គាត់គឺថា មិន -- ដំណើរការត្រង់មកកន្លែងខ្ញុំក៏មាន គឺថា ដូច្នោះមិនមានស្អីដែលខ្ញុំធ្វើហ្នឹងវា ឡើងទៅដល់លោក អៀង សារី ទាំងអស់ទេបាទ។

**ស៖** តើលោកបញ្ជូនឯកសារទៅ ប៉ុល ពត តាមរបៀបណាទៅ?

**ឆ៖** គឺមានតាមផ្នែកលេខាធិការដ្ឋាន។ លេខាធិការដ្ឋានហ្នឹង--*សិក្រេទែរីយ៉ា*-- បាទ គឺថាមានលោកស្រី សួរ សែ គាត់ធ្វើជាប្រធាន ហើយគាត់ជាលេខាបក្ស នៅផ្នែកការិយាល័យ នៃក្រសួងការបរទេសបាទ។

**ស៖** នៅក្របខ័ណ្ឌ នៃការងាររបស់លោក នៅក្នុងក្រសួងព័ត៌មាន និងឃោសនាការ នៃក្រសួងការបរទេស តើលោកទទួលបន្ទុកក្នុងការធ្វើទស្សនាវដ្តី ឬក៏វិភាគសារព័ត៌មានបរទេសដែរឬទេ? ហើយជាពិសេស គឺសារព័ត៌មានបរទេស ដែលមានអត្ថបទទាក់ទងទៅនឹងកម្ពុជាប្រជាធិបតេយ្យ ឬក៏អ្នកមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ?

[១០:២៧:៣៨]

**ឆ៖** មានទស្សនាវដ្តីមួយ ខ្ញុំមិនចាំឈ្មោះ ប៉ុន្តែទស្សនាវដ្តីរូបភាព ជារូបភាពគឺថា ជារូបភាពហើយជាពណ៌ ក៏ប៉ុន្តែមិនមែនផ្នែកខ្ញុំធ្វើទេបាទ គឺអ្នកផ្នែកផ្សេងធ្វើទេ អាចមានកម្មាភិបាលក្រសួងការបរទេសចូលរួម ក៏ប៉ុន្តែមិនមែនខាងផ្នែកខ្ញុំទេបាទ។

**ស៖** បើតាមលោក លោកសាក្សី នៅពេលដែល អៀង សារី ត្រូវបានសម្ភាសនៅបរទេស គាត់សុំឲ្យផ្នែកការងាររបស់ខ្លួន ដើម្បីផ្ទៀងផ្ទាត់ ហើយនិងរកអ្វីដែលត្រូវបានសម្ភាស ហើយតើ -- ដើម្បីយកទៅបោះពុម្ពផ្សាយ អីចឹងមែនទេ?

**ឆ៖** មិនមានទេបាទ។ ដូចគាត់សម្ភាសជាមួយកាសែតអី មិនមានអត្ថបទដែលគាត់សម្ភាសហ្នឹង មកបោះពុម្ពផ្សាយក្នុងប្រទេសទេបាទ។ ហើយជាពិសេស បើបោះពុម្ពផ្សាយ បោះពុម្ពផ្សាយនៅកន្លែងផ្សេង បើកន្លែងខ្ញុំមិនដែលបោះពុម្ពផ្សាយសម្ភាសរបស់គាត់ទេ។

[១០:២៩:១១]

**ស៖** លោកមិនយល់សំណួរខ្ញុំច្បាស់ទេ។ សំណួរខ្ញុំដូចតទៅនេះ នៅពេលដែលលោក អៀង សារី ត្រូវសម្ភាសដោយអ្នកកាសែតនៅបរទេស ហើយសម្ភាសន៍នេះ ត្រូវបានបោះពុម្ពនៅក្នុងកាសែតនៅបរទេស តើលោក អៀង សារី សុំឲ្យការិយាល័យរបស់ខ្លួននោះ ផ្ទៀងផ្ទាត់ ឬក៏យកខ្លឹមសារនៃអត្ថបទបោះពុម្ពផ្សាយនេះ ផ្ទៀងផ្ទាត់ថាត្រឹមត្រូវ ឬក៏អត់។ តើលោក អៀង សារី ធ្លាប់បានសុំឲ្យបុគ្គលិករបស់ខ្លួនធ្វើយ៉ាងដូច្នេះទេ?

**ឆ៖** ខ្ញុំបានជម្រាបហើយថា មិនមានធ្វើតាមរយៈផ្នែករបស់ខ្ញុំទេបាទ ព្រោះសម្ភាសដែលគាត់ធ្វើនៅបរទេស យើងខ្ញុំដឹងក្រោយពីកាសែតនោះ បានចេញផ្សាយទៅហើយបាទ ហើយដឹងតាមទីភ្នាក់ងារព័ត៌មានបរទេសទៀតបាទ។

**ស៖** ឧទាហរណ៍ដូចជា អត្ថបទកាសែត ដែលត្រូវបានបោះផ្សាយនៅ -- កាសែត អាស្ត្រីងហ្គ៌ នៅអាល្លឺម៉ាញ, អ៊ិចប្រេសសូ នៅអ៊ីតាលីអីជាដើមនោះ តើនេះអត្ថបទ ដែលលោកៗបានគេបានប្រាប់អំពីអត្ថបទនេះ ដល់លោកដែរឬទេ?

**ឆ៖** បាទ មិនបានប្រាប់ទេបាទ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណ លោកសាក្សី ដែលបាន ដែលអត់ធ្មត់នេះ។ ហើយខ្ញុំឥឡូវនេះ អស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែង សម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងដែលបានកំណត់អម្បាញ់មិញនេះ គឺម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣១ នាទី ដល់ម៉ោង ១០:៥៣ នាទី)*

[១០:៥៣:២៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ សូមគោរពអង្គសវនាការ។

ហើយសូមជម្រាបសួរលោក ស្លុង ស៊ីគឿន ដែលមានវត្តមាននៅទីនេះផងដែរ។ ហើយសូមថ្លែងអំណរគុណចំពោះលោកដែលបានអញ្ជើញមកឆ្លើយនូវសំណួរទាំងឡាយរបស់ភាគី រួមទាំងអង្គសវនាការនាពេលនេះ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំបាទមេធាវី គង់ សំអុន ជាមេធាវីការពារជាតិរបស់លោក ខៀវ សំផន មានសំណួរមួយចំនួនចំពោះលោក ហើយសូមលោកជួយសហការឆ្លើយទៅតាមលទ្ធភាពដែលលោកបានដឹងដូចតទៅ៖

សំណួរដំបូងខ្ញុំសូមឲ្យលោកជួយពន្យល់អំពីសមាសភាពរបស់រណសិរ្សរួបរួមជាតិ ដែលហៅកាត់ថា “ហ្វុង” ហើយលោក -- ខ្ញុំបានឃើញឈ្មោះរបស់លោកជាសមាជិកនៅក្នុង “ហ្គ្រុង” ដែលហៅថា “រាជរដ្ឋាភិបាលរួបរួមជាតិ” នោះដែរ។ ហើយខ្ញុំចង់ឲ្យលោកជួយបញ្ជាក់ថា តើសមាជិកទាំងអស់ដែលមាននៅក្នុង ហ្វុង ឬក៏ហ្គ្រុង នេះ មានការបែងចែកជាក្រុមតូចៗទៀត ពីនិន្នាការនយោបាយខុសគ្នាដែរឬទេ?

[១០:៥៦:០១]

**លោក ស្លុង ស៊ីគឿន៖**

**ឆ៖** ក្នុងហ្វុង និង ហ្គ្រុងនេះ មានអង្គការចាត់តាំងរបស់ហ្វុងនិងហ្គ្រុងហ្នឹងផ្ទាល់។ ហើយចំពោះហ្វុងគឺជាអង្គការនយោបាយ មានគណៈកម្មាធិការកណ្តាល។ នៅពីលើគណៈកម្មាធិការកណ្តាល

ហ្នឹងគឺថាមានការិយាល័យនយោបាយនៃគណៈកម្មាធិការកណ្តាល ដែលមានសម្តេចចៅហ្វាវាំង ប៉ែន នុត ហ្នឹងជាប្រធាន។ ហើយនៅក្នុងប្រទេសនីមួយៗមានគណៈកម្មាធិការរបស់ហ្នុងនេះ។ នេះជាការចាត់តាំងរបស់ហ្នុង។ ហើយសមាសភាពជានយោបាយដែលចូលរួមហ្នុងហ្នឹង គឺថា ទូលំទូលាយណាស់ គឺបើយើងនិយាយពីនិន្នាការនយោបាយ គឺមានសម្តេចព្រះ នរោត្តម សីហនុ លោកជាប្រធាន ហើយក៏យើងអាចថាជាអ្នកសីហនុនិយម ដែលក្រោយមកបែកចេញជា នៅក្នុងហ៊្វុនស៊ិនប៉ិច នោះបាទ។

[១០:៥៧:៣៣]

ក្នុងនេះគឺថា បើនៅខាងក្រៅ ហើយខ្ញុំក៏នៅខាងក្នុងដែរ។ បើនៅខាងក្រៅជាសមាសភាពដែលមានសមាជិក ហើយនិងមានដូចថាឥទ្ធិពលទូលំទូលាយជាងគេ។ ហើយបន្ទាប់មក គឺថាមានក្រុមដូចថាក្រុមខាងយើងៗនិយាយថាក្រុមខាងឆ្វេងចុះ។ ក្រុមខាងឆ្វេងហ្នឹងក៏សមាសភាពក៏ទូលាយដែរ។ ក្រុមខាងឆ្វេងគឺមិនមែនជាខាងក្រហម។ ក្រុមនេះទូលាយដែរ ហើយមានដូចជាឥស្សរជនដូចជាលោក ចៅ សេង ជាដើម។ គាត់គឺថា ធ្លាប់ជានាយកខុទ្ទកាល័យរបស់សម្តេចនរោត្តម សីហនុ ព្រះប្រមុខរដ្ឋ ហើយគាត់ជាសមាជិកការិយាល័យនយោបាយរណសិរ្ស ហើយនិងជារដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការងារបេសកកម្មពិសេស។ បន្ទាប់មកមានពួកគេហៅថា យើងហៅថា ពួកក្រហម ពួកនេះ ក្រោយមកគេហៅថា “ខ្មែរក្រហម” ហ្នឹងគឺថាពួក ជាពិសេសគឺពួកនេះ មានលោក អៀង សារី, មានលោក ខៀវ សំផន, លោក ហ៊ូ យន់, លោក ហ៊ូ នឹម អីជាដើម។ លោក ជួន ម៉ុំ អីបាទ។ លោក គាត ឈន់ អីហ្នឹង។

[១០:៥៩:២៦]

មានសមាសភាពមួយក្រុមទៀតជាអ្នកតស៊ូចាស់។ ក្រោយពីកិច្ចព្រមព្រៀងហ្សឺណែវ ឆ្នាំ១៩៥៤ អ្នកទាំងហ្នឹងបានត្រូវជម្លៀសទៅនៅវៀតណាមខាងជើង។ ក្រុមនេះគឺថាមានលោក កែវ មាស, លោក ជា សុត អីហ្នឹងបាទ។ ដូច្នោះមានសមាសភាពគឺថា ទូលាយដែរ អានេះដែលៗខ្ញុំក្តាប់បានប៉ុណ្ណឹងបាទ។ ប៉ុន្តែមិនមានបែងចែកជាការចាត់តាំងអីទេបាទ។ ហ្នឹងសូមជម្រាបប៉ុណ្ណេះបាទ។

**ស៖** បាទ សូមអរគុណ។ នៅពេលដែលលោកឆ្លើយជាមួយនឹងតំណាងសហព្រះរាជអាជ្ញា អំពីអ្នកសីហនុនិយម និងឈ្មោះមួយចំនួនក៏ដូចជាអម្បាញ់មិញដែលលោកបានលើកពីពាក្យ “សីហនុនិយម” នេះ តើមានមូលដ្ឋានអ្វីដែលបញ្ជាក់អំពីនិន្នាការសីហនុនិយម នេះដែរឬទេ?

**ឆ៖** ពាក្យថា “សីហនុនិយម” ហ្នឹងគឺដែលខ្ញុំនិយាយនេះ គឺវាមានដូចថា និយមន័យមិនទូលាយអីប៉ុន្មានទេ គឺថាជាឥស្សរជនដែលធ្លាប់បម្រើការ ដែលធ្លាប់ជាសមាជិកសង្គមរាស្ត្រនិយម ហើយដែល

ធ្លាប់បម្រើនៅក្នុងរដ្ឋបាល នៅក្នុងការគ្រប់គ្រងរបស់សម្តេចព្រះ នរោត្តម សីហនុ គឺដូចយើងមានដូចជា លោក ហួត សម្បត្តិ, លោក ជា សាន, លោក កែវ មាស ដែលជា អ៊ំ!មិនមែន កែវ មាស ទេ លោក កែ មាស ដែលជាឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំប្រទេសចិន លោក ពុង ប៉េងចេង។ លោក ពុង ប៉េងចេង ជានាយក អតីតនាយកខុទ្ទកាល័យរបស់ព្រះអង្គ របស់សម្តេចព្រះ នរោត្តម សីហនុ ហើយលោកជាឪពុករបស់លោកស្រី ពុង ឈីវហ្គេច សព្វថ្ងៃនេះបាទ។ ហ្នឹងមានដូចថា គេហៅថា ទូលាយដែរ ហើយមានឥស្សរជនមួយចំនួន ក៏អាចថា ជាអ្នកដូចថា នៅក្នុងរង្វង់ហ្នឹងដែរ ប៉ុនមិនមែនជាអ្នកសកម្មទេ ដូចជា លោកសេនាប្រមុខ -- អ៊ំ! លោកឧត្តមសេនីយ គង់ សំអុល, លោក អាង គឹមឃន។ លោក អាង គឹមឃន ជាអតីតឯកអគ្គរដ្ឋទូតប្រចាំកូរ៉េខាងជើង ហើយលោកជាអ្នកជំនួញមួយមានកេរ្តិ៍ឈ្មោះបោះសំឡេងដែរ នៅខាងនៅខេត្តបាត់ដំបងបាទ។

[១១:០២:៣៧]

**ស៖** បាទ សូមអរគុណ។ នេះខ្ញុំសូមបញ្ជាក់សាឡើងវិញ ពាក្យថា “សីហនុនិយម” នេះការពិតទៅមិនមែនជាអង្គការចាត់តាំងបញ្ជាក់អំពីសមាជិកភាព មានលក្ខណៈជារចនាសម្ព័ន្ធ ជាផ្លូវការអីទេ។ វាគ្រាន់តែបង្ហាញពីនិន្នាការនៅក្បែរ ឬក៏និយមសម្តេច នរោត្តម សីហនុ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អាហ្នឹងគឺអ៊ីចឹងហើយ គឺថាមិនមានអីគេចាត់តាំងទេ។ ព្រះអង្គ គឺថាជាឥទ្ធិពលព្រះអង្គផ្ទាល់ ហើយជា ដូចថា ជាការចងក្រងមួយ មិនមែនជាការចាត់តាំងទេ។ ក៏ប៉ុន្តែក្នុងហ្នឹងក៏មានដូចថា មានអ្នក ដូចយើងថា សព្វថ្ងៃយើងប្រើពាក្យថា “សកម្មជន” គឺថាសកម្ម ហើយស្មោះត្រង់ ដូចថាយើងអាចថា ១០០ភាគរយក៏បានដែរ។ ក្នុងហ្នឹងវាមានអ្នកដែលស្ទួលមួយ គឺថា សកម្ម ស្មោះត្រង់ចំពោះព្រះអង្គ ហើយអ្នកឯទៀតគឺថា វាគ្រាន់តែជា ដូចថា អ្នកកណ្តាលមិនមាននយោបាយអីច្បាស់លាស់ទេ ក៏ប៉ុន្តែគឺអាចថា គឺទទួលឥទ្ធិពល គោរព ហើយនិងស្រលាញ់ព្រះអង្គដែរបាទ។

[១១:០៤:២២]

**ស៖** បាទ សូមអរគុណ។ មុននេះបន្តិចលោកមានប្រសាសន៍អំពីអ្នកឆ្វេង លោកចង់និយាយអំពីឆ្វេងនិយម ប៉ុន្តែមិនមែនជាខ្មែរក្រហម តើលោកអាចពន្យល់បន្ថែមបន្តិចបានទេ? ថាឆ្វេងនិយមមិនមែនជាខ្មែរក្រហមនេះ ជាបុគ្គលដែលមាន -- ដែលស្ថិតនៅក្នុងលក្ខខណ្ឌដូចម្តេចដែរ?

**ឆ៖** ខ្មែរក្រហមវា -- បើនិយាយទៅ បើនៅស្រុកបារាំង ពេលដែលខ្ញុំនៅហ្នឹង គឺមានការចាត់តាំងពីរ។ មានសមាគមសហភាពនិស្សិតខ្មែរ ហ្នឹងគឺយើងអាចនិយាយថាជាអ្នកឆ្វេង ឆ្វេងនិយមហើយ

បាទ។ ក៏ប៉ុន្តែមានអង្គការស្ទូលចាត់តាំងមួយទៀត គឺថាវង់ ម៉ាក្ស-ឡេនីន ហ្នឹងពួក ជារួមគឺថា យើងអាចថាពួកៗក្រហមហើយបាទ។ គឺថាមានពួកក្រហមពេលនោះ គឺថាមានដូចថាស្រលាញ់យកគំរូដូចថាយកសហភាពសូវៀត យកចិនប្រជាមានិត យកសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមហ្នឹងជាគំរូ។ ដូចអង្គាល់ដែលខ្ញុំៗអីហ្នឹង ខ្ញុំស្តាប់វិទ្យុហ្នឹងគឺ គឺស្តាប់វិទ្យុ តែងតែស្តាប់វិទ្យុប៉េកាំង តែងតែស្តាប់សំឡេងវៀតណាម។ ឧបមាអ៊ីចឹង ខ្ញុំចង់និយាយអ៊ីចឹង។ ហើយពួកនេះ គឺដូចថាមានសមានចិត្តចំពោះកុម្មុយនីស្តដែរ ក៏ប៉ុន្តែមិនមាននៅក្នុងអង្គការចាត់តាំងទេ។

[១០:០៦:២១]

មានដូចថា នៅក្នុងប្រទេស មានលោក ស៊ូ ណែម ជាដើម, លោក ចៅ សេង ជាដើម។ ជាឥស្សរជនដែលមានឈ្មោះបោះសំឡេង។ ហើយបើឥស្សរជនខ្លះ ដូចថាលោក ចាន់ យូរ៉ាន់ ដល់ក្រោយមកយើងអាចចាត់ទុកថាគាត់នៅក្នុងជំពូកនេះដែរ ប៉ុន្តែដើមឡើយគាត់ជាខាងសីហនុនិយមទេ ហើយសព្វថ្ងៃក៏គាត់នៅតែសីហនុនិយម ក៏ប៉ុន្តែចំពោះខ្មែរក្រហម ពួកនេះ គឺថាគាត់សហការ ហើយគឺថាគាត់មានការរាប់អានជិតស្និទ្ធដែរបាទ។ នេះមួយជំពូក ដែលមានឥស្សរជនមួយចំនួនដែលស្នេហាជាតិ ហើយដែលសមត្ថភាពបាទ។

**ស៖** បាទ សូមអរគុណ។ តាមចម្លើយរបស់លោកបានបញ្ជាក់អំពីការចូលរួមរវាង នៅក្នុងៗហ្រ្គុង ឬក៏ហ្វុងហ្នឹង មានអ្នកនៅខាងក្រៅប្រទេស និងអ្នកនៅខាងក្នុង ដែលជាអ្នកតស៊ូនៅក្នុងព្រៃ។ លោកបានជម្រាបជូនអង្គសវនាការរួចហើយនៅពេលដែលលោកចៅក្រម ឡាវែន៍ សួរអំពីគោលបំណងនៃការបង្កើតហ្រ្គុងនោះ លោកបានឆ្លើយថា ក្នុងគោលបំណងដើម្បីរំដោះប្រទេសឱ្យរួចផុតពីចក្រពត្តិអាមេរិក និងអាយ៉ង ហើយមានទិសដៅមិនចូលបក្សសម្ព័ន្ធជាដើម ហើយនិងដើម្បីទុកប្រទេសឱ្យនៅជាអព្យាក្រឹតជាដើម។ ក្នុងទិសដៅនេះ ខ្ញុំចង់សួរលោកបញ្ជាក់បន្ថែមថា តើកម្លាំងទាំងពីរ ទាំងខាងក្នុងនិងខាងក្រៅនេះ មានការប្រើប្រាស់គ្នាយ៉ាងដូចម្តេចដែរ? ថាតើកម្លាំងទាំងពីរនេះស្មោះត្រង់នឹងគ្នាក្នុងការសហការគ្នាដោយត្រឹមត្រូវ ឬមួយក៏មានល្បិចកលអ្វីជាការប្រើប្រាស់ដើម្បីយកកេងចំណេញផលប្រយោជន៍រៀងខ្លួនដែរទេ?

[១១:០៨:៥៩]

**ឆ៖** ខ្ញុំឃើញថា ក្នុងការនយោបាយ ហើយគឺនៅពេលនោះ ខ្ញុំនិយាយថានៅពេលនោះ ពេលដែលសេនាប្រមុខ លន់ នល់ គាត់ធ្វើរដ្ឋប្រហារហើយ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ គឺប្រជាជនបាន

ធ្វើបាតុកម្មទូទាំងប្រទេសនៅកំពង់ចាមជាដើម នៅទីក្រុងផ្សេងទៀតជាដើម។ ក៏ប៉ុន្តែកម្លាំងទាំងនេះអត់នៅមានកម្លាំងចាត់តាំងទេ។ គឺមានតែកម្លាំងដែលពេលនោះនៅជាកម្លាំងតិចនៅឡើយ ដែលជាកងការពារពិសេសរបស់ ដែលគេហៅសព្វថ្ងៃនេះ គេថាជាបក្សកុម្មុយនីស្តកម្ពុជា ជាកម្លាំងដូចថាស្នូលដឹកនាំ ហើយនិងប្រមូលដឹកនាំចងក្រងកម្លាំងទាំងនេះ ណេះពេលនុ៎ង។ ហើយក៏យើងមិនអាចបដិសេធទេ ព្រោះនេះជាចំណុចប្រវត្តិសាស្ត្រ ក៏មានអង្គភាពកងទ័ពរំដោះរណសិរ្សវៀតណាមខាងត្បូង បើយើងនិយាយជាភាសា ដូចថាស្រួលស្តាប់ គឺថាពួកវៀតកុងក៏មានវត្តមាននៅកម្ពុជាច្រើនដែរក្នុងពេលនោះ។ ហើយកម្លាំងទាំងពីរនេះ ក៏ប្រមែប្រមូលគឺថាលើកទង់សម្តេច សីហនុ ដើម្បីកៀងគរ ប្រមែប្រមូលមហាជន ប្រជាជនចូលរួមក្នុងការតស៊ូបាទ។

[១១:១១:១៦]

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា តើហ្នុង មានកម្លាំងទ័ពរបស់ខ្លួននៅខាងក្នុងជាខ្មែរ ឬក៏ជាបរទេស? ហើយបើមានជាខ្មែរនោះ តើលោកអាចដឹងពីចំនួនពិតប្រាកដដែរឬទេ? ឬក៏ចំនួនប្រហាក់ប្រហែល?

**ឆ៖** ខ្ញុំមិនបានដឹងច្បាស់ទេ ព្រោះខ្ញុំនៅក្រៅប្រទេស។ ខ្ញុំគ្រាន់តែដឹងថា ពេលឆ្នាំ១៩៧០ មានការបះបោរកសិករនៅសំឡូត ហើយនៅឆ្នាំ១៩៦៨ គឺថាបក្សកុម្មុយនីស្តកម្ពុជាបានសម្រេចធ្វើកុបកម្មទូទៅប្រទេស ដោយដណ្តើមអាវុធពីខ្មាំង។ ក៏ប៉ុន្តែដូចថានៅ ចាប់ផ្តើមនៅបាយដំរាំ ស្អីជាដើមហ្នឹងទេ។ ក៏ប៉ុន្តែកម្លាំងនេះ កម្លាំងប្រដាប់អាវុធនេះមានចំនួនតូចទេ ក្នុងការចងក្រងធ្វើជាកម្លាំងទ័ពរបស់រណសិរ្សហ្នឹង មួយផ្នែកធំក៏ត្រូវបានកងទ័ពរំដោះវៀតណាម ដែលគេហៅថាវៀតកុង នៅក្នុងកម្ពុជាហ្នឹងបានៗប្រមែប្រមូលចាត់តាំង ហើយគ្រប់គ្រងកម្លាំងប្រដាប់អាវុធ ដែលក្នុងនាមសម្តេចព្រះនរោត្តម សីហនុ។

[១១:១៣:១៤]

**ស៖** បាទ សូមអរគុណ។ ឥឡូវ ខ្ញុំសូមសួរលោកទាក់ទងទៅនឹងបក្សកុម្មុយនីស្តកម្ពុជាវិញម្តង លោកបានឆ្លើយបញ្ជាក់ក្នុងពេលកន្លងមកថា លោកបានចូលជាបក្ខជននៅទីក្រុងប៉េកាំង ឆ្នាំ១៩៧១។ ខ្ញុំសូមសួរលោកថា តើលោកដឹងថាបក្សកុម្មុយនីស្តកម្ពុជានេះកើតឡើងនៅពេលណាដែរទេ?

**ឆ៖** ខ្ញុំមិនបានដឹងអីច្បាស់ទេ វាជំនាន់ពេលនោះ ហើយដែលខ្ញុំចូលនៅក្នុងបក្ស ចូលជាផ្លូវការជាបក្ខជនរបស់បក្សកុម្មុយនីស្តកម្ពុជានៅប៉េកាំង នៅឆ្នាំ១៩៧១នេះ គឺវាមានខ្ញុំបានឆ្លងកាត់ការត្រៀមខ្លួនជាយូរមកហើយ។ ចង់និយាយថា ដើមឡើយនៅឆ្នាំ១៩៥៥ ដើមឡើយខ្ញុំបានចូលជាសមាជិកគណបក្ស

ប្រជាធិបតេយ្យផង ក៏ប៉ុន្តែបានខ្ញុំចូលជាក្រុមប្រជាជន។ ពេលនោះបានមានលោក ណុប បូផាន់ គាត់ -- លោក ណុប បូផាន់, លោក កែ មាស។ ដូច្នោះក្រោយមក ពេលដែលលោក អៀង សារី គាត់អញ្ជើញត្រឡប់ពីប្រទេសបារាំងវិញ នៅដើមឆ្នាំ១៩៧០ -- អ៎! ៥៧ ខ្ញុំក៏បានចូលក្នុងអង្គការសម្ងាត់របស់បក្សគឺថាជាជនបង្គោល។ អាហ្នឹងជាលក្ខណៈត្រៀមដើម្បីធ្វើជាបក្ខជនហើយ។ បាទ ដូច្នោះវាមានដំណើរហូរហែដូច្នេះបាទ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេ ថាហេតុអីបានជាត្រូវមានការចូលជាត្រៀមជាលក្ខណៈសម្ងាត់ ដូចលោកមានប្រសាសន៍អម្បាញ់មិញនេះ?

**ឆ៖** ខ្ញុំសូមជម្រាបថា ពេលនោះមិនមានអង្គការ ព្រោះបក្សកុម្មុយនីស្ត ធម្មតាបក្សកុម្មុយនីស្ត ឬបក្សពលករតាមដែលគេហៅនោះគឺ ទិសដៅសំខាន់គឺធ្វើបដិវត្តន៍ ដើម្បីកសាងសង្គមនិយម ឈានទៅកុម្មុយនីស្តនិយមនៅក្នុងប្រទេសកម្ពុជា។ ដូច្នោះប្រឆាំងនឹងរបបដែលគ្រប់គ្រងបច្ចុប្បន្ន អ៎! នៅចំពោះមុខនៅបច្ចុប្បន្ននោះ។ ហើយខ្ញុំចាំច្បាស់ថា ពេលដែលខ្ញុំចូលជាអង្គការសម្ងាត់ ពេលដែលយប់ខ្ញុំទៅប្រជុំម្តងៗ ខ្ញុំតែងតែគិតថា ថ្ងៃណាមួយខ្ញុំនឹងមិនអាចវិលត្រឡប់មកផ្ទះខ្ញុំវិញទេ។ ព្រោះខ្ញុំមិនដឹងថា នៅតាមផ្លូវដែលធ្វើដំណើរទៅកន្លែងប្រជុំហ្នឹងគឺមានកើតអ្វីទេ។ ប៉ុន្តែយើងសុទ្ធតែដឹងច្បាស់ថា មិនមានជាការ ដូចថាងាយស្រួលដូចនៅប្រទេសអឺរ៉ុប ឬនៅសហរដ្ឋអាមេរិកទេបាទ។

[១១:១៧:២០]

**ស៖** បាទសូមអរគុណ។ តើលោកអាចជួយជម្រាបអង្គជំនុំជម្រះ ជាលក្ខណៈសង្ខេបអំពីបេសកកម្មរបស់បក្សកុម្មុយនីស្តកម្ពុជាបានទេបាទ?

**ឆ៖** ខ្ញុំ អាចជម្រាបបានតាមកម្រិតដែលខ្ញុំយល់ដឹង គឺថាបក្សវាមានឈ្មោះថា "កុម្មុយនីស្ត" ហើយមានកម្ពុជា ដូច្នោះទិសដៅទីចុងបំផុតរបស់បក្សគឺកសាងរបបកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា។ អ្វីទៅថា របបកុម្មុយនីស្តនុ៎ង? គឺរបបកុម្មុយនីស្តគឺថា អ្វីៗទាំងអស់វាស្មើគ្នា វាអ្វីៗទាំងអស់ជារបស់សមូហភាព ជារបស់រួម។ អាហ្នឹងគឺថា ជារួមវាប៉ុណ្ណឹងបាទ។ ក៏ប៉ុន្តែតាមខ្ញុំយល់មិនមែន គឺថា មិន ដូចថាស្អីៗក៏រួមទេ មានបញ្ហាខ្លះក៏យើងឲ្យ ដូចថានៅប្រទេសចិន ឬវៀតណាមដូចថាមានកូនចម្ការរួម មានផ្ទះអីនៅដោយឡែក ហូបបាយអីតាមគ្រួសារអីជាដើម អាហ្នឹងវាមានបាទ។ ហើយអាហ្នឹងគឺថា -- ហើយអាហ្នឹងគឺថា ជាទិសដៅយូរអង្វែងរបស់បក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែជាទិសដៅចំពោះមុខ ដូចឧបមាថានៅឆ្នាំ ក្រោយឆ្នាំ១៩៧០ គឺរំដោះប្រទេសកម្ពុជាពីនឹមអាណានិគមនិយមចាស់ថ្មី និងរបប

សក្តិភូមិ ដែលជារណប ដែលជាអាយ៉ងរបស់បរទេស។ អាហ្នឹងចំពោះមុខ ហើយគឺធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ។ អាហ្នឹងគឺថា ជាចំពោះមុខ។ បាទ តាមខ្ញុំយល់ប៉ុណ្ណឹង។

[១១:១៩:៤៨]

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេ អំពីការទទួលខុសត្រូវរបស់បក្សកុម្មុយ-នីស្តកម្ពុជា រួមជាមួយនឹងហ្វុង នៅពេលដែលមានការសហការគ្នានោះ តើវាមានការបែងចែកការទទួលខុសត្រូវដូចម្តេចដែរ?

**ឆ៖** ខ្ញុំមិនបានដឹងអី ជាក់ច្បាស់ទេ គ្រាន់តែខ្ញុំយល់ថា ខាងក្នុងគឺ ការតស៊ូដោយអាវុធ គឺជាការតស៊ូដឹកនាំដោយបក្សកុម្មុយនីស្តកម្ពុជា ហើយនៅក្រៅគឺជា ក្រោមគឺថា ការដឹកនាំ និងគ្រប់គ្រងរបស់សម្តេចព្រះ នរោត្តម សីហនុ ប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ព្រះប្រមុខរដ្ឋពេញច្បាប់នៅពេលនោះ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេ ថាតើអង្គការទាំងពីរនេះ មួយណាមានឥទ្ធិពលលើមួយណាជាង?

**ឆ៖** ខ្ញុំអាចជម្រាបថា កម្លាំងទាំងពីរនេះ រួមសហការគ្នា ហើយបើនិយាយពីឥទ្ធិពល នៅពេលនោះ ទាំងក្នុងប្រទេសនិងក្រៅប្រទេសឥទ្ធិពលរបស់សម្តេចព្រះ នរោត្តម សីហនុ មានឥទ្ធិពលគឺថាគ្របដណ្តប់ ជាពិសេសនៅក្រៅប្រទេស។ នៅក្នុងប្រទេស ក៏ឥទ្ធិពលរបស់សម្តេច ក៏នៅគ្របដណ្តប់ដែរបាទ។ ហើយឥទ្ធិពលរបស់បក្សកុម្មុយនីស្តកម្ពុជា ក៏អាចរីកលូតលាស់ក៏នៅក្រោម ដូចថា នៅក្រោមទង់របស់សម្តេច នរោត្តម សីហនុ ដែរបាទ។ អានេះហើយ ដែលយើងត្រូវដឹងដូច្នេះ ព្រោះកម្លាំងទាំងពីរហ្នឹងសហការគ្នា មិនមានដូចថា អ្នកណាមានឥទ្ធិពលជាងនរណាទេ ព្រោះយើងមិនអាចវាស់ស្ទង់បានទេ ព្រោះជួនកាលបុគ្គលតែមួយហ្នឹង គឺជាអ្នកគោរពស្រឡាញ់សម្តេច សីហនុ ផង ហើយក៏ជាអ្នក គឺកាន់អាវុធដើម្បីធ្វើការតស៊ូនៅខាងក្នុងប្រទេស ដើម្បីសម្រេចទិសដៅរួមរបស់រណសិរ្សរួបរួមជាតិកម្ពុជាដែរបាទ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការ -- បាទសូមអធ្យាស្រ័យដោយសារការបកប្រែមិនទាន់ចប់ ដូច្នេះខ្ញុំសូមផ្អាកបន្តិច។ បាទ ខ្ញុំសូមសួរបន្ត ទាក់ទងទៅនឹងការគ្រប់គ្រងរដ្ឋបាល តាមមូលដ្ឋាន ក៏ដូចជាការបញ្ជាទ័ពនោះ ថាតើហ្វុងមានសិទ្ធិបញ្ជានៅតាមមូលដ្ឋាន ក៏ដូចជានៅតាមសមរភូមិដែរទេ?

[១១:២៣:៤៩]

**ឆ៖** ខ្ញុំមិនអាចជម្រាបបាន ឆ្លើយបានទេ ព្រោះខ្ញុំនៅពេលនោះ ខ្ញុំនៅក្រៅប្រទេស កិច្ចការរាក់ជ្រៅទាំងប៉ុន្មាន គឺថាខ្ញុំមិនអាចដឹងបានទេ។ ខ្ញុំគ្រាន់តែដឹងថា កម្លាំងដែលនៅខាងក្នុងគឺ ចែកជាកម្លាំង គឺថាកម្លាំងប្រដាប់អាវុធរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយកម្លាំងប្រដាប់អាវុធរបស់វៀតកុងរបស់រណសិរ្សរំដោះជាតិវៀតណាមខាងត្បូង របស់វៀតកុងហ្នឹងគឺ ដែលបានបំពាក់អាវុធ បានហ្វឹកហ្វឺន បានដឹកនាំកសាងកម្លាំងខាងសម្តេច នរោត្តម សីហនុ បាទ។

[១១:២៤:៤៨]

**ស៖** បាទសូមអរគុណ។ ខ្ញុំសូមសួរលោកទាក់ទងទៅនឹងតួនាទីរបស់លោក ខៀវ សំផន នៅក្នុងអង្គការហ្រ្គុង លោកបានឆ្លើយបញ្ជាក់រួចហើយថា លោក ខៀវ សំផន គឺជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ និងជាអគ្គមេបញ្ជាការនៃកងទ័ពរំដោះជាតិកម្ពុជា។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា នៅក្នុងសម័យតស៊ូនោះ ថាតើលោកមានបានដឹងអំពីការបំពេញតួនាទីពិតប្រាកដរបស់លោក ខៀវ សំផន នៅក្នុងមុខតំណែងដែលមាននេះទេ?

**ឆ៖** ខ្ញុំពេលនោះ ខ្ញុំនៅក្រៅប្រទេស ហើយនៅក្នុងប្រទេស កិច្ចដំណើរការជាក់ស្តែងយ៉ាងណាខ្ញុំមិនបានដឹងទេ។ ខ្ញុំអាចជម្រាបលោកមេធាវី និងអង្គសវនាការថា បើជាអគ្គមេបញ្ជាកងទ័ពរំដោះអីហ្នឹង គឺថាតាមមើលទៅមិនមែនលោក ខៀវ សំផន គ្រាន់តែជា ដូចថាជាៗ ដូចថា មិនមានអី គ្រាន់ថាជាមានតែឈ្មោះអីចឹងទេ គាត់មិនមានអំណាចអីពិតប្រាកដទេ។ ហើយខ្ញុំជម្រាបនេះ ខ្ញុំដឹងក្រោយមកទេ ប៉ុន្តែខ្ញុំអាចសន្និដ្ឋានថា នៅពេលនោះ មើលទៅ ក៏គ្រាន់តែជាឈ្មោះតែប៉ុណ្ណឹងទេបាទ គឺថាអ្នកផ្សេងទេដែលទទួលនាទីនេះ ពិតប្រាកដបាទ អ្នកបញ្ជាកងទ័ពបាទ។

[១១:២៧:០២]

**ស៖** បាទ សូមអរគុណ។ តើលោកអាចបញ្ជាក់បានទេ ថាតើអ្នកណាជាអ្នកបញ្ជាកងទ័ពពិតប្រាកដនោះ?

**ឆ៖** ខ្ញុំមិនដឹងទេ ពេលនោះ ព្រោះវាជារួមគ្រាន់តែថា អ្នកណាជាលេខាបក្ស ក៏មិនដឹងទេ។ ពេលដែលខ្ញុំនៅ -- ឧបមាថា ខ្ញុំនៅប៉េកាំង គឺខ្ញុំអត់ស្មានថាលោក ប៉ុល ពត ដែលឈ្មោះដើមគាត់សាឡុត ស ជាលេខាបក្សទេ គឺយើងខ្ញុំប៉ុន្មាននាក់ហ្នឹង គឺតែចេះស្មានទៅ ស្មានថា លោក ខៀវ សំផន ជាលេខាបក្ស ឬក៏លោក អៀង សារី ជាលេខាបក្ស។ ប៉ុន្តែឲ្យស្មានថា លោក ប៉ុល ពត ជាលេខាបក្ស គឺអត់ស្មានដល់ទេបាទ។ ដូច្នោះ ខ្ញុំមិនអាចឆ្លើយបាន គឺថាច្បាស់លាស់ចំពោះសំណួរហ្នឹងទេបាទ។

**សៈ** បាទ សូមអរគុណ។ ខ្ញុំសូមចូលមកដល់ក្នុងសម័យ ១៧ មេសា ១៩៧៥ ហើយនិយាយអំពីតួនាទីរបស់លោក ខៀវ សំផន ដដែល។ លោកបានជម្រាបអង្គសវនាការហើយថា លោក ខៀវ សំផន មានតួនាទីជាប្រធានគណៈប្រធានរដ្ឋ។ ខ្ញុំចង់សួរបញ្ជាក់ថា តើលោកបានដឹងអំពីការងាររបស់គណៈប្រធានរដ្ឋនេះ ឬក៏មានការិយាល័យជាអង្គការចាត់តាំង នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះដែរទេ?

**ឆៈ** គណៈប្រធានរដ្ឋហ្នឹង គឺថាមានបីនាក់។ មានប្រធាន អនុប្រធានទី១ និងអនុប្រធានទី២។ ប៉ុន្តែបើតាមខ្ញុំដឹងទៅ ដូចមានតែប៉ុណ្ណឹងទេ ហើយកន្លែងណាជាការិយាល័យ ជាទីស្នាក់ការអី គឺដូចអត់មានទេបាទ ដូចជាក្រសួងនានាមួយចំនួនអីចឹង។ ដល់ប្រហែលគ្នាហ្នឹង មានតែនៅនឹងក្រដាស បាទ។

[១១:២៩:៤១]

**សៈ** លោកអាចបញ្ជាក់បានទេ ថាតើក្រសួងណាខ្លះ ដែលមានតែឈ្មោះលើក្រដាស ហើយអត់មានការិយាល័យ ឬទីស្នាក់ការពិតប្រាកដ?

**ឆៈ** ខ្ញុំអាចថា ឧបមាថាក្រសួងសាធារណការ កាលហ្នឹងមានលោក តូច ភឿន ជារដ្ឋមន្ត្រី។ ហ្នឹងដូចគ្មានក្រសួង ដូចគ្មានក្រសួងរដ្ឋមន្ត្រីអីទេ។ ឧបមាថា ក្រសួងឧស្សាហកម្មអី ដូចជាគ្មានអីទេ។ មែនទែននៅពេលនោះ ក្រសួងដែលមានរចនាសម្ព័ន្ធសមស្របជាក្រសួងរដ្ឋមន្ត្រី គឺមាននៅតែក្រសួងការបរទេសទេបាទ ដូចមានការចាត់តាំងអីជាខ្សែសង្វាក់អីក្រសួងអីទៀត។ ឧបមាថាក្រសួងឃោសនាការ និងព័ត៌មាន មានការចាត់តាំងមួយចំនួនដែរ ប៉ុន្តែដូចមិនមានផ្នែកអីច្បាស់លាស់ទេបាទ។ ប៉ុន្តែក្រៅពីក្រសួងការបរទេស មានក្រសួងព័ត៌មាននិងឃោសនាហ្នឹង ដែលដូចថា មានការចាត់តាំងអីគ្រាន់បើ ប៉ុន្តែដូចក្រសួងអីទៀត -- ឧបមាថា ឥឡូវដូចថា ពួកក្រសួងសុខាភិបាល។ ក្រសួងសុខាភិបាលកាលហ្នឹងមានរដ្ឋមន្ត្រីសុខាភិបាល ដូចថាលោកវេជ្ជបណ្ឌិត ជួន ជឿន មែនទែនមានតែខ្លួនគាត់ម្នាក់ទេ។ ដូច្នោះ មានក្រសួងចំនួនច្រើន មានតែឈ្មោះទេ ក៏អត់មានការចាត់តាំងអី។

[១១:៣១:៤៥]

ហើយបញ្ហានេះវា យើងអាចយល់បាន ព្រោះថាពេលក្រោយពីសង្គ្រាម ពេលកំពុងតែកសាងប្រទេសឡើងវិញគឺ ហើយតាមគោលការណ៍ តាមទ្រឹស្តីរបស់បក្សកុម្មុយនីស្តកម្ពុជាគឺ ការដូចថា ក្រដាសស្នាម មានក្រដាសស្នាម មានទីតាំងអីមានហ្នឹង គឺវាសុទ្ធសឹងតែជារបស់ដែលវាទុកឲ្យមានភស្តុតាងអាចខ្មាំងយកព័ត៌មានតាមហ្នឹង។ ដូច្នោះ អ្វីៗធ្វើដោយសម្ងាត់ ធ្វើដោយដូចថាខុសពីក្បួនខ្នាតៗ

ដែលគេធ្លាប់ធ្វើធម្មតាបាទ។

ឥឡូវខ្ញុំជម្រាប ខ្ញុំចង់បន្ថែមជម្រាបអង្គប្រជុំមួយ។ លោកប្រធាន ខ្ញុំសូមអត់ទោស ដើម្បីឱ្យយល់ ខ្ញុំចេះតែថែមថយអ៊ីចឹង ប៉ុន្តែដើម្បីយល់ទេ។ ខ្ញុំមិនចង់អីនិយាយទេ។ ឧបមាថា ខ្ញុំជាអ្នកបកប្រែព្រឹកហ្នឹងខ្ញុំទៅបកប្រែឱ្យឯកអគ្គរដ្ឋទូតអាល់បានី ដែលគាត់ប្រគល់សារតាំងចំពោះលោក ខៀវ សំផន ជាប្រធានរដ្ឋ។ ហើយឯកអគ្គរដ្ឋទូតអាល់បានីជាពួកម៉ាក់ខ្ញុំ គាត់ស្គាល់ខ្ញុំច្បាស់។ អ៊ីចេះទៅទៀត។ ដល់ល្ងាចហ្នឹង ខ្ញុំ -- ប្រពន្ធឯកអគ្គរដ្ឋទូតគាត់ឈឺ ត្រូវឱ្យពេទ្យក្រសួងហ្នឹងទៅមើលគាត់ អត់មានពេទ្យណាមានពេទ្យក្រសួង។ ខ្ញុំក៏ទៅបកប្រែឱ្យគ្រូពេទ្យក្រសួងហ្នឹងទៅមើលប្រពន្ធលោកឯកអគ្គរដ្ឋទូតអាល់បានីហ្នឹង។ ដល់ខ្ញុំទៅកន្លែងស្ថានទូតរបស់គាត់ហ្នឹង ផ្ទះគាត់ហ្នឹង គាត់មើលខ្ញុំចេះតែមើលអ៊ីចឹង ហើយគាត់អត់និយាយអីទេ គាត់អត់ស្ដីឱ្យអី និយាយខ្ញុំមួយម៉ាត់ ខ្ញុំឆ្ងល់ដែរ ព្រោះខ្ញុំពួកម៉ាក់គ្នា គាត់ចេះ អត់មាននិយាយស្ដីខ្ញុំបកប្រែទៅ។ ខ្ញុំមកវិញ ហើយខ្ញុំចេះតែឆ្ងល់។

[១១:៣៤:០៦]

បានក្រោយមក បានគាត់ប្រាប់ខ្ញុំថា នៅស្រុកគេអ្នកបកប្រែប្រមុខរដ្ឋមិនដែលឱ្យមកបកប្រែឱ្យអ្នកធម្មតាអីទេ គេឱ្យបកប្រែតែប្រមុខរដ្ឋតែមួយទេ។ នេះខ្ញុំចង់និយាយអ៊ីចឹង ប៉ុន្តែខ្ញុំចង់និយាយកម្ពុជាប្រជាធិបតេយ្យ ហើយខ្ញុំក៏អត់ដឹងរឿងពិធីការហ្នឹងដែរ។ ខ្ញុំទៅធម្មតា តែបើឱ្យគេទៅបកប្រែ ទៅកន្លែងណាក៏បកប្រែដែរ។ នេះខ្ញុំសូមជម្រាបបញ្ហាហ្នឹងមួយបាទ។

**សៈ** បាទ សូមអរគុណ។ ពីម្សិលមិញ នៅពេលព្រឹកលោកបានមានប្រសាសន៍ថា ខ្ញុំសូមអានសម្រង់ ដែលចេញជាភាសាខ្មែរទំព័រ១៩ នៅពេលព្រឹកគឺម៉ោង ១០:០៩ ខាងលើហ្នឹងបន្តិច។ ខ្ញុំសូមអានជូនលោក ហើយសូមលោកបញ្ជាក់ឡើងវិញ ព្រោះតាមខ្ញុំដឹងថា ពុំមានការបកប្រែជាភាសា ផ្សេងទៀតទេ។ អ៊ីចឹង ខ្ញុំសូមអានជូន ៖ "ខ្ញុំធ្លាប់បាននិយាយហើយ គឺថាលោក ខៀវ សំផន ក៏ដូចតែខ្ញុំអ៊ីចឹង គ្រាន់តែគាត់ចាស់ គាត់នឹងនរជាងខ្ញុំ គេយកទៅដាក់គាត់ទៅប្រមុខរដ្ឋទៅ ប៉ុន្តែមែនទែនដូចតែគ្នាហ្នឹង។ ន៎ែឱ្យយល់ថា របៀបរបបកុម្មុយនីស្តគេដឹកនាំយ៉ាងម៉េច"។ បាទសូមបិទវិញ។ លោកចាំថា នេះជាសម្ដីរបស់លោកទេ?

**ឆះ** បាទ ខ្ញុំគ្រាន់តែថា ខ្ញុំហើយនិងគាត់បើចំពោះមុខបក្សកុម្មុយនីស្តកម្ពុជា តាមដែលគោលការណ៍ តាមកិច្ចអនុវត្តនៅពេលនោះ វាដូច្នេះឯង។ គឺថាបុគ្គលនីមួយៗមិនមានសារៈសំខាន់ជាអចិន្ត្រៃយ៍ទេ មិនមែនគឺថា មិនចាំបាច់ទេ។ គឺថា ដូចខ្ញុំ ខ្ញុំនិយាយពីខ្ញុំហើយនិងគាត់។ កន្លែងនេះគឺ គេដាក់គាត់ហ្នឹង

ចាត់តាំងគាត់ហ្នឹង គឺដោយសារគាត់បំពេញលក្ខណៈសម្បត្តិមួយចំនួនដែលខ្ញុំគ្មាន ចង់និយាយអ៊ីចឹងចុះ។ ដូចថាគាត់ចាស់ជាងខ្ញុំ គាត់មានសញ្ញាបត្រ ហើយគាត់ជាពិសេស គាត់អំណត់ នឹងនរ បើខ្មែរយើងនិយាយថា គាត់ចាស់ទុំជាងខ្ញុំ ក៏ប៉ុន្តែតាមខ្ញុំដឹងគាត់មិនមានសិទ្ធិអំណាចអីជាងខ្ញុំប៉ុន្មានទេ។ ក្នុងឋានៈជាប្រមុខរដ្ឋ ខ្ញុំចង់និយាយប្រមុខរដ្ឋធម្មតានៅប្រទេសគេណា៎ះ។ ឧបមាប្រមុខរដ្ឋនៅប្រទេសគេមាន មានស្អីអីៗគ្រប់សព្វ មានសិទ្ធិអំណាច មានអី ដូចថា ចុះហត្ថលេខាលើក្រិត្យក្រមអ៊ីចឹង គឺថាគាត់មិនមានទេ។ ខ្ញុំចង់និយាយអ៊ីចឹង។ មិនមែនមានន័យថា ខ្ញុំចង់ការពារគាត់ ស្អីគាត់អ៊ីចឹងទេ។ ខ្ញុំសូមជម្រាបថា ខ្ញុំនិយាយពីការជាក់ស្តែងដែលខ្ញុំបានឃើញ ហើយខ្ញុំក៏មិនមានគិតថា អ្វីដែលខ្ញុំនិយាយហ្នឹងសុទ្ធតែត្រូវទេ ជួនកាលខ្ញុំមិនបានទិដ្ឋភាពខ្លះ នៃកិច្ចការខ្លះ នៃព្រឹត្តិការណ៍ខ្លះ នៅពេលនោះទេ ខ្ញុំមិនបានដឹងទេ។ ចំពោះដែលខ្ញុំដឹង គឺតែប៉ុណ្ណឹងបាទ។

[១១:៣៨:១៩]

ព្រោះខ្ញុំលើកឧទាហរណ៍មួយទៀត ដូចលោកវេជ្ជបណ្ឌិត ជួន ជឿន គាត់ជារដ្ឋមន្ត្រី ខាងសុខាភិបាលខាងអីហ្នឹង។ ក៏ប៉ុន្ត ធម្មតា គាត់ជាគ្រូពេទ្យមួយធម្មតាប៉ុណ្ណឹង។ គ្មានក្រសួង គ្មានបុគ្គលិក គ្មានអីគាត់បញ្ជា គាត់តែបញ្ជាតែខ្លួនគាត់ម្នាក់ប៉ុណ្ណឹងបាទ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូម លោកប្រធានរំឭកដល់សាក្សីថា គាត់មិនត្រូវឆ្លើយព្រាវៗទេ គឺថា មានចម្លើយជាច្រើនដែលគាត់ទាញសេចក្តីសន្និដ្ឋានជាបុគ្គលដោយពុំមានមូលដ្ឋាននៃការទាញសន្និដ្ឋាននេះច្បាស់លាស់នោះទេ។ ហើយលោកប្រធានបានរំឭកច្រើនដងហើយ ដែលថាសាក្សីនេះមិនមែនជាអ្នកជំនាញទេ។ អ៊ីចឹងសូមឲ្យកម្រិត ធ្វើត្រឹម ធ្វើការផ្តល់សក្ខីកម្ម ត្រឹមតែអ្វីដែលបានដឹងបានហើយ បានដឹង បានឮ បានឃើញបានហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ មេធាវី!

**លោក គង់ សំអុន៖**

ខ្ញុំគ្រាន់តែសុំឆ្លើយតបដោយខ្លីទៅសហព្រះរាជអាជ្ញាថា សាក្សីរូបនេះ គាត់បានដឹង និងបានចូល

រួមដោយផ្ទាល់នៅក្នុងព្រឹត្តិការណ៍តាំងពីការតស៊ូនៅក្រៅប្រទេស រហូតមកដល់ការធ្វើបដិវត្តន៍នៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ ការវាយតម្លៃរបស់គាត់វាជាការចាំបាច់សម្រាប់ឲ្យសវនាការនេះធ្វើការសម្រេចសេចក្ដីបានដែរ។ ហើយអ្វីដែលលោកមានប្រសាសន៍បន្ថែម វាអាចលើសលស់ខ្លះ ក៏ប៉ុន្តែក៏មានប្រយោជន៍ជាច្រើនដែរ។ បាទ សូមអរគុណ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំបាទ សូមសួរបន្តនូវសំណួរចំណុចមួយបន្ថែមទៀត ទាក់ទងទៅនឹងចម្លើយរបស់លោកដែលលោកបញ្ជាក់ថា ក្នុងនាមលោកជាបញ្ញវន្ត ជាបញ្ញាជនម្នាក់ លោកមិនចាំបាច់ប្រើខួរក្បាលរបស់លោកដើម្បីគិតទៅលើបន្ទាត់នយោបាយ ឬក៏អ្វីដែលជាការបញ្ជារបស់បក្សទេ។ ហើយលោកត្រូវធ្វើទៅតាមការបញ្ជានោះ ដោយលោកគិតថា ការគិតរបស់លោកវាអាចធ្វើឲ្យមានការខុសប្លែកពីការគិតរបស់អ្នកបដិវត្តន៍ ដែលជាអ្នកតស៊ូ។ សូមឲ្យលោក -- អាចបញ្ជាក់បន្ថែមពីចំណុចនេះថា ហេតុអ្វីបានជាលោកត្រូវបោះបង់ការគិតរបស់លោក ដើម្បីវិភាគថាតើវាខុស វាត្រូវ ឬក៏វាមានសេរីភាព ឬក៏ខ្វះសេរីភាពយ៉ាងដូចម្ដេចនោះ? ហេតុអីបានជាបញ្ញវន្តនៅក្នុងសម័យនោះ បញ្ញាជនក្នុងសម័យនោះ ដែលជាអ្នកស្ថិតនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា មិនប្រើបញ្ញាណរបស់ខ្លួនដើម្បីពិចារណាទៅលើភាពចាំបាច់ទាំងអស់នោះ? សូមលោកជួយពន្យល់បន្ថែម។

[១១:៤២:០៨]

**ឆ៖** លោកប្រធាន អាហ្នឹងតើខ្ញុំៗ ខ្ញុំមិនមែនមិនចង់ឆ្លើយទេ ប៉ុន្តែតែឆ្លើយទៅតំណាងព្រះរាជអាជ្ញាថា ឥឡូវខ្ញុំជាអ្នកជំនាញទៀត ព្រោះសំណួរនេះវាដូចអីអត់មានច្បាស់លាស់អីទេ។ ប៉ុន្តែខ្ញុំឆ្លើយបានមានអីទេ មានអីខ្ញុំពន្យល់បាន ព្រោះខ្ញុំរស់នៅៗក្នុងនុំងហើយ ហើយពន្យល់ ខ្ញុំអាចពន្យល់បាន។ បាទ ចំពោះខ្លួនខ្ញុំព្រោះខ្ញុំឆ្លងកាត់ ខ្ញុំពន្យល់បាន។

**ប្រធានអង្គជំនុំ៖**

បាទ លោកមិនបាច់ឆ្លើយតបនឹងសំណួររបស់លោកមេធាវីអម្បាញ់មិញទេ។ ការបង្ហាញពីការយល់ដឹងផ្ទាល់ខ្លួនរបស់លោក គឺមានតម្លៃដូចគ្នានឹងសេចក្ដីសន្និដ្ឋាន។ លើកលែងតែមេធាវីដូរនូវការតាំងសំណួរ។ នៅចំពោះលោកផ្ទាល់ខ្លួន នូវអ្វីដែលលោកមានបទពិសោធន៍ឆ្លងកាត់នោះ ជារឿងមួយទៀត។ សំណួរអំមិញនេះ គឺមានអត្ថន័យប្រហែលគ្នានឹងឲ្យលោកធ្វើសេចក្ដីសន្និដ្ឋានដែរ ព្រោះគាត់បង្ហាញពីការយល់ឃើញ។ ការយល់ឃើញជា ការបង្ហាញអំពីគំនិតអត្តនោម័តិរបស់បុគ្គលមួយដែលមិនមានគុណ

សម្បត្តិនៅក្នុងការធ្វើដូច្នេះទេ ពីព្រោះលោកចូលរួមក្នុងនាមជាសាក្សី។

[១១:៤៣:៣៤]

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ លោកប្រធានខ្ញុំសូមកែសម្រួលសំណួររបស់ខ្ញុំ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំសូមសួរថា តាមបទពិសោធន៍របស់លោក ដែលលោកបានចូលរួមនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា តាំងពីនៅក្រៅប្រទេស មុនរំដោះ ១៩៧៥ រហូតមកដល់បានរំដោះប្រទេសឆ្នាំ១៩៧៥ ថាតើមានគោលការណ៍អ្វីរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលកម្រិតការគិត ការពិចារណា ឬការប្រើខួរក្បាលរបស់បញ្ញាជន ដែលជាសមាជិករបស់បក្សនោះ? សូមលោកជួយពន្យល់។

**លោក សួង ស៊ីគឿន៖**

**ឆ៖** គឺខ្ញុំអាចឆ្លើយតាមពិសោធន៍របស់ខ្ញុំ។ គឺទីមួយយើងធ្លាប់រស់នៅក្រៅប្រទេសជាយូរឆ្នាំមកហើយ ហើយជាប្រទេសមួយដែលជា មានរបបនាយទុន ហើយជាអតីតអាណានិគមនិយមកម្ពុជាទៀតផង។ ដូច្នោះ វាមាន -- ហើយការអប់រំរៀនសូត្ររបស់យើង ក៏វាទៅតាមនេះដែរ។ យើងចូលមក យើងចង់បម្រើបដិវត្តន៍ ចង់បម្រើបក្សកុម្មុយនីស្តដែលយើងជាសមាជិក។ ដូច្នោះ អ្វីដែលយើងទទួលនៅខាងក្រៅប្រទេស វាជាឧបសគ្គ។ អាហ្នឹងបើនិយាយឲ្យស្រួលស្តាប់ទៅ គឺថាលក្ខខណ្ឌជាដំបូង បើបារាំងថា *កុងឌីស្យុងប្រេអាឡាប៊ើះ* ត្រូវយើងថា អាហ្នឹងត្រូវបោះបង់វាចោលទៅ។ អាហ្នឹងសុទ្ធតែជាសំពាយ សុទ្ធជាបន្ទុក វាជាឧបសគ្គទេ ត្រូវបោះបង់វាចោលទៅ។ ហើយចាប់កសាងខ្លួន កសាងទស្សនៈ តាមរបៀបថ្មី គឺតាមមាគ៌ា គោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា។ ដូច្នេះ អ្វីដែលបក្សសម្រេច ជាមាគ៌ាក្តី ជាមាគ៌ាយុត្តិសាស្ត្រក្តី ជាយុទ្ធវិធីក្តី ជាវិធានការជាក់ស្តែងក្តី យើងចាំបាច់ត្រូវតែគោរព គឺថាបើគ្រាន់តែយើងគិត គ្រាន់តែចាប់គិតភ្លាម គឺថាយើងគ្មានជំនឿជឿជាក់លើបក្សហើយ គ្រាន់តែគិត។ គ្រាន់តែយើងគិតលើអ្វីដែលយើងបានឃើញហ្នឹង មានន័យថាយើងខ្វះជំនឿជឿជាក់លើបក្សទៅហើយ។ ដូច្នេះយើងមិនចាំបាច់ទេ យើងខំធ្វើម៉េចគឺថាអនុវត្តតាម កសាងខ្លួនតាមនេះ។ ដូច្នោះយើងមិនបានគិតថាតើអាហ្នឹងវាត្រឹមត្រូវ តើវាសមស្រប តើវាអីទេ គឺថានេះហើយដែលយើងយល់នៅពេលនោះ។

[១១:៤៧:៣៩]

ខ្ញុំអាចនិយាយចំពោះពិសោធរបស់ខ្ញុំបាន គឺថាដូចជាយើង -- គេសណ្តំៗយើង យើងចាញ់សណ្តំ

របស់គេហើយ ឃើញទេ៎ គេស្គាល់យើងបានហើយ គេឲ្យយើងធ្វើអ្វីតាមតែចិត្ត អំពើយើងធ្វើ។ ហើយខ្ញុំលើកឧទាហរណ៍មួយ ឧបមាថាកម្មសិទ្ធិឯកជន រឿងរ៉ាវវាចេះតែវែងឆ្ងាយ ប៉ុន្តែដើម្បីពន្យល់បញ្ហាហ្នឹង វាត្រូវលើកឧទាហរណ៍។ ដូច្នោះ ខ្ញុំមិនលើកទេ ព្រោះអាហ្នឹងវាវែងឆ្ងាយទៅទៀត។ ខ្ញុំមិនចង់យកពេលទេបាទ។ ខ្ញុំមិនលើកឧទាហរណ៍ទេបាទ លុះត្រាតែលោកប្រធាន លោកអនុញ្ញាត បានខ្ញុំលើកឧទាហរណ៍ បើនិយាយជាដូចថាជាទ្រឹស្តីជាអីហ្នឹងពិបាកយល់ ទាល់តែមានឧទាហរណ៍ជាក់ស្តែង វាស្រួលយល់បាទ។ បាទ សូមប៉ុណ្ណឹងបាទ។

**ស៖** បាទ សូមអរគុណ។ លោកអាចលើកឧទាហរណ៍បាន បើជាប់ពាក់ព័ន្ធទៅនឹងសំណួររបស់ខ្ញុំអម្បាញ់មិញនេះ។

[១១:៤៩:00]

**ឆ៖** ឧទាហរណ៍មានច្រើនណាស់ ហើយមិនមានអីជានេះ ឧបមាថាយើងថាកម្មសិទ្ធិ យើងបោះបង់ចោលកម្មសិទ្ធិឯកជន មានតែបាឡូមួយ បាឡូមិនដឹងគេ ខ្មែរយើងថាមានតែបាឡូមួយតូចអីចឹង គឺថាសមរម្យហើយ កម្មសិទ្ធិសមរម្យហើយ។ ហើយខ្ញុំឆ្លងកាត់បញ្ហាហ្នឹងពេលដែលក្រោយ៧៩ ហើយខ្ញុំឆ្លងកាត់ទៅប្រទេសថៃ។ ខ្ញុំទទួលខុសត្រូវហ្វូងមនុស្ស អ្នកភៀសខ្លួនហ្នឹងប្រហែល៨00នាក់ មានចាស់មានទុំ។ ដល់ទៅប្រទេសថៃ យប់នេះ យប់ដែលខ្ញុំទៅហ្នឹង គឺថាពួកអ្នកជំនួញថៃសួរខ្ញុំថា លោកមានខ្សែក ក្រវាត់មាសអី រឿងគ្រឿងអលង្ការអីលក់ឲ្យខ្ញុំទេ ដូរឲ្យខ្ញុំទេ ដូរជាស្បៀងជាដីទេ? ខ្ញុំថាពួកខ្ញុំធ្វើបដិវត្តន៍សង្គមនិយមស្អីក៏គ្មានដែរ។ ហើយអ្នកជំនួញថៃហ្នឹងសួរពីរបីដង ចង់ខឹងខ្ញុំ ថាខ្ញុំភរ ខ្ញុំថាអត់មានទេ។ គាត់ក៏ទៅវិញទៅ។ ដល់យប់ស្អែកឡើងស្រាប់តែអ្នកដែលនៅជាមួយខ្ញុំ អ្នកខ្លះមានខ្សែក្រវាត់មាសពាក់កណ្តាល អ្នកខ្លះមានការ មានចិញ្ចៀន មានខ្សែដៃ សុទ្ធតែមាស សុទ្ធតែពេជ្រ យកមកដល់។ ឥឡូវពូ ណេះយកទៅ ខ្ញុំសូមតែត្រីខកំប៉ុង ប្រាំកំប៉ុងត្រីខ។ បានខ្ញុំ អូ៎ អីចឹងទេ បដិវត្តន៍សង្គមនិយមអីចឹងទេ ងាប់ហើយឡើងអីចឹង។ អាហ្នឹងវាអីចឹង។ ខ្ញុំចង់និយាយថា ដល់អីចឹងបាន -- ហើយមានរឿងច្រើនណាស់អាអីចឹង។ បានអីចឹងថាដូច្នោះ ការដែលអប់រំអត់មានកម្មសិទ្ធិឯកជន អត់មានអី -- ហើយខ្ញុំសូមជម្រាបថា កាលដែលខ្ញុំចូលភ្នំពេញ៧៥ ពេជ្រ ពេជ្រត្បូង ទទឹម អាស្អីហ្នឹងនៅពេញតែផ្លូវ អត់មាននេះទេ អត់មានរើសយកទុកទេ ខ្ញុំផ្ទាល់ អត់មានរើសយកទុកទេ។ អើ បើសិនជាត្រីខ អាស្អីហ៊្វរក្រាយ អាហ្នឹងបើកហូប កាហ្វេ ខ្ញុំលួចយកទុកតែកាហ្វេអីអីចឹង។ ឃើញទេ នេះចង់និយាយអីចឹងហើយយើង--

[១១:៥១:២៩]

**ប្រធានអង្គជំនុំ៖**

បាន។ ហើយ! សូមបន្តសំណួរតទៅទៀត!

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកអាចពន្យល់អំពី -- លោកអាចពន្យល់អំពីគោលការណ៍សាមគ្គីភាពនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាបានទេ? ហើយសូមលោកពន្យល់ខ្លីៗបានហើយ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីកែសម្រួលនូវតាំងសំណួរ។ កាលណាបើលោកប្រើពាក្យ“ពន្យល់”នេះ ប្រហែលជាមិនទំនងជាសាក្សីទេ វាចូលអ្នកជំនាញហើយ។ ការពន្យល់គឺវាបង្ហាញអំពីការគិតអត្តនោម័តិរបស់គាត់ទៅនឹងអង្គហេតុ ព្រឹត្តិហេតុទាំងឡាយដែលកើតមាន។ យើងមិនអនុញ្ញាតឲ្យលោកតាំងសំណួរបែបនេះទេ ពីព្រោះគាត់ជាសាក្សី មិនមែនជាអ្នកជំនាញទេ។

[១១:៥២:៤៤]

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ សូមអស់សំណួរ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក សួង ស៊ីគឿន ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ឥឡូវដល់វេនខ្ញុំ សូមចោទសំណួរទៅលោកដែលជាសំណួរសូមបំភ្លឺទៅនឹងចម្លើយរបស់លោកមួយចំនួន ទោះបីជាក្នុងលក្ខខណ្ឌនៃការឆ្លើយតបនៅមុខតុលាការនេះ ឬក៏ក្នុងការស្តាប់ចម្លើយលោកពីមុនៗមក ដោយសហចៅក្រមស៊ើបអង្កេតក៏ដោយ។

សំណួរទី១របស់ខ្ញុំទាក់ទងទៅនឹងប្រធានបទ ដែលលោកបាននិយាយនៅក្នុងសវនាការថ្ងៃទី០៦ សីហា មុននេះ ដែលលោកបានពន្យល់ថា នៅក្នុងក្របខ័ណ្ឌនៃខ្សែជីវិតអ្នកបដិវត្តន៍របស់លោក លោក

ត្រូវតែប្រឆាំងខ្លាំងនៅក្នុងខ្លួនឯងផ្ទាល់តែម្តង គឺថាសំដៅកែប្រែផ្នត់គំនិត។ សំណួរខ្ញុំដូចតទៅនេះ ក្នុងឋានៈជាបញ្ញាជន តើលោកចាត់ទុកខ្លួនឯងថាជាអ្នកដែលពិបាកប្រឆាំងជម្រះខ្លាំងនៅក្នុងខ្លួនឯង ជាងកសិករ ឬកម្មករ ឬក៏យ៉ាងម៉េច?

[១១:៥៤:៤២]

**លោក សួង ស៊ីគឿនៈ**

**ឆៈ** បញ្ហាហ្នឹងវាទាក់ទងនឹងបញ្ហាកម្មសិទ្ធិឯកជន គឺបើតាមទ្រឹស្តី ហើយខ្ញុំជឿជាក់ថា ក៏ការពិតជាក់ស្តែងក៏ដូច្នោះដែរ។ គឺកាលណាយើងមានវណ្ណភាពខ្ពស់កាលណា កម្មសិទ្ធិឯកជនវាក្រាស់កាលណោះ។ ដូច្នោះការដែលកែប្រែក្នុងពូជផ្ទៃក្នុងក៏វាមានការលំបាក មានជួបឧបសគ្គច្រើនដែរបាទ។ នេះតាមដែលខ្ញុំយល់។ ក៏ប៉ុន្តែដល់ជាក់ស្តែង ខ្ញុំសូមជម្រាបថាជាក់ស្តែង បញ្ហានេះដូចមិនមានអាស្រ័យតាមវណ្ណៈទេ។ បើនិយាយពី បើអាស្រ័យតាមបុគ្គលដូចត្រូវជាង ព្រោះវណ្ណៈកសិករហ្នឹងក៏ -- ប៉ុន្តែអាហ្នឹងទ្រឹស្តីម៉ាក្សទេ ក៏បាននិយាយដែរ។ វណ្ណៈកសិករ គឺថាជាវណ្ណៈដែលជាប់ជំពាក់នឹងកម្មសិទ្ធិឯកជនជាងគេ។ ឃើញទេ! ព្រោះយើងដឹងស្រាប់ហើយដូចថា មិត្តភក្តិខ្លួនអ៊ីចឹងណ៎ា មិត្តភក្តិនៅជិតគ្នាអាដីពីរម៉ែត្រ បីម៉ែត្រ ខ្ញុំនៅហ្នឹង ខ្ញុំគ្រវីក្បាល ដីពីរម៉ែត្រ បីម៉ែត្រក៏ដណ្តើមគ្នាដែរ។ អ៊ីចឹងបានថាបញ្ហាដីនេះវាចូលដល់ទៀតហើយ។ ឃើញទេ! វាអ៊ីចឹង វាកម្មសិទ្ធិឯកជនហ្នឹងគឺថាមានការលំបាក។

[១១:៥៦:១១]

ចំពោះខ្ញុំ ខ្ញុំដូចមិនសូវមានការលំបាកអីប៉ុន្មានទេ កម្មសិទ្ធិឯកជន ព្រោះៗអីអាហ្នឹងតាមមើលទៅមិនមែនជាការអប់រំអីប៉ុន្មាន អាហ្នឹងជាធាតុរបស់ខ្ញុំ។ ខ្ញុំគឺថា ខ្ញុំមនុស្ស បើនិយាយៗថាមនុស្សចិត្តល្អអ៊ីចឹងតែម្តង។ មិនមែនថា ខ្ញុំមិនមែនថាខ្ញុំមនុស្សល្អទេ ខ្ញុំថាមនុស្សខ្ញុំចិត្តល្អ។ ខ្ញុំមានអី ឲ្យតែគេសុំខ្ញុំ ខ្ញុំឲ្យហើយ ខ្ញុំអត់ទេ ឲ្យតែហារមាត់សុំខ្ញុំ ខ្ញុំឲ្យហើយ។ តាមមើលទៅ អាចសួរខ្ញុំថា ឥឡូវបើអ្នកសុំជីវិតអ្នកឯងឲ្យទេ? ខ្ញុំថា វាអាស្រ័យអ្នកសុំ ជួនកាលសុំជីវិតខ្ញុំ ជួនកាលខ្ញុំឲ្យដែរ។ អាហ្នឹងវាអ៊ីចឹងតែម្តងដូចថាវា -- ហើយខ្ញុំមិនមែនថាជាគុណសម្បត្តិអីទេ អាហ្នឹងវាអាចជាគុណសម្បត្តិផង ជាគុណវិបត្តិផង។ បាទ ខ្ញុំសូមឆ្លើយប៉ុណ្ណឹងបាទ។

**សៈ** លោកសាក្សី ខ្ញុំអរគុណដែលបានឆ្លើយ។ ហើយខ្ញុំសូមសង្កត់ធ្ងន់ សូមឲ្យលោកនិយាយយឺតៗជាងហ្នឹង ពីព្រោះថាយើងមិនអាចទទួលចម្លើយរបស់លោកជាភាសាបារាំងទាំងស្រុងនោះទេ។ ហើយខ្ញុំនឹងសុំចោទសំណួរជាក់លាក់ទៅលោក ហើយសូមឲ្យលោកឆ្លើយមកជាក់លាក់ផងដែរទៅនឹង

សំណួរទាំងអស់នេះ។ សំណួរខ្ញុំដូចតទៅនេះ៖ មុននឹងពេលសម្រាកនេះ ខ្ញុំចង់សួរលោកថា លោកបាននិយាយជាច្រើនដង អំពីការមិនទុកចិត្តបញ្ញាជន ដែលត្រូវបានទទួលការបណ្តុះបណ្តាលនៅបរទេស លោកបានរំឭកអម្បាញ់មិញទៅសហការីនោះថា ពីរឿងនេះអម្បាញ់មិញនោះ។ ហើយសំណួរខ្ញុំគឺថា តើការមិនទុកចិត្តជាប្រចាំថ្ងៃនៅក្នុងក្របខ័ណ្ឌការងាររបស់លោកនោះ ស្តែងឡើងតាមរបៀបណាដែរ?

**ឆ៖** ខ្ញុំនិយាយពីការមិនទុកចិត្តហ្នឹង គឺតាមមើលទៅវាជារួមតែម្តងបាទ ទាំងគ្រប់ទិដ្ឋភាពអីចឹងតែម្តង។ ព្រោះស្អីៗក៏ដោយក្នុងៗកម្ពុជាប្រជាធិបតេយ្យ ក្នុងខ្មែរក្រហម ក្នុងលទ្ធិកុម្មុយនីស្តហ្នឹង វាអ្វីៗវាទាក់ទងគ្នា។ ដូច្នេះយើងមិនអាចបែងចែកពីនយោបាយ ពីការរស់នៅ ពីស្អីទេ វាស្អីៗវាទាក់ទងគ្នា ស្អីៗមានឥទ្ធិពលលើគ្នា។ ដូច្នោះការទុកចិត្តមិនទុកចិត្តហ្នឹងវា វាជាការគ្រប់ជំហានហើយ។

[១១:៥៩:៣០]

ហើយឧទាហរណ៍មានច្រើនណាស់ តូចៗអីចឹង ប៉ុន្តែអានេះគឺដូច្នេះហើយបានជា យើងរស់នៅហើយយើងដូចថា ប្រាស្រ័យទាក់ទងគ្នា ខ្ញុំអត់ទោសគឺថា ប្រាស្រ័យទាក់ទងគ្នាតែចំពោះបញ្ញាជនដូចគ្នាដែរ។ ដូចថា ឧបមាខ្ញុំនិងបងៗឯទៀត គឺអានេះវារាប់ទាំងលេខារបស់បក្សផង ខ្ញុំធ្លាប់ស្គាល់គាត់ ខ្ញុំអត់សូវខ្លាចគាត់ប៉ុន្មានទេ។ ខ្ញុំត្រង់ទេ ខ្ញុំនិយាយប្រាប់គាត់ ឃើញទេ! ព្រោះខ្ញុំស្គាល់គាត់។ ហើយដូច្នោះវាអីចឹង វាមានដូចថា ប៉ុនថាឧបមាថា អ្នកដឹកនាំផ្សេងទៀត ដែលមិនមែនជាបញ្ញាជន ដែលមិនមែនខ្ញុំស្គាល់ ក៏ខ្ញុំអត់សូវប៉ាានដែរបាទ។ ខ្ញុំសូមជម្រាបលោកស្រីមេធាវីបានតែប៉ុណ្ណឹងទេបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន លោកស្រីមេធាវី។ អរគុណសាក្សី។

ឥឡូវដល់ពេលសមល្មមសម្រាកដើម្បីពិសាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាថ្ងៃត្រង់ ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ប៉ុន្តែមុននឹងប្រកាសបន្តកិច្ចដំណើរការសវនាការ អង្គជំនុំជម្រះសូមតាំងសំណួរទៅលោក សួង ស៊ីគឿន ថាតើនៅរសៀលនេះ លោកអាច -- តាមប៉ាន់ស្មានលើសុខភាពរបស់លោក តើលោកអាចបន្តការផ្តល់សក្ខីកម្មនៅរសៀលនេះ ចំពោះមុខអង្គជំនុំជម្រះបានទៀត ដែរឬទេ ឬក៏លោកស្នើសុំសម្រាកនៅរសៀលនេះ ហើយបន្តមកផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែក?

[១២:០១:៣៤]

**លោក សួង ស៊ីគឿន៖**

បាទ លោកប្រធាន គឺតាមសភាពការណ៍សុខភាពរបស់ខ្ញុំ ខ្ញុំមិនអាចបន្តធ្វើសក្ខីកម្មរសៀលនេះទេ ហើយក៏បើលោកប្រធានអនុញ្ញាត ក៏ខ្ញុំសូមសម្រាកស្អែកពេញមួយថ្ងៃទៀតបាទ។ ព្រោះសុខភាពរបស់ខ្ញុំ តាមដែលខ្ញុំពិនិត្យមើលទៅ វាៗកាន់តែចុះទ្រុឌទ្រោមដែរ ព្រោះសភាពការណ៍ជំងឺវាមានធ្លាប់មានជំងឺច្រើនបាទ។ មានបេះដូង មានពោះវៀន មានចង្កេះ មានឈឺចង្កេះអីច្រើន។ ដូច្នោះ ខ្ញុំសូមសម្រាករសៀលនេះ ហើយស្អែកពេញមួយស្អែក ហើយនិងបន្តធ្វើសក្ខីកម្មនៅព្រឹកចន្ទទៀតបានឬទេបាទ?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ អំមិញមានបញ្ហាបន្តិច ឃើញលោកស្រីមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន តើលោកមានបញ្ហាអីទៅ?

**កញ្ញា អង់តា ហ្គីសសេ៖**

បាទ លោកប្រធាន ខ្ញុំគ្រាន់តែចង់ដឹងថា តើសាក្សីហ្នឹងចង់មកផ្តល់សក្ខីកម្មរសៀលនេះ ឬក៏អត់? ហើយឥឡូវលោកប្រធានបានសួរបានបញ្ជាក់ហើយ អ៊ីចឹងរួចស្រេចហើយបញ្ហានេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

[១២:០៣:០៧]

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណ លោកប្រធាន។ ខ្ញុំមិនចង់និយាយឲ្យខុសប្រធានបទទេ ប៉ុន្តែក្នុងឱកាសនេះ ខ្ញុំសូមបញ្ជាក់ថា លោក នួន ជា ចង់តាមដានកិច្ចដំណើរការនីតិវិធីនៅរសៀល នៅក្នុង -- នៅបន្ទប់ខាងក្រោម ដោយសារគាត់ឈឺស្មា ឈឺខ្នង ឈឺក្បាល។ ដូច្នេះ ខ្ញុំគិតថាប្រហែលជាមិនមានបញ្ហាទេ ក្នុងការស្នើសុំបែបនេះ។ ប៉ុន្តែខ្ញុំសូមលើកឡើង ហើយខ្ញុំនឹងដាក់ជូននូវលិខិតលះបង់សិទ្ធិជូនលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ លោក សួង ស៊ីគឿន ដោយសារលោកបានបង្ហាញយ៉ាងច្បាស់លាស់អំពីបញ្ហាសុខភាពរបស់លោក ដែលបាននឹងកំពុងប្រឈមនាពេលបច្ចុប្បន្ន តាំងពីដំបូងនៃការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីស្តាប់សក្ខីកម្មរបស់លោក ហើយអង្គជំនុំជម្រះក៏បានជម្រាបជូនដំណឹងទៅភាគី និងសាធារណជន

អំពីបញ្ហាសុខភាពរបស់លោកដែរ។ ហើយនៅពេលនេះ លោកបានស្នើសុំយ៉ាងជាក់ច្បាស់ អំពីការដែលសុំសម្រាករយៈនៅរសៀលនេះ ហើយនិងនៅថ្ងៃស្អែកពេញមួយថ្ងៃទៀត ហើយលោកនឹងមានលទ្ធភាពអាចមកផ្តល់សក្ខីកម្ម បន្តការផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះនៅព្រឹកថ្ងៃចន្ទ សប្តាហ៍ក្រោយ។

[១២:០៤:៥៨]

អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោកធ្វើដូច្នេះ។ ដូច្នេះ អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគី និងសាធារណជនឲ្យជ្រាបថា នៅរសៀលនេះ ហើយនិងនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សីមួយរូបទៀតគឺលោក អ៊ុង ចុងហឿង ដែលអង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់លោក -- របស់គាត់ហ្នឹងអស់មួយរសៀលហើយ កាលពីម្សិលមិញ។

អ៊ីចឹងលោក សួង ស៊ីគឿន អង្គជំនុំជម្រះអញ្ជើញលោកមកផ្តល់សក្ខីកម្មទៀតនៅថ្ងៃចន្ទ សប្តាហ៍ក្រោយ។ គឺថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១២ ហើយសូមលោកអញ្ជើញមកឲ្យបានដល់ទីនេះ ដល់កន្លែងផ្តល់សក្ខីកម្មនេះនៅវេលាម៉ោងប្រាំបួនព្រឹក ដូចគ្នាដែរ គឺមេធាវីប្រឹក្សាសាក្សី សូមអញ្ជើញមកអមសាក្សីនៅក្នុងអំឡុងពេលដែលសាក្សីរូបនេះផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនលោក សួង ស៊ីគឿន ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់សម្រាក ដែលគាត់ស្នាក់នៅ ហើយនិងឲ្យអញ្ជើញគាត់ឲ្យមកកាន់កន្លែងផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃចន្ទ សប្តាហ៍ក្រោយនៅវេលាម៉ោងប្រាំបួន។

[១២:០៦:៣៣]

ហើយអង្គជំនុំជម្រះ មុននឹងសម្រាកគឺបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់សវនាការពេញមួយរសៀលថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាព។ អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីលោក នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្ជាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការនេះដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់របស់ជនជាប់ចោទ នួន ជា។

ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការនៅរសៀលថ្ងៃនេះ។

[១២:០៧:៤៥]

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយនៅរសៀលនេះទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍ជាស្រេចសម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ និងបង្គាប់ឲ្យនាំខ្លួនលោក ខៀវ សំផន ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៨ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:២៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នីតិវិធីសវនាការនៅរសៀលនេះ ហើយនិងនៅថ្ងៃស្អែកគឺ បន្តការស្តាប់សាក្សី អ៊ុង ចុងហឿង ហើយឥឡូវនេះគឺនឹងបន្តឡើងដោយតំណាងសហព្រះរាជអាជ្ញា។ ហើយមុននឹងផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសួរទៅសហព្រះរាជអាជ្ញា ក៏ដូចជាជម្រាបជូនសហព្រះរាជអាជ្ញាថា សហព្រះរាជអាជ្ញានិងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅមានពេលវេលាមួយថ្ងៃ។ បានន័យថា នៅរសៀលនេះ ហើយនិងបូកជាមួយនឹងស្អែកមួយព្រឹកទៀត។ ដូច្នេះ សូមបញ្ជាក់ច្បាស់លាស់អំពីបញ្ហានេះ ហើយបើអាចបង្ហាញបានគឺ គប្បីបង្ហាញអំពីការបែងចែកពេលវេលាជាមួយនឹងក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឲ្យអង្គជំនុំជម្រះងាយស្រួលក្នុងការគ្រប់គ្រងពេលវេលានេះ ហើយប្រើប្រាស់ពេលវេលាឲ្យមានប្រសិទ្ធភាព។

[១៣:៣៣:៥៦]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។ ដើម្បីបញ្ជាក់អំពីកាលវិភាគនោះ ខ្ញុំគិតថា ខ្ញុំនឹងប្រើពេលវេលាសម្រាប់រសៀលនេះ សម្រាប់សួរសំណួរទៅកាន់លោកសាក្សី ហើយនិងផ្តល់វេទិកាជូនដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ស្អែកព្រឹក។ ដូច្នេះ ខ្ញុំគិតថា ខ្ញុំនឹងអាចបញ្ចប់ការសួរសំណួររបស់ខ្ញុំនៅម៉ោងបួនរសៀលនេះ។ សូមអរគុណលោកប្រធាន។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ចំពោះពួក -- ចំពោះខាងយើងខ្ញុំនោះ ពេលវេលាមួយព្រឹកសម្រាប់សួរនោះ គឺថាគ្រប់គ្រាន់ហើយ យើងអាចត្រូវការពេលតិចជាងមួយព្រឹកផង។ សូមអរគុណលោកប្រធាន។

[១៣:៣៤:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

**ស៖** លោកសាក្សី សូមអរគុណដែលលោកបានត្រឡប់មកទីនេះ ដើម្បីឆ្លើយនឹងសំណួរ។ ហើយសូមអរគុណដែលលោកបានធ្វើដំណើរទាំងពីទីក្រុងព្រុចសែល ដើម្បីចូលរួមនៅក្នុងសវនាការនេះ ដើម្បីស្វែងរកការពិត។ ជាដំបូង ខ្ញុំមានសំណួរសួរបន្តមួយចំនួន ទៅនឹងអ្វីដែលលោកបានឆ្លើយកាលពីថ្ងៃម្សិលមិញ គឺថ្ងៃអង្គារ ជូនសហភាតារបស់ខ្ញុំ ហើយបន្ទាប់មកទៀត យើងនឹងនិយាយអំពីរឿងរ៉ាវរបស់លោកនៅប-២ ដែលលោកធ្វើការនៅឆ្នាំ៧៧នោះ។ ខ្ញុំសូមឱ្យលោកចងចាំថា អ្វីដែលយើងចាប់អារម្មណ៍នោះ គឺថាអ្វីដែលលោកដឹងនៅសម័យនោះ យើងមិនចាប់អារម្មណ៍ទៅលើអ្វីដែលលោកបានដឹងនៅពេលក្រោយដោយការធ្វើការសិក្សាទៅលើចម្លើយសារភាពនៅស-២១នោះទេ។ ដូច្នេះសូមលោកព្យាយាមបែងចែកឱ្យបានច្បាស់ គឺសុំឱ្យលោកនិយាយតែពីអ្វីដែលលោកបានស្តាប់ឮ និងបានឃើញនៅក្នុងសម័យនោះ។ សំណួរទី១ របស់ខ្ញុំគឺពាក់ព័ន្ធទៅនឹងសហភាពនិស្សិតខ្មែរ ខ្ញុំចង់ដឹងថា តើសហភាព

នោះមាននិន្នាការលម្អៀងទៅខាងសូវៀត ឬក៏ខាងចិន?

[១៣:៣៦:៣៥]

**លោក អុង ថុងហឿន៖**

**ឆ៖** ដូច -- តាមខ្ញុំដឹងដើម -- ពីដើមកំណើតសហភាពនិស្សិតខ្មែរនៅប្រទេសបារាំង មិនមាននិន្នាការដូចគណបក្សកុម្មុយនីស្តបារាំងដែរ ព្រោះកុំភ្លេចថា សហគមន៍និស្សិតខ្មែរនៅប្រទេសបារាំងកើតឡើងដោយការជ្រោមជ្រែងនៃគណបក្សកុម្មុយនីស្តបារាំង។ ដោយគណបក្សកុម្មុយនីស្តបារាំង ហើយនិងគណបក្សកុម្មុយនីស្តសូវៀតជាមានសហការជិតគ្នា យើងអាចចាត់ទុកថា សហភាពនិស្សិតខ្មែរមាននិន្នាការសូវៀត។

**ស៖** សូមអរគុណ។ តើសហភាពនេះបន្តដំណើរការរយៈពេលប៉ុន្មានចាប់ពីពេលដែលលោកជាសមាជិកនោះ គឺថានៅក្នុងអំឡុងឆ្នាំ៧០?

**ឆ៖** ថ្ងៃខែពិតប្រាកដដែលគណបក្សនោះ -- អឺ ដែលសមាគមនោះត្រូវរំលាយខ្លួន ខ្ញុំមិនចាំច្បាស់ទេ គ្រាន់តែខ្ញុំចាំច្បាស់ក្រោយពីការណែនាំរបស់លោក អៀង សារី។ ប៉ុន្តែមុននឹងៗនិយាយដល់រឿងនេះ គឺខ្ញុំចង់បញ្ជាក់បន្តិច ដើម្បីជាឲ្យយល់ គឺថា ជាពិសេសក្រោយពីមានសភាពការណ៍ មានទំនាស់មនោគមន៍វិជ្ជារវាងសហភាពសូវៀតសេរីនិយម និងបក្សកុម្មុយនីស្តសូវៀត និងបក្សកុម្មុយ-នីស្តចិន។

[១៣:៣៨:៥៤]

បញ្ហានៅក្នុងសហភាពនិស្សិតខ្មែរនៅប្រទេសបារាំង ក៏មានការប្រទាញប្រទង់គ្នាដែរ ហើយជាពិសេសពួកក្មេងៗ ជាយុវជនដែលទើបទៅដល់ប្រទេសបារាំងថ្មីៗ នៅជំនាន់នោះ ពួកនេះ ភាគច្រើនមាននិន្នាការៗចិនតាំងពីនៅក្នុងប្រទេសកម្ពុជាមក ពីព្រោះតាមខ្ញុំដឹងសមាគមនិស្សិតខ្មែរនៅប្រទេសកម្ពុជាដែលដឹកនាំដោយ ភោគ ឆាយ ពេលនោះគឺមាននិន្នាការតាមលោក ហ៊ូ នឹម គឺមានសភាពការណ៍ជិតដិតជាមួយចិនជាងសូវៀតបាទ។

**ស៖** សូមអរគុណ។ កាលពីម្សិលមិញ លោកបាននិយាយអំពីការិយាល័យបេសកកម្មរបស់ហ្វុង ឬក៏ហ្រ្គុង នៅប៉ារីស គឺថាវាជាមន្ទីរទី២ របស់ហ្វុង ដែលដឹកនាំដោយ អ៊ុក សុគន្ធ ហើយដែលបានផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានរបស់ហ្វុងនៅប៉ារីស។ តើចំពោះលោកផ្ទាល់ លោកទទួលព្រឹត្តិបត្រព័ត៌មាននេះពីហ្វុងដែរឬទេ? ឬក៏បើសិនបើមិនបានទទួលដោយផ្ទាល់ទេ តើលោកតាមមធ្យោបាយណា ដែល

លោកអាចពិគ្រោះជាមួយនឹងព្រឹត្តិបត្រនេះបាននោះ?

[១៣:៤០:៣៧]

**ឆ៖** ខ្ញុំមិន -- មិនគ្រាន់តែបានទទួលទេ ពេលខ្លះបានជួយទាញ*រ៉ូនេអូ* ទាញធ្វើ*ប៉ូឡាគាំង* ក្នុងឋានៈ ខ្ញុំជានិស្សិតចូលហ្លុងបាទ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្ទាឯល៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញជូនឯកសារមួយទៅកាន់លោកសាក្សី គឺឯកសារ IS12.3 ដែលមានលេខ E3/113។ នេះគឺជាព្រឹត្តិបត្រ ដែលមានចំណងជើងថា "ដំណឹងកម្ពុជា" មកពីទីភ្នាក់ងារព័ត៌មានកម្ពុជា ផ្សព្វផ្សាយដោយមន្ទីរព័ត៌មាន របស់រណសិរ្សរួបរួមជាតិកម្ពុជា។ ខ្ញុំគ្រាន់តែយកជាឧទាហរណ៍មួយទេ គឺច្បាប់នេះ គឺចុះលេខ៦៩៣ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ៧៤។ ដូច្នេះខ្ញុំសូមអនុញ្ញាតពីលោកប្រធានដើម្បីផ្តល់ជូនលោកសាក្សី នូវអត្ថបទជាភាសាបារាំង ដែលជាច្បាប់ដើមនៃឯកសារនេះ ហើយសូមអនុញ្ញាតបង្ហាញឯកសារនេះ នៅលើអេក្រង់ភាសាខ្មែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាស ពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនសាក្សី)*

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្ទាឯល៖**

**ស៖** លោកសាក្សី ខ្ញុំទុកពេលឲ្យលោកពិនិត្យមើលឯកសារនេះសិន។ ខ្ញុំមិនចាប់អារម្មណ៍ទៅលើខ្លឹមសារនៃអត្ថបទនេះទេ ប៉ុន្តែខ្ញុំចង់ចាប់អារម្មណ៍ ទៅលើទ្រង់ទ្រាយ។ តើលោកអាចបញ្ជាក់បានទេថា ជាព្រឹត្តិបត្របែបនេះហើយឬ ដែលលោកពិគ្រោះនៅទីក្រុងប៉ារីសជាញឹកញាប់នោះ គឺនៅពេលដែលលោកនៅទីនោះនោះ?

**លោក អុង ថុងហឿង៖**

**ឆ៖** បាទ ប្រាកដមែនហើយ។

[១៣:៤៣:០៦]

**ស៖** ប្រសិនបើលោកមើលនៅទំព័រដំបូង យើងឃើញមានប្រភេទនៃខ្លឹមសារ សូមលោកពិនិត្យមើលចំណងជើង នៃអត្ថបទនេះ គឺមានអត្ថបទទី១ គឺនិយាយអំពីជនក្បត់នៅទីក្រុងភ្នំពេញ មាននិយាយ

អំពីព្រះសង្ឃ វត្ត ហើយនិងប្រជាជននៅទីក្រុងឧដុង្គ ហើយបន្ទាប់មកមានមួយផ្នែកមួយទៀត និយាយអំពីទស្សនកិច្ចរបស់លោក អៀង សារី និង ខៀវ សំផន នៅប្រទេសចិន។ ហើយផ្នែកទី៣ នោះនិយាយអំពីសភាពការណ៍យោធានៅមូលដ្ឋាន។ តើអ្វីដែលបានបង្ហាញនេះ គឺវាដូចគ្នាទៅនឹងអ្វីដែលលោកមានទម្លាប់អាននៅក្នុងអត្ថបទបោះពុម្ពផ្សាយ របស់រណសិរ្សរួបរួមជាតិកម្ពុជា នៅសម័យនោះ ឬក៏មានសារបាប់អ្វី ដែលបាត់បង់នៅទីនេះ។ តើលោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ ខ្ញុំអាចអះអាងបានថា អត្ថបទនេះ វាមានខ្លឹមសារ ដូចអត្ថបទដែលខ្ញុំធ្លាប់បានអាននៅពេលនោះ។

**ស៖** លោកបានបញ្ជាក់ថា ការិយាល័យបេសកកម្មរបស់ហ្វ្រុង ឬហ្វុង នោះមានសកម្មភាពខ្លាំងណាស់។ តើការិយាល័យនេះ មានបោះពុម្ពផ្សាយព័ត៌មានអ្វីផ្សេងទៀតទេ ដូចជាសេចក្ដីថ្លែងការណ៍របស់រដ្ឋាភិបាល ឬក៏ព័ត៌មានទាក់ទងទៅនឹងរដ្ឋមន្ត្រីរបស់ហ្វ្រុងនោះ?

[១៣:៤៥:០៧]

**ឆ៖** ខ្ញុំដែលបាននិយាយថា បេសកកម្មហ្វុងនៅប្រទេសអឺរ៉ុប ជាបេសកកម្មសំខាន់ សឹងតែធំស្មើនឹងនៅប៉េកាំងដែរពីព្រោះថា នៅបស្ចិមប្រទេស វាមានតែនៅសកលលោកទាំងមូលមាននៅប៉ារីសទេដែលជាទីតាំងធំជាងគេ ហើយក្នុងនោះការទាក់ទងផ្សាយតាមសារព័ត៌មាន បើយើងទាក់ទងសារព័ត៌មានបរទេស សារព័ត៌មានបារាំង សារព័ត៌មានដែលធំៗនៅប្រទេសបារាំងហ្នឹង គឺថាជាវាផ្សាយពេញសកលលោក។ ដូច្នេះក្នុងន័យនេះហើយ បានខ្ញុំថានៅប៉ារីស ជាកន្លែងមួយ ជាមណ្ឌលមួយដ៏ធំបំផុតសម្រាប់ហ្វុងនៅបរទេសបាទ បន្ទាប់ពីប៉េកាំង។

**ស៖** ក្នុងព្រឹត្តិបត្រព័ត៌មានដែលលោកអាននៅសម័យនោះ ឬក៏អត្ថបទផ្សេងៗទៀតរបស់ហ្វុងតើជាការធម្មតាទេដែលយើងឃើញមានពាក្យថា ជនមហារក្សត់មុនពេលវាយកទីក្រុងភ្នំពេញបាននោះ? តើសញ្ញាណនោះធ្វើលោកឲ្យលោកនឹកឃើញអ្វីទេនៅពេលនោះ?

[១៣:៤៦:៤២]

**ឆ៖** នៅពេលនោះ ខ្ញុំមិនមែនអត់បាននឹកឃើញអ្វីទេ ពិត -- សូម្បី -- ពិតមែនតែខ្លួនខ្ញុំផ្ទាល់មិនចូលចិត្តប្រើពាក្យហិង្សាបែបនេះ ប៉ុន្តែខ្ញុំគ្មានប្រតិកម្មប្រឆាំងទេបាទ។

**ស៖** ឥឡូវនេះ ខ្ញុំចង់សង្កត់ធ្ងន់ទៅលើកិច្ចប្រជុំ ដែលលោកបានចូលរួមនៅពេលលោក អៀង សារី ធ្វើដំណើរទៅទីក្រុងប៉ារីស ជាមួយនឹងសហគមន៍និស្សិតខ្មែរនៅទីនោះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតដើម្បីអានឃ្លាមួយ នៃកំណត់ហេតុស្តាប់ចម្លើយលោកសាក្សីរូបនេះ ហើយបន្ទាប់មកខ្ញុំនឹងសួរសំណួរទៅកាន់គាត់។ កំណត់ហេតុនេះគឺមានលេខ D141/1 ឬក៏ E3/97 ជាភាសាបារាំងទំព័រ៤, ជាភាសាអង់គ្លេសទំព័រ៤ ដូចគ្នា, ជាភាសាខ្មែរទំព័រ ៦-៧។ ខ្ញុំសូមការអនុញ្ញាតបង្ហាញជូននៅលើអេក្រង់។ ហើយខ្ញុំសូមសួរលោកសាក្សីថា ចង់បានជាភាសាខ្មែរ ឬក៏ជាភាសាបារាំង?

**លោក អុង ថុងហឿង៖**

បាទ សូមជាភាសាបារាំងបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាស ពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

[១៣:៤៨:៥២]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ទំព័រជាភាសាខ្មែរ គឺទំព័រទី៦-៧។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំសូមអានសម្រង់ នៃកំណត់ហេតុស្តាប់ចម្លើយនេះ ខ្ញុំសូមដកស្រង់ "អៀង សារី ព្រមទាំងគណៈប្រតិភូបានមកទីក្រុងប៉ារីសជាច្រើនដង។ ឧទាហរណ៍ដូចជាឈានចូលមក ដើម្បីចូលរួមសន្និសីទនៃប្រទេសមិនចូលបក្សសម្ព័ន្ធ ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងការបរទេស។ ដូចជាមនុស្សទូទៅដែរ ពួកខ្ញុំត្រូវបានគេប្រាប់ដឹង ហើយក៏បានចូលទៅស្តាប់គាត់ថ្លែងការណ៍ដែរ។ សុន្ទរកថារបស់គាត់ គឺដដែលៗ និយាយពីការជួយកាន់ជើងប្រទេស ហើយថាអ្វីៗទាំងអស់កំពុងដំណើរការល្អ។ ជីវភាពរស់នៅបានជាទីគាប់ចិត្ត"។ បន្ទាប់មកពីរឃ្លាទៅខាងមុខទៀត ខ្ញុំសូមដកស្រង់៖ "ខ្ញុំដឹងថា អៀង សារី បានថ្លែងសុន្ទរកថានៅឯមហាសន្និបាតនៃអង្គការសហប្រជាជាតិ ជាទីដែលគាត់បានបង្ហាញប្រាប់ថាប្រទេសរបស់គាត់មិនដែលធ្លាប់មានវិបុលសុខ និងសុខសប្បាយដូចនេះទេ តាំងពី២០០០ឆ្នាំមកម្ល៉េះ"។ លោកៗសាក្សី ខ្ញុំចង់ឲ្យលោកបំភ្លឺចំណុចមួយចំនួន លោកថា អៀង សារី ទៅប៉ារីសជាច្រើនដង។ ក៏ប៉ុន្តែចំពោះលោកផ្ទាល់នោះ តើលោកបានឃើញគាត់ ហើយនិងស្តាប់គាត់ប៉ុន្មានដងនៅក្នុងកិច្ចប្រជុំ

ជាមួយនឹងបញ្ញាជននៅបារាំងនោះ តើម្ដង ឬក៏ច្រើនដង ឬក៏លើសពីពីរដង?

[១៣:៥០:៤៣]

**ឆ៖** ខ្ញុំអាចថាលើសពីពីរ ឬបីដងបាទ។

**ស៖** តើវាកើតឡើងក្រោយពីជ័យជម្នះថ្ងៃទី១៧ មេសា នៅពេលដែលគាត់ជារដ្ឋមន្ត្រីក្រសួងការបរទេសរួចមកហើយ ឬក៏មុនពេលទទួលជ័យជម្នះ?

**ឆ៖** មុនពេលជ័យជម្នះក៏ខ្ញុំបានជួប ក្រោយជ័យជម្នះក៏ខ្ញុំបានជួបយ៉ាងតិចម្ដង។ ខ្ញុំមិនបានជួបផ្ទាល់ទេ ប៉ុន្តែជួបក្នុងពេលមីទ្ទីងបាទ។

**ស៖** បន្ទាប់ពីជ័យជម្នះដែលលោកថា បានឃើញយ៉ាងហោចណាស់ម្ដងនោះ តើគេទទួលគាត់ក្នុងឋានៈជាវីរជននៃបដិវត្តន៍មែនទេ?

**ឆ៖** ខ្ញុំចាំថា គេទទួលគាត់ក្នុងឋានៈជា -- មិនមែនជាវីរជនទេ គេប្រើធំជាងនេះ ក្នុងឋានៈជា *ហេរ៉ូ* ជាមគ្គុទ្ទេសក៏មួយដ៏ៗឆ្នើមបាទ។

**ស៖** តើគាត់មានកិត្យានុភាពយ៉ាងខ្លាំងចំពោះសហគមន៍ខ្មែរនៅប៉ារីស ដូចជាប្រជាជន ឬក៏និស្សិត ឬក៏បញ្ញវន្តនៅទីនោះមែនទេ?

[១៣:៥៤:០៤]

**ឆ៖** ពេលនោះមែនបាទ គឺគាត់មានឥទ្ធិពលខ្លាំងលើបញ្ញវន្ត និងនិស្សិតនៅប្រទេសបារាំង ដោយសារ ទី១ ដោយសារគាត់មានស្គាល់មិត្តភក្តិជំនាន់គាត់ ធ្វើការនៅទីនោះ ជាស្នូលរបស់គាត់ ហើយដោយសារពួកចាស់ៗហ្នឹងអប់រំពួកក្មេងៗដូចពួកខ្ញុំបាទនេះ ឲ្យគាំទ្រគាត់បាទ។

**ស៖** កាលពីម្សិលមិញលោកបានរៀបរាប់អំពីឈ្មោះ អ៊ិន សុភាព ហើយនិង សួង ស៊ីគឿន ជាអ្នកដែលនៅជិតស្និទ្ធនឹងគាត់។ តើលោកមានបានឃើញសហការី ឬក៏បុគ្គលផ្សេងទៀតដែលនៅជុំវិញគាត់ អមដំណើរគាត់ ជាពិសេសនៅពេលដែលមានទស្សនកិច្ចក្រោយថ្ងៃទី១៧ មេសា? ខ្ញុំចង់សំដៅដល់លោក សួរ ហុង ជាពិសេស តើលោក សួរ ហុង ពេលនោះគាត់មានទៅតាមលោក អៀង សារី ទេ?

**ឆ៖** បាទ ក្នុងចំណោមអ្នកដែលជូនដំណើរលោក អៀង សារី ខ្ញុំចាប់អារម្មណ៍ សួរ ហុង ជាងគេ ពីព្រោះខ្ញុំផ្ទាល់បានជួបគាត់ ហើយបាននិយាយពិភាក្សាជាមួយគាត់ ហើយខ្ញុំសំណេះសំណាលជាមួយគាត់ ពីព្រោះគាត់ជាមជ្ឈដ្ឋានមនុស្សម្នាក់ដែលចេញពីក្នុងប្រទេស ហើយដែលខ្លួនខ្ញុំដាច់ឆ្ងាយពីប្រទេសជាតិជាង១០ឆ្នាំហើយ ឃើញថាវាដូចជាភ្ជាប់សាច់ភ្ជាប់ឈាមជាមួយបងប្អូនយើងនៅក្នុង

ប្រទេស។ ដូច្នេះ សួរ ហុង នេះមាន -- ខ្ញុំចាប់អារម្មណ៍ឈ្មោះគាត់ហ្នឹងជាងគេបាទ។

[១៣:៥៥:០៥]

**ស៖** នៅពេលជួបគ្នានោះ ដើម្បីបញ្ចុះបញ្ចូលអ្នកតស៊ូឲ្យចូលមកប្រទេស តើលោក អៀង សារី មានប្រើពាក្យថា "ស្នេហាជាតិ" "ជាតិនិយម" ដើម្បីបញ្ចុះបញ្ចូលពួកគេឲ្យមកកសាងប្រទេសដែរឬទេ? ឬក៏គាត់ប្រើពាក្យអ្វីផ្សេងខ្លះទៀត ដើម្បីបញ្ចុះបញ្ចូលអ្នកទាំងនោះ ឲ្យត្រឡប់មកជួយកសាងជាតិនោះ?

**ឆ៖** គាត់ច្រើនពាក្យ "ព្រលឹងជាតិ ស្នេហាជាតិ ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន" ហើយគាត់ចង់និយាយបញ្ជាក់ហើយបញ្ជាក់ទៀតថា ប្រទេសកម្ពុជា មិនមែនជាវណាបរបស់វៀតណាមទេ។ ហើយពាក្យថាដែលមិនមែនជាវណាបវៀតណាមនេះ គឺខ្មែរគ្រប់ប្រទេសទាំងអស់ គ្រប់មជ្ឈដ្ឋានទាំងអស់ ចូលចិត្តស្តាប់ណាស់បាទ។

**ស៖** តើគាត់មានប្រាប់លោកអំពីការលំបាកដែលប្រទេសកំពុងតែជួបប្រទះ ក្រោយការរំដោះទីក្រុងភ្នំពេញ នារយៈពេលប៉ុន្មានក្រោយពេលរំដោះនោះ? ឧទាហរណ៍ ដូចជា គាត់មានប្រាប់លោកថា មានសភាពការណ៍លំបាកលំបិនអ្វីទេ?

[១៣:៥៦:៤៥]

**ឆ៖** គាត់មិនដែលនិយាយពីបញ្ហានេះដោយ តាមខ្ញុំចាំដូចជាអត់ទេ ប៉ុន្តែគាត់តែងតែយកឧទាហរណ៍ដូចអ្នកចូលស្រុកៗមុន ដូចជា សួង ស៊ីគឿន, អ៊ិន សុភាព ជាដើម ថាគេកំពុងតែសប្បាយនៅក្នុងតស៊ូជាមួយបងប្អូនអ៊ីចឹង ធ្វើឲ្យពួកខ្ញុំនៅណោះ គឺមានសតិអារម្មណ៍ធ្វើម៉េចបានចូលស្រុកកាន់តែឆាប់ឡើង ដើម្បីធ្វើដូចពួក អ៊ិន សុភាព ឬ សួង ស៊ីគឿន បាទ។

**ស៖** តើលោក អៀង សារី ឬក៏អ្នកជិតស្និទ្ធនឹង អៀង សារី នៅក្នុងកិច្ចប្រជុំនោះ មាននិយាយថា ក្នុងឋានៈជាបញ្ញាជននៅបរទេសនោះ ពេលត្រឡប់មកប្រទេសវិញនោះ ត្រូវតែឆ្លងកាត់ការហាត់ពត់លត់ដំកសាងខ្លួនទេ?

**ឆ៖** យើង -- ខ្ញុំមិន -- ខ្ញុំដឹងថា គាត់ៗ បាននិយាយថា យើងត្រូវហាត់លត់ដំការកសាងខ្លួន ប៉ុន្តែជា -- យើងមិនដឹងថាកសាងខ្លួននោះ ដោយអត់បាយ ដោយធ្វើការពលកម្ម ដូចយើងមកជាក់ស្តែងទេ យើងៗមិនស្មានអ៊ីចឹងបាទ។ អង្កាល់នោះ ខ្ញុំអត់ចាប់អារម្មណ៍អ៊ីចឹង ប៉ុន្តែថាមកកសាងខ្លួន ឲ្យលត់ដំខ្លួន ឲ្យប្រជាជន រស់នៅដូចប្រជាជន អាហ្នឹងបាន គាត់បាននិយាយបាទ។

**ស៖** តើអំពាវនាវដដែលៗរបស់លោក អៀង សារី នៅក្នុងពេលប្រជុំទាំងនោះ ក្រោយថ្ងៃ១៧

មេសា ៧៥ ឲ្យត្រឡប់ចូលមកប្រទេសវិញនោះ ថាមានឥទ្ធិពលទៅលើសហគមន៍និស្សិត ឬក៏បញ្ញាជននៅទីក្រុងប៉ារីសដែរឬទេ?

[១៣:៥៩:០៩]

**ឆ៖** វាមានឥទ្ធិពលខ្លាំងណាស់ ពីព្រោះខ្មែរយើងពេលនោះ អ្នកខ្លះមានគ្រួសារបារាំង មានកូនសុខចិត្តលក់ផ្ទះ សុខចិត្តយកលុយរាប់ម៉ឺនរាប់ គឺថាយកលុយ លះបង់ អ្នកខ្លះលះបង់ទាំងប្រពន្ធកូន ទុកកូនដើម្បីចូល ហើយលក់ផ្ទះរបស់ខ្លួន យកលុយមកជូន ដើម្បីជួយជាតិ កសាងជាតិ ហើយមកចូលរួបរួមជាតិ ជាមួយបងប្អូននៅកម្ពុជា។

**ស៖** តើលោកអាចផ្តល់ឈ្មោះមិត្តភក្តិរបស់លោក ឬក៏អ្នកដែលបានចូលរួមនៅក្នុងកិច្ចប្រជុំនោះ ហើយបន្ទាប់មកបានសម្រេចចិត្តថាត្រឡប់ចូលមកប្រទេសវិញនោះ នៅពេលដែលប្រជុំជាមួយនឹង អៀង សារី ហើយនោះ?

**ឆ៖** ខ្ញុំមិនអាចរៀបរាប់ឈ្មោះបានទាំងអស់ទេ ប៉ុន្តែខ្ញុំចាំដូចជាលោក ទីវ ឈុនឡេង ខ្ញុំចាំជាងគេ ពីព្រោះគាត់ជាវិស្វករហើយលោក អៀង សារី បានប្រាប់គាត់ថាដូចថាគាត់ត្រូវការ ទីវ ឈុនឡេង ហើយដោយ ទីវ ឈុនឡេង ហ្នឹងគាត់ជាវិស្វករ ហើយៗគាត់មាន -- គេទទួលស្គាល់គាត់នៅប្រទេសបារាំង ហើយគាត់មានគ្រួសារបារាំង គាត់មានជីវភាពធូរធារមែនទែន ហើយគាត់មានកូនប្រុសមួយ ហើយ ទីវ ឈុនឡេង ត្រូវការគាត់ឲ្យមកជួយធ្វើតាមគាត់ប្រាប់ខ្ញុំ គឺ ទីវ ឈុនឡេង ពេលនោះគឺគាត់ស្ម័គ្រចិត្តមកដោយចោលប្រពន្ធគាត់នៅណោះ ពីព្រោះ ហើយកូនគាត់ ព្រោះគាត់ចង់ធ្វើ -- តាមខ្ញុំភ្លាប់បានពេលនោះថាធ្វើផ្លូវរថទេះភ្លើងពីភ្នំពេញទៅៗព្រំប្រទល់ដែនលាវ ដែលខ្ញុំចាំបាន ហើយគាត់ក៏មកស្រុកទៅ។

[១៤:០១:០៩]

ហើយមួយទៀតដូចជា លី ណៃស៊ីម, ប៉ែន ទ្រីវ៉ាន់ គាត់មាន -- គាត់ចោលម្តាយគាត់នៅណោះ ហើយ ប៉ែន ទ្រីវ៉ាន់ គាត់គឺជាវិស្វករដែរ។ ហើយគាត់ លី ណៃស៊ីម គាត់ជាពេទ្យ ហើយគាត់ក៏លះបង់គាត់យកកូនគាត់មួយមក កូនហ្នឹងនៅតូចទេគាត់មក ហើយគាត់ឲ្យលក់ផ្ទះហ្នឹងឲ្យៗផ្ទះហ្នឹងជូនទៅលុយហ្នឹងទៅអង្គការហ្នឹង ហើយគាត់ចូលមក។ អាហ្នឹង មានច្រើនតទៅទៀតបាទៗ របៀបហ្នឹង។ ហើយទាំងអស់ហ្នឹងស្លាប់អស់ហើយបាទ។

**ស៖** សូមអរគុណលោកសាក្សី។ នៅចន្លោះពេលរំដោះភ្នំពេញ ហើយនិងពេលដែលលោក

ត្រឡប់ចូលមកកម្ពុជាវិញ។ តើលោកដឹងទេនៅសម័យនោះថា មានប្រហែល -- មានខ្មែរប្រហែលប៉ុន្មាននាក់នៅបរទេសដែលបានត្រឡប់មកប្រទេសកម្ពុជាវិញ ដើម្បីកសាងជាតិនោះ?

**ប្រធានអង្គជំនុំ៖**

អត់ទាន់ៗមាន។

[១៤:០២:៣៤]

**លោក អុង ហុងហឿង៖**

**ឆ៖** តាមការស្មាន សូមទោសមិនមែនស្មានទេ។ តាមការស្រាវជ្រាវរបស់ខ្ញុំដែលហើយ តាមការដឹងរបស់ខ្ញុំសម័យនោះ គឺ -- ហើយតាមរយៈឯកសារមួយចំនួនរបស់ *អេកូហ្វ្រង់សេ ដិចស្ត្រែម អូរីយ៉ង់* ដែលខ្ញុំអាចចាត់ទុកថាខ្មែរចូលស្រុកអង្កាល់នោះមានមួយពាន់ -- ប្រហែល១.៧០០នាក់ ហើយនៅរស់ ១៥០០នាក់ អ៎! នៅរស់២០០នាក់ ស្លាប់១.៥០០នាក់។ ហើយឈ្មោះអ្នកស្លាប់ ខ្ញុំបានស្រង់មួយចំនួន។ អានេះដែលឈ្មោះខ្ញុំបានឃើញនៅក្នុងសៀវភៅដែលខ្ញុំបានសរសេរបាទ។

[១៤:០៣:៤៦]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកអ្វីដែលលោកបាននិយាយកាលពីម្សិលមិញ លោកបានបញ្ជាក់ថា អៀង សារី មុនពេលលោកមកចូលមកវិញ នៅពេលជិតដល់មហាសន្និបាតអង្គការសហប្រជាជាតិ គាត់បានផ្តល់សន្និសីទកាសែតមួយ ហើយគាត់បាននិយាយថាអ្នកជម្លៀសចេញពីភ្នំពេញហ្នឹង នឹងត្រឡប់ចូលមកទីក្រុងវិញ។ តើការថ្លែងការណ៍ ឬក៏ការនិយាយបែបនេះ វាចូលរួមចំណែកក្នុងការធានាលោក ឲ្យដឹងអំពីស្ថានភាព ឬក៏សភាពការណ៍ដែលកើតមាននៅប្រទេសនៅពេលនោះទេ?

**ឆ៖** បាទ ពាក្យអស់ទាំងនេះ វាធ្វើ លើកទឹកចិត្តខ្ញុំឲ្យជឿថា បងៗដែលតស៊ូនៅលើសមរភូមិនៅលើ -- នៅក្នុងស្រុកហ្នឹង គឺមិនមែនជាមនុស្សល្ងង់ អត់រៀនសូត្រអីទេ គឺអ្នកចេះដឹង។ ដូច្នេះគាត់មិនអាចធ្វើអ្វីព្រៃផ្សៃសម្លាប់ជាតិឯងទេបាទ។

[១៤:០៥:១៩]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំចង់បង្ហាញឯកសារមួយទៀត គឺថាឯកសារ E3/550 ដែលមានលេខ IS20.4 គឺជាសម្រង់ -- កិច្ចសម្ភាសន៍របស់លោក អៀង សារី ជាមួយនឹងលោក -- កាសែត ញូវស៍វីក ថ្ងៃទី៨

កញ្ញា ឆ្នាំ១៩៧៥ ហើយទំព័រដែលយើងចាប់អារម្មណ៍ ជាភាសាខ្មែរហ្នឹងគឺថាទំព័រទី២ ភាសាអង់គ្លេស ទំព័រទី១ ភាសាបារាំងទំព័រទី២ដែរ។ បាទ ខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារចម្លងជាភាសាបារាំងទៅលោកសាក្សី ហើយនិងសូមបញ្ចាំងជាភាសាខ្មែរនៅលើអេក្រង់ ដែលជាឯកសារបកប្រែលោកប្រធាន។ សូមការអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** បាទ នេះគឺជាចម្លើយរបស់លោក អៀង សារី ដែលគាត់ឆ្លើយទៅអ្នកកាសែត ចេមស៍ ស៊ីងហ្គើល របស់កាសែតញូវស៍វីក។ សំណួរដូចតទៅនេះ ៖ “តើភ្នំពេញនៅតែគ្មានមនុស្សនៅឬ? ចម្លើយ៖ ទេ មានប្រជាជនប្រហែល ១សែននាក់បានវិលត្រឡប់ចូលមកវិញ ហើយប្រជាជនផ្សេងទៀតកំពុងតែវិលចូលមកភ្នំពេញជាបណ្តើរៗ សាលារៀន មន្ទីរពេទ្យ រោងចក្របានចាប់ផ្តើមបើកទ្វារ និងធ្វើសកម្មភាពវិញជាបណ្តើរៗហើយ ប្រជាជនអាចវិលត្រឡប់ចូលមកប្រទេសវិញបាន ប្រសិនបើពួកគេចង់ ឬក៏ពួកគេចង់ស្នាក់នៅជនបទ។ ប្រជាជនយើងធ្វើការទាំងយប់ទាំងថ្ងៃ ដើម្បីកសាងប្រទេសឡើងវិញ។ ប្រទេសកម្ពុជាដូចជា រោងចក្រ -- ជារោងជាងដ៏ធំមួយ”។ សូមបញ្ចប់ការដកស្រង់។

[១៤:០៧:២៤]

អ្វីដែលលោកបាននិយាយកាលពីម្សិលមិញនេះ ទាក់ទងទៅនឹងការដែលថា អ្នកដែលជម្លៀសហ្នឹងកំពុងតែត្រឡប់ចូលទីក្រុងភ្នំពេញវិញហើយ តើវគ្គសម្អាសនេះគឺ វាដូចអ្វីដែលលោកបានឮ លោក អៀង សារី និយាយទាក់ទងនឹងការត្រឡប់មកវិញនៃមនុស្សដែលគេជម្លៀសនេះដែរឬទេ?

**ឆ៖** បាទនេះជាអត្ថបទដែលខ្ញុំបានអាន ហើយខ្ញុំ ដែលៗខ្ញុំបាននិយាយ គឺខ្ញុំឈរលើអត្ថបទហ្នឹងបាទ។

**ស៖** បាទ សូមអរគុណ។ ពេលចេញដំណើររបស់លោក -- ខ្ញុំសូមត្រឡប់មកនិយាយអំពីសៀវភៅរបស់លោកវិញ គឺថាសៀវភៅដែលមានលេខD141/1.2 លោកបាននិយាយនៅទំព័រ៣១-៣២ ជាភាសាបារាំង ហើយនិងជាភាសាខ្មែរគឺ 00831090 ដល់ 91។ លោកនិយាយថា លោកនឹងចេញមក

ពីប៉ារីសមកប្រទេសកម្ពុជា ហើយក្រុមរបស់លោកបានចុះហត្ថលេខាសេចក្ដីប្រកាសសារព័ត៌មានមួយ។ សួរថាតើអ្នកណា ជាអ្នកសរសេរសេចក្ដីប្រកាសនេះ?

[១៤:០៩:១៨]

**ឆ៖** ខ្ញុំបាទអត់បានដឹងទេកាលនោះ អត់ដឹងទេ ប៉ុន្តែគ្រាន់ដឹងថាអ្នកជិតស្និទ្ធជាមួយ អៀង សារី ប៉ុន្តែខ្ញុំអត់បានដឹងជាអ្នកណាពិតប្រាកដទេបាទ។

**ស៖** ហើយសេចក្ដីប្រកាសនេះមានខ្លឹមសារយ៉ាងម៉េច នៅពេលដែលលោកធ្វើសេចក្ដីប្រកាសនេះ មុនពេលដែលលោកចេញពីប្រទេសបារាំងមកប្រទេសខ្មែរនេះបន្តិចនោះ?

**ឆ៖** សេចក្ដីប្រកាសនេះមានខ្លឹមសារ គឺថា ពួកយើងខ្ញុំដែលចូលមកប្រទេសនេះ គឺចូលទី១ ដោយស្ម័គ្រចិត្ត។ ទី២ គឺដោយស្ម័គ្រចិត្តដោយសារអី ដោយសារសភាពការណ៍ជាក់ស្ដែងនៅក្នុងប្រទេស វាមិនមែនខ្មៅងងឹត ព្រៃផ្សៃដូចសារព័ត៌មានចក្រពត្តិនិយមបរទេសចេះតែថានោះទេ។ ដូច្នេះ វាមានខ្លឹមសារអ៊ីចឹងបាទ។

**ស៖** ហើយនៅសម័យនោះ សារព័ត៌មានរបស់ចក្រពត្តិនុ៎ងគេនិយាយអ្វីខ្លះទាក់ទងនឹងស្ថានភាពរបស់ប្រទេសកម្ពុជា។ តើមានការចោទប្រកាន់លើរបបខ្មែរក្រហមដែរឬទេ នៅសម័យនោះ?

**ឆ៖** ចាប់មានការផ្ដន្ទាទោសលើរបប លើអំពើព្រៃផ្សៃរបស់ខ្មែរក្រហម ជាពិសេសដោយមានខ្មែររត់ចេញពីប្រទេស ហើយកាសែត សារព័ត៌មានបារាំងក្ដី សារព័ត៌មានអង់គ្លេសាក់ស្សុងក្ដី បានចាប់និយាយពីការ អំពើព្រៃផ្សៃនៅក្នុងប្រទេសកម្ពុជា ហើយព័ត៌មានដែលខ្លាំងជាងគេគឺបន្ទាប់ពី ពេល ហ្វ្រង់ស្វ័រ ប៉ង់សូ គាត់បានចេញសៀវភៅមួយ "កម្ពុជា ឆ្នាំសឺរ៉ូ -- ឆ្នាំសូន្យ"បាទ។

[១៤:១១:៥០]

**ស៖** មុននឹងវេចបង្វេចមកប្រទេសខ្មែរ តើលោកបានទទួលដំបូន្មានថា ត្រូវយកអ្វីមកប្រទេសខ្មែរ ឬក៏មិនត្រូវយកមកប្រទេសខ្មែរដែរឬទេ?

**ឆ៖** ដំបូន្មានមានធំគឺថា ឲ្យយកតែបង្វេចមួយបង្វេចមកបានហើយ កុំយកអ្វីទាំងអស់មក ព្រោះថា មកនេះគឺថា បើយកអីច្រើនពេកនាំតែធ្ងន់ ព្រោះយើងមកនេះមកដើម្បីកសាងខ្លួនជាមួយប្រជាជនកម្ពុជា។

**ស៖** តើដោយប្រយោល ឬក៏ដោយផ្ទាល់ អៀង សារី ហ្នឹងបានសូមឲ្យលោកធ្វើអ្វីមួយមកប្រទេសកម្ពុជាដែរឬទេ?

**ឆ៖** ដោយប្រយោល ខ្ញុំ -- ពួកខ្ញុំមកហ្នឹងមានបានទទួលឯកសារពីគណៈប្រតិភូ ពីបេសកកម្មខ្មែរនៅ បេសកកម្ម ហ្នុង នៅប៉ារីស ប៉ុន្តែខ្ញុំមិនដឹងៗជាខ្លឹមសារយ៉ាងម៉េចទេ។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំត្រឡប់មកនិយាយអំពី ក-១៥ វិញ ដើម្បីចោទសំណួរពីរបីទៀត ទៅលើសំណួរដែលគេចោទសួរទៅលោកកាលពីម្សិលមិញហើយ ហើយ។ លោកបាននិយាយថា លោកដាំបន្លែនៅ ក-១៥ តើគេមានបានប្រាប់គាត់ថា បន្លែទាំងអស់នេះពេលដាំហើយហ្នឹងយកទៅឲ្យអ្នកណាដែរឬទេ?

[១៤:១៤:១០]

**ឆ៖** ជារួមគេ ដូចជាមិនប្រាប់ថា យកទៅឲ្យអ្នកណាទេ ប៉ុន្តែបញ្ហាធំកន្លែងនីមួយៗត្រូវបណ្តុះបណ្តាលភោគផល ដើម្បីៗគ្រប់គ្រាន់ ឲ្យបានគ្រប់គ្រាន់ខ្លួនឯងបាទ។

**ស៖** នៅក-១៥ លោកបានមកដល់ទីនុ៎ង គឺពីរបីខែក្រោយប្រពន្ធគាត់ -- អ៊ំ ប្រពន្ធលោក ហើយនិងអ្នកផ្សេងទៀតដែលមកដល់ប្រទេសខ្មែរមុនលោក តើអ្នកបញ្ញវន្តផ្សេងទៀតនោះ ក្នុងរយៈពេល៣ខែដែលលោកស្នាក់នៅទីនុ៎ង នៅតែបន្តមក ក-៥(ស៊ីក) ដែរ ហើយមកនៅ -- មកស្នាក់នៅទីហ្នឹងទៀតឬក៏យ៉ាងម៉េច ឬក៏អត់មានអ្នកណាមកទៀតទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ខ្ញុំ -- កាលខ្ញុំធ្វើដែលជាមួយអ្នកតំណាងតុលាការ ខ្ញុំបាននិយាយថា៣ខែ ប៉ុន្តែជាក់ស្តែងខ្ញុំមក៦ខែក្រោយ។ ប្រពន្ធខ្ញុំមកខែ១ ខ្ញុំមកខែ៧។ ដូច្នេះ៦ខែ។ ហើយដែលជាក់ស្តែងទៅខ្ញុំមក៦ខែក្រោយហ្នឹង គឺថាតាមខ្ញុំដឹងគឺថាមាន -- ដល់ពេលខ្ញុំមកដល់ គេយកខ្មែរមួយចំនួនធំទៅនៅជំរំមួយទៀត ហៅថា ជំរំតាឡី។ តាឡីហ្នឹង ខ្ញុំមិនដែលទៅទេ។ មិនដឹងឯណាច្បាស់លាស់ ប៉ុន្តែគេថាប្រហែលជានៅខាងត្បូងក្រុងភ្នំពេញ។ ហើយក្រៅពីហ្នឹង គេយកមនុស្សចំនួនទៀត ដូចជាយោធា ដូចអីអ៊ីចឹង យកទៅ -- ក្រោយមកខ្ញុំឃើញឈ្មោះហ្នឹងនៅទួលស្លែង។

[១៤:១៦:២០]

**ស៖** លោកសាក្សី ខ្ញុំមិនសូវច្បាស់អម្បាញ់មិញនេះ ខ្ញុំចង់ដឹងថាតើអ្នកបញ្ញវន្តផ្សេងទៀតនោះនៅតែបន្តមកក្រោយលោកដែរឬទេ គឺថាពេលដែលចេញពីព្រលានយន្តហោះមកហ្នឹង ហើយសួរថាតើគាត់ហ្នឹងទៅ ក-១៥ដែរឬទេ? តើបញ្ញាជនទាំងអស់ហ្នឹងមក ក-៥(ស៊ីក) ហ្នឹង ជាច្រើនក្រុមដែរឬទេដែលនៅកន្លែងក-៥ (ស៊ីក) ដែលលោកនៅទីនោះស្រាប់ហើយនោះ?

**ឆ៖** បាទ--

**ប្រធានអង្គជំនុំ៖**

ឈប់សិន! ក-៥ ឬក៏ ក-១៥?

អ្នកបកប្រែម្ដង ក-៥ ម្ដង ក-១៥ អាចមានការមិនច្បាស់លាស់។ សូមបញ្ជាក់ម្ដងទៀត ក-១៥ ឬក៏ ក-៥? ភាសាខ្មែរ?

លោកតំណាងសហព្រះរាជអាជ្ញាតាំងសំណួរអម្បាញ់មិញម្ដងទៀត ពីព្រោះមានការបកប្រែអាចច្រឡំគ្នារវាងការប្រើពាក្យម្ដងថា ក-៥ ម្ដងថា ក-១៥។ មួយណាដែលត្រឹមត្រូវ? ដើម្បីឲ្យសាក្សីហ្នឹងស្ដាប់ឲ្យបានន្ធូវអង្គហេតុដែលពាក់ព័ន្ធនឹងសំណួរដែលគាត់អាចឆ្លើយតបដោយត្រឹមត្រូវទៅនឹងសំណួរដែលសួរ។

[១៤:១៧:៥៧]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាងលេ៖**

បាទ សូមអរគុណលោកប្រធាន គឺ ក-១៥ មិនមែន ក-៥ទេ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាងលេ៖**

**ស៖** បាទ សំណួរខ្ញុំអម្បាញ់មិញហ្នឹង គឺចង់ដឹងថា តើមានក្រុមបញ្ញាជនត្រឡប់មកពីបរទេស គឺថាទោះបីជាប្រទេសបារាំង ឬក៏ទីកន្លែងផ្សេងទៀតក៏ដោយ មកមន្ទីរ ក-១៥នេះ នៅពេលដែលលោកសាក្សីហ្នឹងនៅទីនោះស្រាប់ហើយ?

**លោក អ៊ុង ចុងហៀង៖**

**ឆ៖** បាទ មានបន្តទៅទៀត ហើយចំពោះខ្ញុំរួបខ្ញុំផ្ទាល់ ហើយនិងរូបភរិយាខ្ញុំ គឺមានជាអាទិ៍គឺបងថ្លៃខ្ញុំ រស់ សារិន ព្រមទាំងគ្រួសារ និងកូនចៅគាត់ បាទ និងខ្មែរមួយចំនួនទៀត។

**ស៖** ទាក់ទងនឹងការរៀបចំមន្ទីរ ក-១៥ នេះ ហើយនិងកន្លែងផ្សេងទៀតដែលលោកត្រូវបានគេបញ្ជូនទៅនៅពេលក្រោយ តើកម្មាភិបាលខ្មែរក្រហមប្រើវិធី ប្រើវិធីគឺថាដាក់ឈ្មោះអ្នកធ្វើការ ឬក៏អ្នកឃុំឃាំងខ្លួនដើម្បីឲ្យគ្រប់គ្រងលើអ្នកផ្សេងទៀត តើគេមានធ្វើយ៉ាងដូច្នេះទេ គឺថាចាត់តាំងអ្នកណាម្នាក់អ៊ីចឹងទៅ ដើម្បីឲ្យគ្រប់គ្រងលើអ្នកដែលគេឃុំឃាំងផ្សេងទៀតនោះ ឬក៏បញ្ញវន្តផ្សេងទៀត?

**ឆ៖** បាទ នៅដូចជា នៅក-១៥ អ៊ីចឹង មានភុំ ហើយនិងគ្នាគាត់ពីរបី -- បួនប្រាំនាក់ ឬក៏ខ្ញុំមិនច្បាស់ទេ។ អ៊ីចឹងទៅគេត្រួតពីលើ។ ហើយក្នុងហ្នឹងគេចាត់តាំងខ្មែរ ដែលមកពីបរទេសដូចគ្នាហ្នឹងធ្វើជាប្រធាន ឬក៏ធ្វើជាមេក្រុម ដើម្បីត្រួតគ្នាឯងដូចជាពួកអាល្លឺម៉ង់ ធ្វើជាមួយពួកជ្វីហ្វដូចគ្នា ប៉ុន្តែគេ

ចាត់តាំងឲ្យធ្វើជាមេក្រុម ឬប្រធាន ឬក៏ស្អី ដើម្បីត្រួតគ្នាឯង ហើយរាយការណ៍ប្រាប់គេបាទ។

[១៤:២០:២៥]

**ស៖** តើការធ្វើបែបនេះ នោះគឺថាបង្កឲ្យមានសម្ពាធទៅដល់ក្រុមបញ្ញាជន ដែលត្រឡប់មកពីបរទេសវិញដែរឬទេ នៅពេលដែលមានការចាត់តាំងប្រធានក្រុម ហើយនិង -- បើសិនជាខ្ញុំមិនច្រឡំទេ គឺថាការដែលមានវគ្គប្រជុំទិតៀន ស្វ័យទិតៀនហ្នឹង តើការទាំងអស់នេះបង្កឲ្យមានសម្ពាធដែរឬទេ? ភាពតឹងតែងដែរឬទេ?

**ឆ៖** ការធ្វើបែបនេះ ដូចយើងដឹងស្រាប់ហើយ បើឧបមាថា នៅកន្លែងហ្នឹង កន្លែងឥឡូវយើងកំពុងជួបគ្នាហ្នឹង ស្រាប់ពីណាមួយគេបិទទ្វារយើង ហើយយើងអត់មានទឹក មានស្អីទាំងអស់នៅហ្នឹង ហើយចាត់តាំងយើងឲ្យធ្វើដើម្បីត្រួតគ្នានៅហ្នឹងទៅ ហើយអត់មានការទាក់ទងពីកន្លែងណាមកទៀត យើងទាំងអស់គ្នាហ្នឹង យើងមុន -- ឥឡូវហ្នឹងយើងសើចដាក់គ្នា ប៉ុន្តែដល់យើងអត់ទឹកហូប ដល់យើងឃើញអ្នកណាមានទឹកកន្លះកែវ យើងដណ្តើមគ្នាហើយ។ ដូច្នេះយើងចាប់ទាស់គ្នាហើយអាហ្នឹងជាការធម្មតារបស់មនុស្ស គឺមនុស្សបើសិនជាយើងឃាំងមនុស្សឲ្យនៅកន្លែងតូចមួយ មនុស្សគ្មានសិទ្ធិសេរីភាពដើរទៅណាទៀត ហើយគ្មានម្ហូបហូប គ្មានទឹក គ្មានអីធ្វើអ្វីទាំងអស់គឺថា មនុស្សទោះជាស្រឡាញ់គ្នារបៀបណា ក៏មានការរកាំរកូសគ្នា ហើយការយកគ្នាឯងធ្វើជានេះ ធ្វើឲ្យគឺថា រឹតតែពិបាកឡើងទៀត ពីព្រោះអ្នកធ្វើហ្នឹង វាត្រូវយកចិត្តអង្គការផង ហើយវាមានទំនាស់ជាមួយគ្នាឯង ក្នុងការធ្វើហ្នឹង គឺធ្វើឲ្យបរិយាកាសនៅក្នុងមន្ទីរឃុំឃាំង មន្ទីរជំរំហ្នឹង កាន់តែទាស់គ្នា កាន់តែមិនទុកចិត្តគ្នា កាន់តែខ្លាំងឡើងៗ។ ហើយនេះជាៗយុទ្ធសាស្ត្ររបស់អង្គការបាទ គឺកសាង ៗ គឺកសាង គឺអង្គការឲ្យទិតៀន ស្វ័យទិតៀនគ្នាដើម្បីៗ ឲ្យឃើញកំហុសគ្នាទៅវិញ ទៅមក ហើយជួនកាលយើងធ្វើកំហុសហ្នឹងបងប្អូន ដែលជាយុទ្ធជនហ្នឹង មួយចំនួនធំ ជួនកាលគ្នាមិនដឹងថា នៅស្រុកបារាំងអានេះធ្លាប់នៅសមាគមនេះ អានេះធ្លាប់ទៅធ្វើអីចេះវាខុសគ្នាយ៉ាងម៉េច គ្នាក្តាប់អាបញ្ហាហ្នឹងអត់បានទេ។ ប៉ុន្តែជួនកាលបងប្អូនយើងពេលប្រជុំអ៊ំ អានេះប្រូ-សូវៀត អ្នកនេះធ្លាប់អី។ ដល់បងប្អូនយើង គាត់ក្តាប់អាហ្នឹងមិនបាន គាត់ថា អាប្រូ-សូវៀត វាខ្លាំងហើយអានោះ។ ដូច្នោះ វាធ្វើឲ្យដោយអចេតនា វាធ្វើឲ្យដូចថា ច្របូកច្របល់ការណ៍ហ្នឹង វាមិនទុកចិត្តគ្នា។ អានេះខ្ញុំនិយាយជាៗ ការពិសោធ ហើយនិងការសង្កេតឃើញរបស់ខ្ញុំពេលនោះបាទ។

[១៤:២៣:៣៥]

**ស៖** បាទ សូមអរគុណ។ តាមកំណត់ហេតុស្តាប់ចម្លើយលោក កាលដែលលោកទៅមន្ទីរក-១៥

ហើយនិងដ-២ លោកបានទៅមន្ទីរពេទ្យ ហើយលោកត្រូវបានគេបញ្ជូនទៅតាខ្មៅផងដែរ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តើលោកអាចជម្រាបជូនយើងបានដែរឬទេថា តើលក្ខខណ្ឌការងារ ហើយនិងលក្ខខណ្ឌជីវិតនៅកន្លែងធ្វើការនៅតាខ្មៅនោះ ដូច ឬក៏ប្រសើរជាង ឬក៏យ៉ាប់ជាងនៅក-១៥ ឬក៏ ដ-២ ដែរឬទេ?

**ឆ៖** បាទ សភាពការណ៍កាន់តែទ្រុឌទ្រោមដុនដាបទៅ នៅចំពោះជីវភាពពួកយើងខ្ញុំមកពីបរទេស ជាពិសេសនៅតាខ្មៅ ហើយនិងបន្ទាប់ទៀតនៅបឹងត្របែកបាទ។

[១៤:២៥:០៣]

**ស៖** ឥឡូវយើងនិយាយពីតាខ្មៅទេ តើលោកមានសិទ្ធិឈឺនៅទីនោះដែរឬទេ? ហើយមានរឿងអ្វីកើតឡើងចំពោះលោក បើសិនជាលោកឈឺវិញ?

**ឆ៖** នៅតាខ្មៅអត់មានអំណាចឈឺទេ បើឈឺគេបន្ថយអាហារបាទ។

**ស៖** ហើយលោកត្រូវធ្វើការងារអ្វីនៅតាខ្មៅ? សូមឲ្យនិយាយឲ្យបានសង្ខេបបន្តិច លោកខ្លីៗ។

**ឆ៖** មុខព្រួញផ្សេងៗមានឆ្ការកាប់ព្រៃ ដាំអំពៅ កាប់ -- ស្រីៗកាប់ៗអំពៅជាខណ្ឌៗ ដើម្បីយកវាទៅដាំ ហើយដាំបន្លែផ្សេងៗដូចជំរំផ្សេងទៀតដែរ។ ប៉ុន្តែខ្ញុំបញ្ជាក់ថានៅតាខ្មៅនេះ វាមានសភាពការណ៍អាប់អួរ ដោយសារបញ្ហាខ្មែរមួយចំនួន ដែលអង្កាល់ពួកខ្ញុំចេញទៅរោងចក្រនោះ ខ្មែរមួយចំនួនមកទៅធ្វើការអង្គរជ័យ ហើយខ្មែរហ្នឹងវាកាលនៅធ្វើការកសិដ្ឋានរដ្ឋអង្គរជ័យហ្នឹង ដែលវាមានគ្នា មានការធ្វើបាបពីៗកម្មាភិបាលកន្លែងនោះ ហើយមកវិញ ពួកហ្នឹងចេះតែនិយាយពីជីវិតនៅនោះវាលំបាកអីចេះមួយអីចេះពីរ វាអត់បាយ គេមើលងាយអីចេះមួយអីចេះពីរ។ ដូច្នេះ កម្មាភិបាលដែលត្រួតពួកយើងខ្ញុំនៅតាខ្មៅហ្នឹង គាត់ខឹង គាត់ដូចថា យើងនិយាយពីអង្គការអីចឹង ដូចថាវាយើងជាខ្មាំង។ ដូច្នេះ វាសភាពការណ៍ទាំងអស់ហ្នឹង ធ្វើឲ្យៗបរិយាកាសនៅបឹងត្របែក -- អំ!នៅតាខ្មៅហ្នឹងកាន់តែអាប់អួរឡើងបាទ។

[១៤:២៧:៣៣]

**ស៖** ក្នុងរយៈពេលហ្នឹង តើកម្មាភិបាលខ្មែរក្រហមបាននិយាយប្រាប់លោក អំពីសញ្ញាណខ្មាំងទេ? តើសញ្ញាណនេះគ្របដណ្តប់លើអ្វីខ្លះចំពោះខ្មែរក្រហមនេះ? ចង់បានន័យថា តើអ្នកណាជាខ្មាំង?

**ឆ៖** ពី ចាប់ពីតាខ្មៅទៅ គឺថាខ្មាំងធំបំផុតគឺខ្មាំងនៅក្នុងផ្ទៃក្នុងពួដ៏ផ្ទៃក្នុងយើងម្នាក់ៗ។ អាហ្នឹង

ខ្លាំងធំបំផុត ខ្លាំងដែលលាក់នៅក្នុងព្រលឹងផ្ទៃក្នុង សតិអារម្មណ៍យើងម្នាក់ៗ។

**ស៖** នៅតាខ្មៅ តើដូចនៅក-១៥ ឬក៏ដ-២ ដែរឬទេ? តើគេនៅតែចាត់ទុកថាលោកជាមនុស្ស របស់ហ្នុង ប៉ុន្តែមិនមែនជាអ្នកបដិវត្តន៍អ្វីទេ? អ៊ីចឹងមែនទេ?

**ឆ៖** បាទ មែន ប៉ុន្តែនៅដ-២ លោកប្រធានរោងចក្រគាត់ចិត្តល្អ។ គាត់មិនអាក្រក់ដូចនៅតា -- អ្នកត្រួតត្រាពួកយើងខ្ញុំនៅតាខ្មៅទេ។

[១៤:២៩:១៨]

**ស៖** ហេតុអ្វីបានជាគេចាត់ -- មើលយើងផ្លូវអាក្រក់ ថាយើងចាត់ទុកថាយើងជាមនុស្សរបស់ រណសិរ្សរួបរួមជាតិទៅវិញ? តើដោយសារថាយើង លោកចូលរួមក្នុងបដិវត្តន៍ហ្នឹងក្រោយគេ យឺតជាង គេបន្តិច ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំព្យាយាមអត់ធ្មត់ជាច្រើនដងហើយចំពោះការនាំមុខនេះ ប៉ុន្តែអ្វី ដែលគាត់ធ្វើ គឺគាត់ហាក់ដូចជាកំណត់នូវចម្លើយ។ គាត់ធ្វើដដែលៗ ជាច្រើនដងកន្លងមកហើយ។ ខ្ញុំមិន ចង់ជំទាស់ទៅលើអ្វីដែលបានសួរនេះទេ ព្រោះថាលោក លោកស្រី គឺជាអ្នកដែលមានអាជីព គាត់អាច ចោទនូវសំណួរទៅសាក្សី ដើម្បីឲ្យផ្តល់នូវចម្លើយ មិនមែនឲ្យចម្លើយទៅសាក្សី ហើយសួរថាអ៊ីចឹង មិនមែនទេ អានេះមិនមែនជាការចោទសួរសំណួរឡើយ។ ដូច្នេះហើយខ្ញុំគិតថា យើងគួរតែរក្សាទុក ឬក៏ គួរតែផ្តល់នូវការជំទាស់ចំពោះការដែលបានធ្វើឡើងដោយព្រះរាជអាជ្ញានេះ។ សូមអរគុណ។

[១៤:៣០:៤៣]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំកាត់សំណួរនេះជាពីរ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ហេតុអ្វីបានជាគេចាត់ទុកថា ពួកគាត់នេះជាសមាជិករបស់រណសិរ្សរួបរួមជាតិ?

**លោក អ៊ុង ចុងហឿង៖**

**ឆ៖** ខ្ញុំអត់មានចម្លើយនេះទេ ប៉ុន្តែតាមយោបល់ខ្ញុំ ខ្ញុំគិតពិចារណាខ្លួនឯង ហើយជាមួយគ្រួសារ

ខ្ញុំដែលពិចារណាទៅ ថាតើយើងហ្នឹងជាអ្វី? ជាវណ្ណៈអីសព្វថ្ងៃហ្នឹង? ឥឡូវយើងវាអត់មានអីទាំងអស់ ថាយើងអនុជន គឺយើងវាអត់មានអនុជនអី ហើយយើងអត់មានអីទាំងអស់ ហើយយើងមានតែស្បោង មានតែខោមួយ អាវមួយដូចប្រជារាស្ត្រ កម្មករ កសិករក្រអឺចឹង ដូចយើងវាអស់មានអីហើយ។ តើយើងមានអីខុសពីហ្នឹង? ហើយខ្ញុំពិចារណាទៅ ប្រពន្ធ អំ! គ្រួសារខ្ញុំគាត់ប្រាប់ថា "វាខុសគ្នាត្រង់កន្លែងយើងបានចូលសាលា ហើយបងប្អូនយើងគាត់អត់បានចូលសាលា វាខុសគ្នា ប្រហែលជាខុសគ្នាត្រង់កន្លែងហ្នឹង"។ ខ្ញុំជឿថាប្រពន្ធ អំ! គ្រួសារខ្ញុំនិយាយគាត់និយាយហ្នឹងដូចត្រូវបាទ។

[១៤:៣២:១៤]

**ស៖** តើអ្នកណាជាអ្នកដឹកនាំកន្លែងការដ្ឋានការងារនៅតាខ្មៅ?

**ឆ៖** ឈ្មោះបដិវត្តន៍គាត់ឈ្មោះ យុត។

**ស៖** តើនៅសម័យនោះលោកដឹងទេថា កន្លែងតាខ្មៅនេះនៅក្រោមឱវាទស្ថាប័នណា នៅក្រោមក្រសួងណាដែរ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ ប៉ុន្តែក្នុងសតិអារម្មណ៍ ខ្ញុំតាំងពី មកពីបរទេសមក ខ្ញុំដឹងថា ពួកខ្ញុំមកហ្នឹងដោយសារលោក អៀង សារី គឺនៅក្នុងតែសតិអារម្មណ៍ខ្លួនឯងអឺចឹង។ ប៉ុន្តែអត់មានឈរលើការអីច្បាស់លាស់ទេបាទ ប៉ុន្តែគ្រាន់ពួកខ្ញុំមកហ្នឹង ក៏ដោយគាត់អំពាវនាវមក។ ដូច្នេះចេះនៅក្នុងសតិអារម្មណ៍ខ្លួនឯងហ្នឹង គឺថានៅក្នុងក្រោមការគ្រប់គ្រងរបស់គាត់។ ប៉ុន្តែខ្ញុំអត់មានឯក -- អត់មានស្អីឲ្យដឹងថាពីណាទាក់ទងអីអង្គការណាផ្សេងទៀត ខ្ញុំៗក្តាប់អត់បានទេលោក។

**ស៖** បាទ សូមអរគុណ។ នៅតាខ្មៅនោះ តើបញ្ញាជនដែលនៅទីនោះ មានព្យាយាមរត់ចេញពីជំរំទេ? តើធ្លាប់មានកើតឡើងទេករណីបែបហ្នឹង?

[១៤:៣៤:០២]

**ឆ៖** មានបាទ មាន។ មានម្នាក់គាត់ ចៅ -- គាត់ឈ្មោះ ចៅ សេងណុង គាត់ដែលៗមកពីស្រុកបារាំង ហើយគាត់ជិះកប៉ាល់ហោះមកជំនាន់ជាមួយគ្រួសារខ្ញុំ។ ហើយពេលដល់ខ្ញុំទៅដល់តាខ្មៅហ្នឹង ឃើញគាត់ឈឺនៅ គាត់អត់ចូលធ្វើការពលកម្ម គាត់ឈឺ។ ហើយឈឺហ្នឹង គេអត់ឲ្យគាត់នៅផ្ទះទេ គេឲ្យនៅក្រោមផ្ទះរបស់ប្រធាន យុត ហ្នឹង។ ហើយគាត់ឈឺហ្នឹង គេឯកោគាត់ គេមិនសូវចង់ឲ្យអ្នកទាក់ទងគាត់ទេ ហើយគ្នាយើងក៏សូវមិនប៊ានទាក់ទងគាត់ដែរ។ គាត់ឈឺ ហើយដល់ៗ មួយនោះ ស្រាប់តែដល់ថ្ងៃមួយស្រាប់តែ យោធាហ្នឹងគេវ៉ៃៗ មោង វ៉ៃឲ្យពួកយើងខ្ញុំទៅប្រជុំ។ ទៅប្រជុំ គេថាមាន -- គេ

ហើយ បានគេព័ត៌មានថា ចៅ សេងណុង រត់ពីមន្ទីរតាខ្មៅហ្នឹងទៅបាត់។ ហើយគេ ឲ្យអ៊ីចឹងទៅ គេថា ចៅ សេណុង ហ្នឹងក្បត់ អ៊ីចេះមួយ អ៊ីចេះពីរអ៊ីចឹងទៅ ហើយក៏គេឲ្យយើងទៅធ្វើការ វិញទៅ ហើយពួកអស់លោកហ្នឹង គាត់ក៏ស្ងាត់ទៅ។ ហើយដល់ពីរបីថ្ងៃក្រោយមក ក៏គេថា គេចាប់ ចៅ សេណុង ហ្នឹងបានហើយ។ ហើយពួកខ្ញុំក៏ ចាប់បានហើយ ក៏នឹកមុនដំបូងប្រហែលជាគេយកមកវិញ ប៉ុន្តែបាត់ទៅពីមួយថ្ងៃទៅមួយថ្ងៃ បាត់ទៅ ចេះតែបាត់អ៊ីចឹងទៅ ក៏វាស្ងាត់ស្ងៀមទៅ បាទ។ ហើយដូច្នេះ ហើយដល់ពេលក្រោយមកទៀត ខ្ញុំឃើញឈ្មោះ ចៅ សេណុង នៅ អេស-ម្ភៃមួយ (S-21) បាទ។

[១៤:៣៥:៥៨]

**ស៖** លោកសាក្សី តើលោកអាចនិយាយប្រាប់យើងបានទេថា លោកនៅតាខ្មៅនោះ រយៈពេលប៉ុន្មាន -- ប្រហែលប៉ុន្មានដែរ? ហើយបន្ទាប់មក គេបញ្ជូនលោកទៅណាទៀត? ដោយមិនបាច់មើលពិគ្រោះសៀវភៅលោកទេ លោកសាក្សី។ បើសិនជាលោកចាំនោះ លោកសាក្សី?

**ឆ៖** ក្នុងចុងឆ្នាំ ១៩៧៦ បាទ។ ខ្ញុំប្រហែលក្នុងចុងឆ្នាំ ខែ ក្នុងប្រហែលជាខែ១១ ខែតុលា បើខ្ញុំ -- ឬក៏ខែ១១ ឬខែ១០ ឬខែ១១ ខ្ញុំនៅប្រហែល១ខែទេបាទ។ ខ្ញុំនៅ១ខែ ១ខែជាងបន្តិចបន្តួច ខ្ញុំមិនចាំច្បាស់ទេបាទ។

**ស៖** ហើយបន្ទាប់មកគេបានបញ្ជូនលោកទៅណាដែរ នៅចុងខែនុ៎ង?

**ឆ៖** បន្ទាប់មក គេយកពួកយើងខ្ញុំហ្នឹង ទៅមន្ទីរបឹងត្របែកបាទ។ យកពួកខ្ញុំទៅមន្ទីរបឹងត្របែក ប៉ុន្តែមួយចំនួន គេដកទៅកន្លែងផ្សេង។ ប៉ុន្តែអ្នកដកទៅកន្លែងផ្សេង ពេលនោះខ្ញុំអត់ដឹងថា គេដកទៅណាទេ ប៉ុន្តែក្រោយមក ខ្ញុំដឹងថា គេដកទៅ អេស-ម្ភៃមួយ។

[១៤:៣៧:៥៥]

**ស៖** បាទ សូមអរគុណ។ ឥឡូវនេះ យើងនិយាយទាក់ទងទៅនឹងការស្នាក់នៅរបស់លោកនៅបឹងត្របែក។ តើនៅទីនោះ លោកបានទទួលមិត្តភក្តិជាច្រើន ឬបញ្ញាជនជាច្រើន ដែលលោកបានស្គាល់ពីមុនមក ហើយដែលមកពី ក-១៥ អីជាដើមនោះ?

**ឆ៖** បាទ តាមខ្ញុំដឹងថា ដល់ពេលខ្ញុំមកដល់បឹងត្របែកហ្នឹង គឺខែ ប្រហែលជាខែ១១ ឃើញថាខ្ញុំបានដំណឹងថា ក-១៥ បិទហើយបាទ។ ហើយគេប្រមូលខ្មែរមកពីបរទេសទាំងអស់ នៅមកបឹងត្របែកបាទ។

**ស៖** តើមានមនុស្សច្រើនទេ នៅបឹងត្របែកហ្នឹង?

**ឆ៖** មនុស្សច្រើនៗជាងតាខ្មៅ ប៉ុន្តែបើប្រៀបធៀបមនុស្សដែលមករាប់ពាន់នាក់នោះ វាដូចជាមិនច្រើនប៉ុន្មានទេបាទ។

**ស៖** អ្នកដែលនៅបឹងត្របែកស្រាប់នោះ តើមានតែបញ្ញាជនទេឬ ឬក៏មានប្រភេទមនុស្សផ្សេងទៀតដែរ?

**ឆ៖** មានប្រភេទមនុស្សផ្សេងទៀត មានកម្មាភិបាលខ្មែរក្រហមពីរបីនាក់។ ខ្ញុំឥឡូវហ្នឹង ខ្ញុំភ្លេចឈ្មោះហើយ ប៉ុន្តែមានកម្មាភិបាលខ្មែរក្រហមពីរបីនាក់ ហើយក្រៅពីហ្នឹង សុទ្ធតែខ្មែរមកបរទេស។

**ស៖** ពេលដែលលោកនិយាយថាខ្មែរមកពីបរទេសនុ៎ង ដូចថា តើអ្នកទាំងអស់នោះមកពីណាដែរ ហើយតើៗពួកគាត់នោះមកពីប្រទេសផ្សេងៗគ្នា ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ភាគច្រើនមកពីប្រទេសផ្សេងៗគ្នា ប៉ុន្តែភាគច្រើនមកពីប្រទេសបារាំង មួយចំនួនតូចមកពីសូវៀត។ ប៉ុន្តែឃើញពួកមកពីសូវៀត និង -- មានតិចទេមានបាត់មួយចំនួនធំហើយ។

[១៤:៤១:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី។ អរគុណតំណាងសហព្រះរាជអាជ្ញា។

ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលកន្លែងសម្រាកសម្រាប់សាក្សី នៅបន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:២២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណច្រើនលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** លោកសាក្សីអម្បាញ់មិញនេះ យើងកំពុងតែនិយាយពេលដែលលោករស់នៅបឹងត្របែក លោកឆ្លើយថា លោកបានទៅដល់ខែវិច្ឆិកា ឆ្នាំ៧៦ គឺប្រហាក់ប្រហែលក្នុងពេលនុ៎ង។ តើនៅបឹងត្របែក លោកមានបានឃើញអ្នកដែលនៅក្នុងយន្តហោះជាមួយលោកដែលជិះមកទីក្រុងភ្នំពេញ គឺថាដូចជាឧទាហរណ៍អ្នកអតីតយោធារបស់សាធារណរដ្ឋខ្មែរនោះ? តើលោកមានធ្លាប់ឃើញពួកគេទេនៅទីនោះ?

[១៥:០២:៣១]

**លោក អុង ថុងហឿង៖**

**ឆ៖** បាទ អត់ឃើញទេ។

**ស៖** នៅពេលនោះ នៅបឹងត្របែក តើមានអ្នកការទូតចាស់ៗនៅទីនោះទេ?

**ឆ៖** នៅបឹងត្របែកពេលនោះ មុនខ្ញុំ -- នៅពេលនោះអត់មានអ្នកការទូតមកពីបរទេសទេ។

**ស៖** តើលោកមានស្គាល់ឈ្មោះលេខកូដរបស់បឹងត្របែកចន្លោះឆ្នាំ៧៦ និងឆ្នាំ៧៧ ទេ?

**ឆ៖** នៅពេលនោះ ខ្ញុំអត់បានដឹងទេ។ ក្រោយមកគេប្រាប់ខ្ញុំដែរ ប៉ុន្តែខ្ញុំអត់ចាំទេបាទ។

**ស៖** នៅបឹងត្របែក តើលោកត្រូវបំពេញភារកិច្ចប្រចាំថ្ងៃអ្វីខ្លះ? ហេតុអ្វីបានជាអម្បាញ់មិញនេះលោកនិយាយថា លក្ខខណ្ឌជីវភាពនៅទីនោះមានការលំបាក?

[១៥:០៤:២១]

**ឆ៖** ខ្ញុំចង់និយាយថា ការតស៊ូវណ្ណៈ ដែលចាប់ផ្តើមផុសផុលពីតាខ្មៅមកនោះ វាកាន់តែផុសផុលឡើងនៅបឹងត្របែក។ បានន័យថា គេយកការតស៊ូប្រឆាំងនឹងសតិអារម្មណ៍ជាកត្តាកំណត់។

**ស៖** តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ទេ លោកចង់មានន័យថាម៉េចការតស៊ូវណ្ណៈហ្នឹង តើវាស្តែងឡើងយ៉ាងម៉េចដែរនៅពេលនុ៎ង? ជាពិសេស គឺថាជាមួយនឹងកម្មាភិបាលនៃជំរុំបឹងត្របែកនេះតែម្តង។

**ឆ៖** ការតស៊ូហ្នឹង វាកាន់តែស្រួចស្រាំឡើង តាមគេនិយាយប្រាប់យើងពេលនោះថា តាមមាគ៌ារបស់បក្ស -- អ៎! របស់អង្គការ មិនមែនបក្សទេ សូមទោស! របស់អង្គការគឺត្រូវតស៊ូរកសត្រូវផ្ទៃក្នុង នៅក្នុងខ្លួនបុគ្គលម្នាក់ៗ។ ដូច្នេះ ឧបមាថា នៅបឹងត្របែកនេះហើយដែលពួកយើងខ្ញុំ ជួនវាមកស្រេកឃ្លាន គឺជួនកាលទៅឃើញដូងនៅបឹងត្របែកហ្នឹង វាមិនមែនជួនកាលទេ គឺឃើញដូងធ្លាក់ ទុំធ្លាក់ពេញអ៊ីចឹង បើគេហាមមិនឱ្យបេះ រើសដូងហ្នឹងយកមកទទួលទានទេ។ គេហាមមិនឱ្យបេះផ្លែឈើដែលមានហ្នឹងយកមកទទួលទានទេ។ គេហាមមិនឱ្យរើសខ្យងនៅកន្លែងបឹងត្របែកហ្នឹងមកទទួលទានទេ ពីព្រោះគេថាអាហ្នឹងសេរី ក្បត់ មិនៗតាមគោលការណ៍តស៊ូប្រឆាំងនឹងបុគ្គលនិយម សេរីនិយមរបស់បក្ស -- អ៎!របស់អង្គការ។ ដូច្នេះ គឺគេ គេថាអ៊ីចឹង ហើយពេលខ្លះគេថាតស៊ូក្ដៅហ្នឹង គឺថា បើជួនកាលគេចាប់ គេចាប់គ្នាយើងដែលរើសដូង ទទួលទានដោយអត់មានការអនុញ្ញាតហ្នឹងមកធ្វើមីទ្ទិង។ គេថាធ្វើមីទ្ទិងប្រឆាំងនឹង អារឿងហៅថា អ្នកក្បត់វណ្ណៈ។ ធ្វើមីទ្ទិងហ្នឹងយ៉ាងម៉េច? គឺធ្វើមីទ្ទិងហ្នឹង គេអ្នកៗទទួលខុសត្រូវហ្នឹង គេចាប់ផ្ដើមីទ្ទិងហ្នឹងទៅ ហើយគេឱ្យ គេចាប់អ្នកហ្នឹងមក ឱ្យគ្នាយើងហ្នឹងទិតៀនអ្នកហ្នឹងទៅ យក ហើយអ្នកហ្នឹងទទួលសារភាពថាខ្លួនឯងខុសអ៊ីចេះមួយ អ៊ីចេះពីរទៅ។ អាហ្នឹង គឺអ៊ីចឹងបាទ។ អាហ្នឹងគេហៅថា តស៊ូវណ្ណៈក្ដៅបាទ។

[១៥:០៧:៤៥]

**ស៖** បើតាមលោកដឹងនៅពេលនោះ នៅពេលដែលលោកទៅដល់បឹងត្របែកភ្លាមនោះ តើជំរំមានការរៀបចំយ៉ាងម៉េចដែរ? មានរចនាសម្ព័ន្ធយ៉ាងម៉េច តើមានក្រុមផ្សេងៗគ្នាដែរឬទេ? ហើយរចនាសម្ព័ន្ធឋានានុក្រមនៅក្នុងជំរំនោះ វាយ៉ាងម៉េចដែរ?

**ឆ៖** វាជាក់ស្ដែងទៅ គឺតាមខ្ញុំក្ដាប់បានគឺថាវា គេនៅរៀបចាត់តាំង រៀបចាត់ចែងជាក្រុមជាប្រធានក្រុមហ្នឹងនៅដែលបាទ។ គឺថាគេយកអ្នកមកពីបរទេសដូចគ្នាហ្នឹង ធ្វើជាប្រធាន ឬក៏ធ្វើជាប្រធានជំរំ ធ្វើប្រធានក្រុមអ៊ីចឹងចាត់ចែង។ រីឯអនុប្រធានស្អីៗចាត់ចែង ត្រួតគ្នាឯងទៅ ហើយដែលគេហៅថា អង្កាល់នោះគេហៅថា តំណាងអង្គការនោះនៅត្រួតពីលើ ហើយតំណាងអង្គការហ្នឹង តើតំណាងពីត្រឹមថ្នាក់ណាមក យើងខ្ញុំអត់ដឹងទេ។ ប៉ុនគ្រាន់ថា គេអ្នកនៅ យើងគ្នាយើងដែលទទួលខុសត្រូវហ្នឹង រាយការណ៍ប្រាប់គេទៅ ហើយអាហ្នឹងក៏វានៅភាពដដែល គឺថាធ្វើឱ្យអ្នកដែលទទួលខុសត្រូវហ្នឹង គឺថា វាមាន ត្រូវយក ត្រូវរាយការណ៍ទៅឱ្យអ្នកទទួលខុសត្រូវតំណាងអង្គការហ្នឹង។ ហើយដូច្នេះ វាត្រូវគាបសង្កត់មិត្តភក្ដិខ្លួនឯងហ្នឹង ដើម្បីឱ្យអង្គការហ្នឹងគេពេញចិត្ត។ បាទ អាហ្នឹងវាៗ បង្កើតឱ្យមាន

បរិយាកាសមិនទុកចិត្តគ្នា បរិយាកាសទិតៀនស្វ័យទិតៀនគ្នា បរិយាកាសមើលមុខគ្នាមិនត្រង់។ អាហ្នឹង វាអ៊ីចឹង។ អាហ្នឹងជាបាតុភូតដែលមាននៅពេលនោះ ហើយអាហ្នឹងបាតុភូតនៅបឹងត្របែកពេលនោះ គឺវាតានតឹងជាងនៅតាខ្មៅទៀតបាទ។

[១៥:១០:០៥]

**ស៖** តើកម្មាភិបាលខ្មែរក្រហមណាខ្លះដែលជាអ្នកដឹកនាំមន្ទីរបឹងត្របែក? លោកអាចប្រាប់ឈ្មោះកម្មាភិបាលខ្មែរក្រហមទាំងអស់នោះបានទេ? ឬក៏ឈ្មោះបញ្ញាជនមួយចំនួន ដែលខ្មែរក្រហមចាត់ឲ្យដឹកនាំមន្ទីរនោះ?

**ឆ៖** កម្មាភិបាលខ្ញុំចាំមួយ ដូចឈ្មោះ សារ៉ន។ ហើយឈ្មោះផ្សេងទៀត ខ្ញុំបាទភ្លេចហើយ ទាល់តែបើកសៀវភៅមើល ប៉ុនខ្ញុំភ្លេចហើយ។ ហើយមិត្តភក្តិខ្ញុំមកពីបរទេសមាន ទ្រី ម៉េងហួត, ទ្រី ម៉េងហួត ហ្នឹងគាត់ជាបណ្ឌិតខាងគីមី ហើយ តូ ទីភាគ, តូ ទីភាគ ហ្នឹងគាត់ៗមកពី គាត់ធ្លាប់ទៅរៀននៅប៉េកាំង គាត់មកពីស្រុកបារាំង ហើយគាត់នៅស្នាក់រៀនពេទ្យនៅប៉េកាំង។ ហ្នឹងគាត់ ដែលខ្ញុំចាំមានពីរនាក់ហ្នឹងជាពិសេសបាទ។

[១៥:១១:២១]

**ស៖** នៅសម័យនោះ តើលោកដឹងទេថាអ្នកណាជាមេរបស់ សារ៉ន នោះ?

**ឆ៖** ខ្ញុំបាទគ្រាន់តែឮថាអង្គការ ប៉ុនមិនដឹងថាអង្គការហ្នឹងពីណាទេបាទ។

**ស៖** ក្នុងអំឡុងពេលដំបូងៗដែលលោកស្នាក់នៅបឹងត្របែក តើមានអ្នកណាត្រូវបានគេនាំចេញពីជំរំបឹងត្របែកដែរឬទេ? ហើយការនាំចេញទៅនេះញឹកញាប់ដែរឬទេ?

**ឆ៖** ការនាំចេញហ្នឹងញឹកញាប់ ប៉ុន្តែខ្ញុំមិនចាំឈ្មោះអស់ទេ ប៉ុនឃើញថាញឹកញាប់បាទ។ ជាពិសេសបឹងត្របែកហ្នឹងជាជំរំចុងក្រោយរបស់ពួកយើងខ្ញុំនៅភ្នំពេញ មុនគេដឹកនាំយើងខ្ញុំទៅដីក្រហម។ ដូច្នេះគេ -- ពេលហ្នឹងគឺគេយកចេញទៅញឹកញាប់ដែលខ្ញុំអាចរាប់ឈ្មោះបានខ្លះ ដែលខ្ញុំចាំ។ ទី១ ដែលខ្ញុំជាងគេ គឺ វស់ សារិន ហ្នឹងជាបងថ្លៃខ្ញុំ, ហើយលោក ភីង តុន, លោក ឈូក មឹងម៉ៅ ហើយនិងអ្នកផ្សេងៗទៀតដែលខ្ញុំមិនបាននឹកឃើញឈ្មោះភ្លាមៗហ្នឹងទេបាទ។

**ស៖** ហើយគេនាំមនុស្សចេញទៅហ្នឹងក្នុងកាលៈទេសៈបែបណា? គេមានប្រាប់ពួកគាត់ថាត្រូវយកទៅណាទេ?

**ឆ៖** តាមខ្ញុំដឹងគេអត់មានប្រាប់ពីណាយកទៅណាទេ ចំពោះខ្ញុំដែល -- ហ្នឹងករណីផ្ទាល់ខ្លួនក្នុង

គ្រួសារខ្ញុំ ដែលគេយកបង រស់ សារិន ទៅហ្នឹង ខ្ញុំ -- យើងខ្ញុំស្មានថា គេយកគាត់ទៅធ្វើការនៅ -- ព្រោះគាត់ជាចាងហ្វាង អតីតចាងហ្វាងចំណតអាកាសយានពោធិ៍ចិនតុង ក្រែងគេត្រូវការអីយកទៅធ្វើខាងកប៉ាល់ហោះអីអឺចឹង ចេះស្មានអឺចឹងដើម្បី -- ប៉ុន្តែពេលនោះអត់មានដឹងទេបាទ។

[១៥:១៤:១៦]

**ស៖** តើនៅពេលនោះ នៅក្នុងជំរំបឹងត្របែក លោកមានឃើញឈ្មោះ ឃួន ដាវីដ ទេ? មាននឹកមានដឹងទេថា ឈ្មោះនេះនៅទីហ្នឹងដែរឬទេ?

**ឆ៖** ឃួន ដាវីដ ជា១មិត្តភក្តិមួយរបស់ខ្ញុំ ប៉ុនខ្ញុំដូចជាភ្លេចទៅហើយបាទ។ មិនដឹងជាគេយកគាត់តាំងពីនៅបឹងត្របែក ឬក៏យកពីជំរំ ក-១៥ ខ្ញុំភ្លេចហើយឥឡូវហ្នឹង។ ខ្ញុំកាលមុន ខ្ញុំនៅចាំ ប៉ុនឥឡូវខ្ញុំភ្លេចហើយ។ ប៉ុនខ្ញុំដែលច្បាស់នោះ ខ្ញុំបានឃើញឈ្មោះគាត់នៅ អេស-ទ្រាំងតេអង។

**ស៖** ចុះលោក គ្រិន លាន លោកមានធ្លាប់ឃើញគាត់ទេ នៅក្នុងជំរំណាមួយដែលលោករស់នៅនុ៎ង? គឺឈ្មោះ គ្រិន លាន។

**ឆ៖** លោក គ្រិន លាន គឺដល់ខ្ញុំនៅជំរំបឹងត្របែកខ្ញុំបានឃើញគាត់ជាចុងក្រោយបំផុត ហើយតាមខ្ញុំចាំ ពេល ភុំ, ពេលហ្នឹង ភុំ គាត់ចាប់ធ្វើសន្និបាត គេប្រជុំនៅរោងពុម្ព នៅរោងពុម្ពបឹងត្របែកហ្នឹង ហើយគេយកគាត់ហ្នឹង គាត់ជួប ភុំ ហើយទៅ គេដឹក គ្រិន លាន ហ្នឹងចេញពីបឹងត្របែកហ្នឹងទៅ។ អាហ្នឹងបើតាមខ្ញុំចាំ ព្រោះគាត់មកដល់បឹងត្របែកហ្នឹង មិនដឹងមកពីណាទេ មកជាមួយគ្នាពីរនាក់ទៀត ហើយខ្ញុំបានជួបគាត់នៅជាចុងក្រោយ ហើយជា១លើកទី១ ហើយជាចុងក្រោយនៅបឹងត្របែកហ្នឹង។

[១៥:១៦:៣២]

**ស៖** អម្បាញ់មិញលោកនិយាយថា សារ៉ន ជាអ្នកដឹកនាំបឹងត្របែក ហេតុអីបានជាឈ្មោះ ពូ (ស៊ីក) នេះជាអ្នកកោះប្រជុំទៅវិញ នៅពេលដែលនៅបឹងត្របែកនោះ?

**ឆ៖** ខ្ញុំក្តាប់មិនបានទេ ភុំ ប៉ុន្តែ ភុំ ហ្នឹងជាអ្នកមើលខុសត្រូវត្រួតត្រាពួកខ្ញុំនៅក-១៥។ ដូច្នេះខ្ញុំអត់ដឹងថា មូលហេតុអីទេ ប៉ុន្តែគ្រាន់ថា ពេលហ្នឹង ភុំ ហ្នឹងគ្រាន់តែពេលចាំពេលនោះ គាត់និយាយថាក្នុងសន្និបាតហ្នឹងគាត់បាននិយាយថា "ការតស៊ូផ្ទៃក្នុងរបស់បក្សហ្នឹង គាត់ខ្លួនឯងក៏ស្រៀវខ្នងដែរ"។ ហើយដល់ឮសួរអឺចឹង ខ្ញុំនឹកឃើញសម័យហ៊ីទ្លែរ ដែលនឹកឃើញថាពាក្យបារាំងថា *ឡានុយ ដឺ ពុយត្វ* គឺនឹកឃើញថាពួកហ្នឹងកំពុងកាប់ចាក់គ្នា ដូចឮសួរ ភុំ គាត់និយាយអឺចឹង។

**ស៖** សូមអរគុណ។ លោកបានបញ្ជាក់ថា ក្រោយមកលោកចេញទៅដីក្រហម តើលោកអាច

បញ្ជាក់បានទេថា លោកនៅដីក្រហមនោះរយៈពេលប៉ុន្មានខែដែរ? ហើយដីក្រហមហ្នឹងនៅឯណាដែរ នៅក្នុងប្រទេសកម្ពុជា?

[១៥:១៨:០៦]

**ឆ៖** ខ្ញុំចេញទៅដីក្រហមចុងឆ្នាំ៧៦ ខែ១២បាទ។ ហើយខ្ញុំនៅរហូតទៅដល់ឆ្នាំ៧៥ -- រហូតដល់ ២, ៣ខែមុនៗ របបកម្ពុជាធិបតេយ្យធ្លាក់ទៅវិញបាទ។ សូមទោសថ្ងៃខែខ្ញុំចាំអត់ច្បាស់ទេ។

**ស៖** ប្រសិនបើខ្ញុំយល់ច្បាស់តាមការបកប្រែនោះគឺថា លោករស់នៅទីនោះរហូតដល់ -- រស់នៅទីនេះពីខែ១២ ៧៦ រហូតដល់មុនពេលបែក។ លោកអាចប្រាប់បានទេ ហេតុអីបានជាគេឲ្យលោកទៅដីក្រហម? ហើយនៅពេលដែលលោកទៅដល់ដីក្រហមនោះ គេឲ្យលោកធ្វើអ្វីខ្លះដែរ?

**ឆ៖** ខ្ញុំមកដល់បឹងត្របែក នៅដល់បានបន្តិច ក៏ឮសូរគេផ្សាយថា ឲ្យនាំគ្នាចុះស្ថិតិ។ ខ្ញុំ ហើយចុះ -- គេថាឲ្យចុះឈ្មោះក្នុងស្ថិតិដើម្បីទៅដីក្រហម។ ខ្ញុំចេះតែឆ្ងល់ថា ចុះឈ្មោះក្នុងស្ថិតិម៉េច ហើយដល់ហើយទៅយល់ថា ឲ្យចុះឈ្មោះ ដើម្បីគេត្រូវការអ្នកស្ម័គ្រចិត្តទៅរស់នៅដីក្រហម។ គេប្រាប់ថា ដីក្រហមហ្នឹងវាមានសំបូរណាស់ វាមានម្នាស់ វាមានចេកទុំ វាមានស្ពី មានដំឡូងឈើ មានអី អត់ខ្វះហូបទេ គឺថា គឺទៅហ្នឹង គឺថាសម្បូរ ស្ពីក៏សម្បូរដែរ។ ដូច្នេះ គឺគេឲ្យអំពាវនាវឲ្យចុះ ហើយៗបងថ្លៃខ្ញុំហ្នឹង គាត់ រស់ សារិន ហ្នឹង គាត់ចុះមុនគេ ហើយខ្ញុំ អង្គាល់ហ្នឹង គ្រួសារខ្ញុំគាត់ឲ្យ គាត់ពិភាក្សាជាមួយខ្ញុំ ឲ្យខ្ញុំចុះឈ្មោះនឹងគេនឹងឯងដែរ។ ប៉ុន្តែខ្ញុំចេះប្រយ័ត្ន ខ្ញុំថា យី! គេឲ្យយើងរើសទៅអ៊ីចឹង ហើយគេប្រាប់ថា វាសម្បូរអ៊ីចឹង ក្រែងគេរើសតិអារម្មណ៍យើងឲ្យប្រយ័ត្ន ខ្ញុំថាឲ្យប្រយ័ត្នសិន។ ប៉ុន្តែគ្រួសារខ្ញុំគាត់ចេះតែរុញទៅ ខ្ញុំ បើចង់ចុះក៏ចុះទៅបើ -- ដូច្នេះ ធំក៏ ខ្ញុំក៏ចុះឈ្មោះនឹងគេនឹងឯងទៅបាទ ទៅដីក្រហមហ្នឹង។

[១៥:២១:០៤]

**ស៖** ហើយមុននឹងពេលដែលលោកចាប់ផ្តើមធ្វើសកម្មភាពនៅទីនោះ តើលោកអាចប្រាប់បានទេថា តើដីក្រហមនោះ មានទីតាំងឯណាដែរ? នៅក្នុងតំបន់ណាដែរនៃប្រទេសកម្ពុជានោះ?

**ឆ៖** ធ្វើដំណើរទៅយប់ ហើយគេប្រាប់ខ្ញុំថានៅ អ្នកស្គាល់ភូមិសាស្ត្រ គេប្រាប់ខ្ញុំថា នៅស្រុកស្ទឹងត្រង់។ ហើយអង្គាល់ហ្នឹង ធ្វើដំណើរទៅ ដូចទៅដល់ហ្នឹង យប់អាធ្រាត្រហើយ គឺទៅដល់ដីក្រហមហ្នឹង វាកាត់ព្រៃកៅស៊ូ ហើយវា ហើយដល់ភ្លឺឡើង ស្រាប់នៅក្នុងមន្ទីរមួយ ហៅថា មន្ទីរ១៧។ មន្ទីរ១៧ហ្នឹង ហើយទៅក៏បងប្អូននៅមន្ទីរហ្នឹង មានឈ្មោះ កាន់ ឈ្មោះអ៊ីៗហ្នឹង គឺថាទទួលពួកយើងខ្ញុំហ្នឹង

ដោយ -- ជាលើកទីមួយហើយ ទទួលដូចជាវា ដូចបងប្អូងអ៊ីចឹង ឃើញថា អ្នកខ្លះថា អ៊ូ ធ្លាប់ គេធ្លាប់ធ្វើការ ខ្សឹបប្រាប់ថាគេធ្លាប់ អង្កាល់ហ្នឹងពីមុន ធ្លាប់មាន ទ្រង់នរោត្តម ភូរីស្សារា, ហ៊ូ យន់ អីអ្នក អ្នកដែលធ្លាប់ធ្វើជារដ្ឋមន្ត្រីនេះ រដ្ឋមន្ត្រីនោះ នៅកន្លែងហ្នឹង។ ហើយដូច្នេះ ខ្ញុំទៅដីក្រហមហ្នឹង គឺភូមិសាស្ត្រដីក្រហមហ្នឹង មាន ប-២០, ប-១៧ ដែលពួកខ្ញុំនៅ ហើយ ប-១៧ក្នុង ដែលពួកកម្មាភិបាលនៅ។ ហើយក្រោយមកទៀត មានកើតមន្ទីរមួយទៀត ហៅ ប-១៨។ អាហ្នឹង ភូមិសាស្ត្រហ្នឹងនៅជិតនៅស្រុកស្ទឹងត្រង់ ប៉ុន្តែនៅក្នុងព្រៃ ហួសៗពីចម្ការកៅស៊ូបន្តិចទៅបាទ។ ខ្ញុំមិនដឹងជាភូមិ -- ខ្ញុំធ្លាប់ទៅក្រោយម្តងទៀតដែរ ប៉ុន្តែខ្ញុំមិនដឹងជាភូមិសាស្ត្រហ្នឹង -- ខ្ញុំអាច -- មិនអាចប្រាប់ជម្រាបលោកហួសពីហ្នឹងទេបាទ។

[១៥:២៣:០៣]

**ស៖** អ៊ីចឹងឲ្យខ្លីទៅ ថានៅទីនោះ លោកធ្វើការអ្វីខ្លះ?

**ឆ៖** ការងារដំបូង គឺកាប់ឆ្ការព្រៃបាទ កាប់ឆ្ការព្រៃដំឡូងៗឈើ។

**ស៖** តើលោកអាចប្រាប់បានទេថា នៅដីក្រហមនោះមានវិន័យយ៉ាងណាដែរ? ហើយមានមនុស្សបាត់ខ្លួនពីជំរំដីក្រហមនេះដែរឬទេ?

**ឆ៖** នៅដីក្រហមនេះជារួមមានជីវភាពធូរស្រាល។ ទី១ យើងមានដំឡូងឈើ មានផ្លែឈើហូបច្រើនមែន។ ដូច្នេះយើង ជីវភាពយើងរស់បានស្រួល ហើយមានកន្លែងដើរចុះដើរឡើងធំ ហើយនៅជិតព្រៃ ហើយមានទឹក។ ដូច្នេះ ជីវភាពយើងជារួម គឺវាល្អជាងបឹងត្របែកឆ្ងាយណាស់។ ហើយកម្មាភិបាលខ្មែរក្រហមទៀតសោត នៅទីនោះ គឺក៏មានការគួរសមជាមួយយើង។ ជាមួយពួកយើងខ្ញុំ ក៏មានការគួរសមជាមួយពួកយើងខ្ញុំ ធម្មតា ដូចជាលើកទីមួយហើយ ដែលយើងខ្ញុំបានទទួលមានកម្មាភិបាលខ្មែរក្រហម ដូចគេគួរសមរបៀបនេះបាទ។ ប៉ុន្តែការគួរសមនេះទៅដីក្រហមបន្តិចទៅគឺទៅថ្ងៃទី១ ក៏គេយក -- មុនដំបូងគេយកគ្នាយើងដែលខ្មែរនៅនោះ គឺថាយកចេញមកជាបន្តបន្ទាប់ដែរ ដែលខ្ញុំចាំជាងគេយកលើកដំបូងដែលខ្ញុំនៅចាំ ជាងគេ គឺគេយកក្អួយលោក ក្អួយគ្រួសារលោក អៀង សារី ដែលអ្នកស្រី អៀង ធីរិទ្ធ យកពីរនាក់ចេញពីដីក្រហមហ្នឹងបានទៅបានពីរបីថ្ងៃ គេយកចេញមក។ ខ្ញុំមិនដឹងជាពីរ ឬបីថ្ងៃទេ ប៉ុន្តែនៅមិនបានយូរស្រាប់គេយកចេញមកវិញ។ ហើយយកមួយទៀត យក ហាម សុគង់ យកមកវិញ។ យក ហាម សុគង់ ហ្នឹងយកចេញតែម្នាក់ឯង ចេញអត់ចេញជាមួយគ្នាទេ អាហ្នឹងពេលថ្មីៗក្នុងអាទិត្យតែមួយគេយកបីនាក់ហ្នឹងយកចេញមកវិញ។ ហាម សុគង់ ខ្ញុំនៅចាំច្បាស់ ពីព្រោះជា

វិស្វករ ហើយកាលនៅ គាត់នៅស្រុកបារាំងគាត់នៅបូរីអន្តរជាតិផ្ទះហូឡង់ជាមួយគ្រួសារខ្ញុំ ជាមួយភរិយាខ្ញុំ ហើយជាមិត្តភក្តិភរិយាខ្ញុំ ខ្ញុំស្គាល់គាត់ ហើយគាត់លាចេញទៅវិញ។ អាហ្នឹងគឺ -- ហើយបន្តបន្ទាប់ទៀត គឺយកចេញជាបន្តបន្ទាប់គឺ -- ហើយយកចេញម្តងៗគឺថា យើងនាំគ្នាពេលខ្លះកាប់ ពេលខ្លះគេកាប់ អង្គការហ្នឹងគេឲ្យយើងកាប់ គេឲ្យយើងកាប់មាន់កាប់ទា ដើម្បីៗដូចថាដើម្បីយកឲ្យគ្នាយើងចេញហ្នឹងដំណើរហូបតាមផ្លូវអ៊ីចឹង គឺថាយើងដូចជាបុណ្យ ដើម្បីចេញគឺថា ដែលចេះចេញជាបន្តបន្ទាប់ខ្ញុំមិនដឹងច្បាស់ទេ ដែលខ្ញុំដូច ខ្ញុំនៅចាំមួយចំនួន ឈ្មោះមួយចំនួនប្រហែលជាង១០០នាក់ ដែលខ្ញុំនៅចាំគឺចេញៗជាហូរហែបន្តបន្ទាប់ក្នុងអំឡុងដែលពួកយើងខ្ញុំរស់នៅ។ បាទន៎ចេញទៅ អង្គាល់ហ្នឹងអត់ដឹងចេញទៅណាទេបាទ។

[១៥:២៧:០៧]

**សៈ** តើលោកដឹងទេ ថាក្មួយរបស់ អៀង សារី, អៀង ធីរិទ្ធ នេះស្ថិតនៅក្នុងចំណោមអ្នកបាត់ខ្លួននោះ ឬក៏ពួកយើងអាចឃើញពួកគាត់នៅពេលក្រោយមកទៀត?

**ឆៈ** ដែល ខ្ញុំដល់ហើយទៅដល់ពួកយើងខ្ញុំចេញពីដីក្រហមមកវិញហើយ រក ដល់ខ្ញុំមកធ្វើការនៅមន្ទីរទួលស្លែង ខ្ញុំឃើញឈ្មោះខ្មែរមកពីបរទេសមួយចំនួន ខ្ញុំរើឈ្មោះខ្មែរបរទេសមួយចំនួន ហើយខ្ញុំអត់ឃើញឈ្មោះអ្នកមកពីទួលស្លែង អ៊ំ! មកពីដីក្រហម។ ហើយខ្ញុំចេះតែឆ្ងល់ថាពួកហ្នឹងទៅណាទៅ។ ហើយដែលខ្ញុំដឹងគឺថា ពួកហ្នឹងបាត់ខ្លួន បាត់ខ្លួននៅ -- ឃើញនៅរស់តែពីរនាក់គឺក្មួយលោក ម៉ាដាម អ៊ំ! លោកស្រី អៀង ធីរិទ្ធ គឺគាត់នៅរស់រហូតដល់សព្វថ្ងៃ ក្រៅពីហ្នឹងស្លាប់អស់បាទ។

[១៥:២៨:២៧]

**សៈ** ដូច្នេះ គឺថាពេលនោះលោកមិនទាន់ដឹងទេ លោកដឹងនៅពេលក្រោយទេអ៊ីចឹងមែនទេ? នៅពេលបញ្ចប់ការរស់នៅដីក្រហម តើគេមានប្រាប់លោកថា លោក -- គេបញ្ចប់ការអប់រំលត់ដំលោកទេ? ព្រោះថាលោកបាននៅទីនោះយូរ ហើយក្រោយពីប៉ុន្មានខែប៉ុន្មានឆ្នាំហ្នឹងមក គេបានវាយតម្លៃកម្រិតអប់រំកសាងខ្លួនលោក ថាលោកត្រូវបញ្ចប់ការអប់រំកសាងហើយ ឬក៏គេបញ្ជូនលោកទៅកន្លែងណាផ្សេងទៀតដើម្បីអប់រំកសាងទៀត?

**ឆៈ** ខ្ញុំអាចបញ្ជាក់បន្តិច គឺថាដល់វាបាត់ខ្លួនអ្នកផ្សេងទៀតមកពីបឹងត្របែក អ៊ំ! មកពីដីក្រហមអ៊ីចឹងទៅក៏ឆ្នាំ២០០០ -- អង្គាល់ឆ្នាំ១៩៧៩ អង្គាល់ពេលដែលខ្ញុំទៅដល់មន្ទីរ ទៅធ្វើការនៅមន្ទីរ អេស-រ៉ាំងតេអង ហ្នឹងគេមានៗពេទ្យម្នាក់ ដែលអង្គាល់ពីដើមគាត់ធ្វើការនៅជាមួយពួកខ្មែរក្រហម គាត់ប្រាប់

ខ្ញុំថា ពួកបងឯងហ្នឹងគេយកទៅសម្លាប់នៅព្រៃកុងអស់ហើយ។ ហើយខ្ញុំវាក៏ ខ្ញុំភ្លាមៗហ្នឹង ខ្ញុំអត់ជឿទេ សម្លាប់នៅព្រៃកុងហ្នឹងៗ ប្រហែលជាកន្លះម៉ោងយ៉ាងៗយូរពីមន្ទីរដែលពួកយើងខ្ញុំនៅ។ ហើយខ្ញុំថា អីចុះយកមនុស្សមករាប់ៗគ្រប់គ្នាហ្នឹង មិនដឹងប៉ុន្មានដងនឹងយកមកសម្លាប់អ៊ីចឹងធ្វើអី ហើយខ្ញុំក៏ដូចវាពិបាកជឿដែរ ប៉ុន្តែដល់ហើយទៅក្នុងឆ្នាំ២០០០ ខ្ញុំក៏បានទៅជាមួយ ហង់រី ឡូកា ហើយនិង *ហ្វូតូក្រាហ្វ* អ្នកថតរូប អៀរឡង់ដេ ម្នាក់ទៅ -- ដែលកូនខ្ញុំដែលវាកើតនៅកន្លែងហ្នឹង វាចង់ទៅឃើញកន្លែងកំណើតវា ហើយដល់ពេលហ្នឹងទៅជួបកសិករនៅហ្នឹងក៏គេក៏បង្ហាញស្អីដែលថា គេប្រាប់ថា នៅកន្លែងព្រៃកុងហ្នឹង មានខ្មែរមកពីបរទេសហ្នឹងគេយកមកសម្លាប់ជាហូរហែ តាំងពីៗជំនាន់ដែលពួកយើងខ្ញុំនៅនោះ។

[១៥:៣០:៥២]

រហូតដល់ឥឡូវ ខ្ញុំៗគ្រាន់ថា គេបង្ហាញរបស់ខ្លះ ប៉ុន្តែខ្ញុំក៏មិនទាន់ដឹងថាការពិតហ្នឹងវាយ៉ាង ម៉េចទេ ព្រោះពួកដែលរាប់រយអ្នកដែលស្លាប់ហ្នឹង គឺស្លាប់ព្រៃកុង ឬក៏ជាការពិតស្លាប់នៅឯងណាអត់ដឹងទេ។ គ្រាន់តែជាក់ស្តែងរហូតដល់ឥឡូវហ្នឹង ពួកដែលបាត់ខ្លួនហ្នឹង ក្រៅពីចេញពីដីក្រហម ក្រៅពីក្មួយអៀង សារី ពីរហ្នឹង គឺថាពួកហ្នឹងបាត់ខ្លួនទាំងអស់គ្នា រកអត់ទាន់ឃើញថា ពួកគ្នាហ្នឹងស្លាប់នៅកន្លែងណា បាត់ខ្លួននៅកន្លែងណា គេយកទៅធ្វើយ៉ាងម៉េចអត់ដឹងទេ។ អាហ្នឹងទី១។ ហើយអាហ្នឹង ខ្ញុំចំពោះរឿងហ្នឹងខ្ញុំសូមបញ្ចោក់ ហើយចំពោះសំណួរលោកទី២ ខ្ញុំសូមសួរម្តងទៀតបាទ។

**ស៖** សំណួរ ខ្ញុំអម្បាញ់មិញនេះ ខ្ញុំចង់សួរលោកថា នៅពេលលោកបញ្ចប់ការងារនៅដីក្រហម តើកម្មាភិបាលខ្មែរក្រហមនោះ បានចាត់ទុកថាគេអប់រំលោកចប់ហើយ ឬមួយក៏ថាលោកមិនទាន់ចប់ទេ ត្រូវតែបញ្ជូនលោកទៅជំរំណាមួយផ្សេងទៀត ដើម្បីបន្តអប់រំកសាងលោកបន្តទៅទៀត?

**ឆ៖** នៅពេលនោះ គឺថាខ្ញុំក្តាប់បាន គេថាដូចថាៗ គេថាសព្វថ្ងៃហ្នឹងអង្គការត្រូវការពួកបងៗហើយ ដូច្នេះពួកបងៗត្រូវទៅភ្នំពេញវិញ។ ហ្នឹងគេប្រាប់អ៊ីចឹង ហើយក៏គេដឹកពួកយើងខ្ញុំ អ្នកនៅសេសសល់ហ្នឹងឲ្យមកភ្នំពេញមកបាទ។ ពីរឿងថា រៀនវគ្គសិក្សាចប់ ឬមិនចប់អី ខ្ញុំអត់ដឹងទេ គ្រាន់តែគេប្រាប់ សព្វថ្ងៃហ្នឹងអង្គការត្រូវការពួកបងៗឲ្យមកជួយធ្វើការ។

[១៥:៣២:៤៧]

**ស៖** ហើយនៅទីក្រុងភ្នំពេញ តើមានអ្វីកើតឡើង ហើយគេនាំលោកទៅកន្លែងណាដែរ?

**ឆ៖** ដល់មកដល់ភ្នំពេញហ្នឹងគេយកពួកយើងខ្ញុំនៅចត ឲ្យចេញពីទូក -- អ៎! ពីទូកនៅខាង នៅ

ជាប់ស្ពួនច្បារវាំង ហើយក៏គេដឹកទៅផ្ទះ ឲ្យទៅនៅផ្ទះសម្រាប់អ្នកបច្ចេកទេសកូរ៉េ ឬក៏អ្នកបច្ចេកទេសចិននៅជិតវត្តភ្នំ។ គេឲ្យពួកយើងខ្ញុំនៅសំណាក់នៅវត្តភ្នំ ហើយអ្នកនាំទៅនឹងគឺ លោក ជឹប ដែលគាត់ជាដៃ -- ដែលគាត់ជាអ្នកសហការីរបស់លោក អៀង សារី ហើយគាត់ៗដឹកពួកយើងខ្ញុំទៅថា បង អៀង សារី មកយកពួកបងៗឲ្យទៅនៅៗ -- ឲ្យទៅសំណាក់នៅកន្លែងជិតវត្តភ្នំ។ អាហ្នឹងយប់មកដល់បាទ។

[១៥:៣៣:៥៨]

**ស៖** ហើយតើលោកនៅទីនោះរហូតដល់វៀតណាមចូលមកដល់ ឬក៏នៅទីនោះបណ្តោះអាសន្នទេ ហើយបន្ទាប់មកទៀតលោកបន្តដំណើរតទៅមុខទៀត?

**ឆ៖** ពួកយើងខ្ញុំទៅហ្នឹងនៅបានតែមួយយប់ទេ ប៉ុន្តែយប់ហ្នឹងក៏លោក អៀង សារី គាត់មកជួបពួកខ្ញុំ ប៉ុន្តែខ្ញុំៗគេងលក់ទៅ។ ប៉ុន្តែគាត់ជួបអ្នកផ្សេងទៀត ប៉ុន្តែព្រលឹមឡើងមានមិត្តភក្តិខ្ញុំគាត់បានជួបគាត់ ហើយគាត់សួរពួកយើងខ្ញុំថា ពួកយើងខ្ញុំប៉ុន្មានឆ្នាំហើយទៅនៅឯណា? ហើយពីអ្នកណាអ្នកបញ្ជូនពួកយើងខ្ញុំហ្នឹងទៅដីក្រហម? ហើយដីក្រហមហ្នឹងយ៉ាងម៉េច? គាត់សួរអ៊ីចឹង ហើយគាត់សួរពីថាដូចថា គាត់សំណេះសំណាល ត្រូវការ អ៊ំ! ដូចថាសំណេះសំណាលជាមួយពួកយើងខ្ញុំហ្នឹង គឺថាដូចជាៗបងប្អូន ដូចសំណេះសំណាលដូចអង្កាល់ជួបគ្នានៅប៉ារីសអ៊ីចឹងបាទ។

[១៥:៣៥:០៦]

**ស៖** បាទ សូមអរគុណ។ ដូច្នេះ ពេលក្រោយពីថ្ងៃយប់ហ្នឹងទៅ តើលោកគេត្រូវបានបញ្ជូនទៅកន្លែងណា?

**ឆ៖** បន្ទាប់ពីពេលហ្នឹងទៅ ក៏គេបញ្ជូនពួកខ្ញុំហ្នឹងទៅបឹងត្របែកៗ។ ទៅនៅបឹងត្របែកហ្នឹងជាដំបូងគេឲ្យនៅប-៣០។ បឹងត្របែកមួយប-៣០។ ក្រោយមកខ្ញុំដឹងថា បឹងត្របែកហ្នឹងមានប-៣០ មានប-៣២ ហើយមានប-៣១។ ទៅដល់ភ្លាមហ្នឹង គេឲ្យទៅនៅប-៣០ បាទ។

**ស៖** ការចាត់តាំង -- ដាក់ឈ្មោះនោះមានតាំងពីមុនមកហើយ ឬក៏ទើបតែគេដាក់ឈ្មោះក្រោយទេ? ហើយអ្នកណាធ្វើការនៅក្នុងសាខាទាំងបីហ្នឹង ផ្នែកទាំងបីហ្នឹង គឺថាប-៣០, ៣១, ៣២នេះ នៅសម័យហ្នឹង?

**ឆ៖** ការចាត់តាំងមានភាពប្លែកពីកាលពីមុនខ្ញុំ ព្រោះបឹងត្របែក ជំរំនៅបឹងត្របែកដូចគ្នា ប៉ុន្តែការចាត់តាំងមានភាពប្លែកពីអង្កាល់មុនពួកយើងខ្ញុំទៅដីក្រហម ហើយខ្ញុំភ្លាប់បាន គេគ្រាន់តែ គេប្រាប់ថា ឥឡូវពួកៗបងឯងហ្នឹងនៅក្រោមការគ្រប់គ្រងរបស់បង អៀង សារី។

[១៥:៣៧:០៥]

**ស៖** ដូច្នេះនៅពេលនោះ តើគេដាក់លោកនៅប-៣០ ឬក៏ប-៣១ ឬក៏ប-៣២? ហើយនៅជាមួយប្រភេទមនុស្សបែបណាដែរ?

**ឆ៖** ខ្ញុំនៅ ប-៣០ហ្នឹងមួយរយៈ គេយកខ្ញុំទៅប-៣២។ យកទៅប-៣២ នៅជាមួយពួកអតីតទូត។ ហើយអង្គាល់ហ្នឹងគេប្រាប់ខ្ញុំថា ដោយសារនៅដីក្រហមហ្នឹង ខ្ញុំកសាងខ្លួនអត់បាន។ ដូច្នេះគេយកខ្ញុំទៅដាក់ជាមួយពួកទូត ពួកមន្ត្រី។ ព្រោះអង្គាល់នៅប-៣០ បើអ្នកណា ដូចថាគេត្រូវការ គេយកទៅប-៣១។ ប-៣១ វា ហើយគេ ពីប-៣១ហ្នឹងទៅ គេយកទៅធ្វើការនៅប-១។ ដូច្នេះ អ្នកទៅប-៣២ហ្នឹង អ្នកហ្នឹងដូចជា ដូចថាអ្នកហ្នឹងតាមធម្មតា វាអត់ៗ វាកសាងខ្លួនអត់ទាន់បានបាទ។

**ស៖** ហើយកម្មាភិបាលខ្មែរក្រហមដែលគ្រប់គ្រងបឹងត្របែកនុ៎ង ដែលនៅ ស្ថិតនៅប-៣០ ឬប-៣១ ឬក៏ប-៣២?

**ឆ៖** ពេលនោះ ខ្ញុំដូចអត់មានចាំថា មានកម្មាភិបាលខ្មែរក្រហមក្រៅពីលោក អៀង សារី និងសហការីរបស់គាត់។ យូរៗគាត់មកអើតម្តង យូរៗគាត់យកត្រី យកស្អីៗមកឲ្យ ឲ្យតែបងហូបទៅៗ ជួនកាលគាត់យកក្រពើមក ជួនកាលគាត់យកអីមក គឺថាគាត់បំពក់បំពុលយើងខ្ញុំហ្នឹង គឺថាឲ្យពួកយើងខ្ញុំហ្នឹងហូប ហើយធ្វើការអីក៏វាធូរស្រាលជាងមុន។ ហើយគេថា គេអប់រំពួកក្មេងៗដែលឪពុកម្តាយពួកទូត គេយកទៅសម្លាប់ហ្នឹង គេថាពួកហ្នឹងធ្លាប់ចេះភាសាបរទេសពីដើម។ គេត្រូវការពួកហ្នឹងឲ្យទៅរៀន ដើម្បីទៅ ដើម្បីរៀបចំទទួល ស្អីអាដែងៗ អ្នកទទួលភ្ញៀវបរទេសដែលមកចូលធ្វើទស្សនកិច្ចនៅស្រុកខ្មែរ។ ដូច្នេះសភាពការណ៍វាដូរ ពេលហ្នឹងវាដូរ គឺថាយើងអាច គេមិនបង្ខំឲ្យយើងធ្វើការអីដូចពីដើមទេ ប៉ុនយើងនៅតែខំធ្វើអ៊ីចឹង ដូចពីដើម ប៉ុនវាសភាពការណ៍វាធូរស្រាលដូចមេឃនិងដីអ៊ីចឹងបាទ។

[១៥:៣៩:៥៦]

**ស៖** នៅពេលដែលលោកត្រឡប់មកបឹងត្របែកវិញ ស្វាន់ ដែលដឹកនាំបឹងត្របែកនៅពេលនោះ គាត់នៅទីនោះដដែល ឬក៏យ៉ាងម៉េច?

**ឆ៖** ឮសូរតែគេនិយាយថា សារ៉ន ហ្នឹងអង្គការចាប់។ ពេលខ្ញុំមកដល់ហ្នឹង។ អង្គការនាំចេញៗមិនមែនអង្គការចាប់ទេ សូមទោស។ អង្គការនាំចេញ។

**ស៖** តើលោកបានចូលរួមប្រជុំជាមួយ អៀង សារី នៅពេលដែលលោកនៅបឹងត្របែកដែរឬទេ?

**ឆ៖** ខ្ញុំដូចជាបានចូលប្រជុំពីរដងបាទ។

**ស៖** យើងចាប់ផ្ដើមនិយាយពីកិច្ចប្រជុំទី១។ កិច្ចប្រជុំទី១នេះ ប្រព្រឹត្តឡើងនៅកន្លែងណា? ហើយប្រព្រឹត្តឡើងនោះរយៈពេលប៉ុន្មានបន្ទាប់ពីពេលលោកមកដល់បឹងត្របែក?

[១៥:៤១:២០]

**ឆ៖** នៅសាលមួយអតីតសាលាបឹងត្របែកហ្នឹង ខ្ញុំនៅៗរោងពុម្ពបឹងត្របែកហ្នឹង ខ្ញុំ -- ហើយរយៈពេលដូចជា១ថ្ងៃ។ ដូច្នេះខ្ញុំមិនចាំម៉ោងច្បាស់ទេ ប៉ុនរយៈ១ថ្ងៃតាមមើល ប៉ុនខ្ញុំអត់ច្បាស់ទេបាទ។

**ស៖** ហើយនៅពេលនោះអ្នកណាខ្លះចូលរួមកិច្ចប្រជុំហ្នឹង? តើអ្នកធ្វើការនៅប-៣០, ប-៣១, ប-៣២ ទាំងអស់ ឬក៏យ៉ាងម៉េច?

**ឆ៖** ប្រជុំទី១ តាមខ្ញុំចាំ គឺរួមគ្នាទាំងអស់ ពីប-៣០, ប-៣១, ប-៣២ ជួបជុំប្រជុំគ្នាទាំងអស់ដើម្បីស្ដាប់ឧទ្ទេសនាមរបស់គាត់។ ហើយពេលនោះជាលើកទី១ហើយដែលខ្ញុំ លើកទី១ មុនខ្ញុំទៅប-៣២ ដែលលើកទី១ ខ្ញុំឃើញដែលទូតចាស់ៗខ្ញុំធ្លាប់ស្គាល់ ដូចជាលោក សារិន ឆាក, លោក ចែម ស្នួន, លោក ហោ ណាំហុង អីចឹងបាទ។ ខ្ញុំទៅពេលប្រជុំហ្នឹង។

**ស៖** ហើយ អៀង សារី បានធ្វើបទបង្ហាញមួយ តើគាត់និយាយពី -- តើលោកចាំពីប្រធានបទអីខ្លះដែលគាត់បាននិយាយនៅពេលនោះ?

**ឆ៖** ប្រធានបទដែលខ្ញុំចាំលើកដំបូង គឺប្រធានពីសភាពការណ៍បច្ចុប្បន្ននៅប្រទេសកម្ពុជា គឺថាយើងសព្វថ្ងៃហ្នឹង វាទាល់មានការតស៊ូស្វិតស្វាញជាមួយវៀតណាម។ អាហ្នឹងខ្ញុំចាំជាងគេបាទ។ ហើយគាត់ថាកុំឲ្យព្រួយ យើងច្បាស់ជាឈ្នះ។

[១៥:៤៤:០០]

**ស៖** តើផ្នែកសន្តិសុខ គេយកមកនិយាយ -- គាត់មាននិយាយទេ? ហើយគាត់មាននិយាយពីជនក្បត់ដែរឬទេ?

**ឆ៖** គាត់មានៗនិយាយពីជនក្បត់ ប៉ុនខ្ញុំៗមិនចាំថាគាត់និយាយលើកទី១ លើកទី២ លើកទី៣ អីខ្ញុំអត់ចាំទេ។ គ្រាន់ថាគាត់មាននិយាយពីរឿងសន្តិសុខ ពីរឿងចាប់ខ្លួនគ្នាយើង អ៎!ពីរឿងចាប់ខ្លួន។ ខ្ញុំចាប់អារម្មណ៍ជាងគេ គឺថាពេលនោះគាត់បាននិយាយថា តូ ទីភាគ ដែលជា ដែលកាលមុនខ្ញុំទៅដីក្រហមជាធ្វើក្នុងគណៈកម្មាធិការដែលគណៈកម្មាធិការបឹងត្របែកហ្នឹង គាត់ហ្នឹងចូល*គុកមីងតង់*។ ហើយ វ៉ាន់ពិនី ដែលខ្ញុំធ្លាប់ស្គាល់យូរហើយពីប៉ារីសមកហ្នឹង មានគេចោទគាត់ មានឯកសារពីរចោទគាត់។ អង្គាល់ហ្នឹងខ្ញុំអត់ដឹងថាឯកសារពីរចោទគាត់ហ្នឹង ហើយឥឡូវហ្នឹងគាត់ថា គាត់សម្រេចថាដើម្បីចោទចាប់អ្នក

ណាមួយ ត្រូវឯកសារបី។ ហើយខ្ញុំអង្កាល់ហ្នឹង ខ្ញុំក៏អត់យល់ថា ដែលគាត់ប្រើពាក្យថា "ឯកសារ" ហ្នឹង ក៏ខ្ញុំមិនដឹងថាគាត់និយាយលើអី ប៉ុន្តែគ្រាន់ថា -- ហើយៗគាត់និយាយមួយទៀត គាត់ថា គាត់តែងតែតស៊ូការពារមិត្តយើងមកពីបរទេសទាំងអស់។ គាត់ថាមិត្តយើងមកពីបរទេសហ្នឹងគឺថា គាត់មិនជឿថា វាក្បត់ទាំងអស់គ្នាទេ។ ដូច្នេះគាត់ៗ ដូចគាត់ថាគាត់ហ្នឹង គឺជានិច្ចកាលគាត់តែងតែការពារគ្នាយើងមកពីបរទេសជានិច្ចកាល តាមដែលគាត់អាចធ្វើទៅបាន។

[១៥:៤៦:០៤]

**ស៖** បើសិនជាមិនយល់ច្រឡំពីឃ្លាចុងក្រោយរបស់លោកអម្បាញ់មិញនេះទេ គឺថាបញ្ញាជនដែលមកពីបរទេសទាំងអស់នោះ មិនប្រាកដថាជាជនក្បត់ទាំងអស់គ្នានោះទេ។ តើអ៊ីចឹងមែនទេ ឃ្លារបស់លោកអម្បាញ់មិញនេះ?

**ឆ៖** លោក អៀង សារី គាត់បាននិយាយដូច្នេះមែន ពីព្រោះគាត់ដែល គាត់បាននិយាយថា គាត់តែងតែនិយាយប្រាប់គេ ប៉ុន្តែគេហ្នឹងពីណាគេ? គឺថាខ្មែរមកបរទេសមិនមែនសុទ្ធតែក្បត់ទាំងអស់ទេ។

**ស៖** ទាក់ទងនឹងលោក វ៉ាន់ ពីនី លោកបាននិយាយពីការដែលថាគេឆ្លើយដាក់គាត់ក្នុងឯកសារជាច្រើន។ តើលោក អៀង សារី បាននិយាយថា បុគ្គលរូបនេះជាកម្មវត្ថុនៃការចាប់ខ្លួន លោក អៀង សារី បាននិយាយយ៉ាងដូច្នេះដែរឬទេ?

**ឆ៖** អង្កាល់ហ្នឹងខ្ញុំទៅស្ដាប់ ខ្ញុំវាអត់មាននឹកឃើញថាមាន អេស-វ៉ាំងតេអង អត់អី ខ្ញុំគ្រាន់ឮសួរគាត់និយាយអ៊ីចឹងមក ខ្ញុំមិនៗ ខ្ញុំអត់ដឹងថាម៉េច ខ្ញុំអត់ដឹងមានន័យថាម៉េចទេ ខ្ញុំភ្លាប់អត់បានទេពេលហ្នឹង គ្រាន់តែថា ខ្ញុំគ្រាន់តែដឹងថា វ៉ាន់ ពីនី មានឯកសារពីរចោទគាត់ ហើយខ្ញុំគ្រាន់តែថាប៉ុណ្ណឹងទៅ ខ្ញុំមិនដឹងជាឯកសារហ្នឹងស្អី ហើយមានន័យថាម៉េច ខ្ញុំអង្កាល់ហ្នឹងខ្ញុំភ្លាប់អត់បានទេបាទ។

[១៥:៤៧:៥៧]

**ស៖** តើ អៀង សារី បាននិយាយអំពីការចោទប្រកាន់លើ វ៉ាន់ ពីនី ហើយគេមានប្រាប់ពីមូលហេតុនៃការចោទប្រកាន់លើ វ៉ាន់ ពីនី នេះទេ ឬក៏លោក អៀង សារី មិនបាននិយាយអ្វីទាំងអស់?

**ឆ៖** តាមខ្ញុំចាំ លោក អៀង សារី គ្រាន់តែបាននិយាយថា មានគេ -- មានឯកសារពីរចោទគាត់ ចោទ វ៉ាន់ ពីនី បាទ។ ខ្ញុំមិនចាំថាគាត់បាននិយាយពាក្យអ្វីផ្សេងទៀតទេបាទ។ គ្រាន់ថាបើ តូ ទីភាគ គាត់និយាយថា តូ ទីភាគ ចូល*គួកមីងតង់* ហ្នឹងខ្ញុំបានឮ។

**ស៖** នៅពេលដែលលោកចេញបឹងត្របែកទៅដីក្រហម ស្វ៊ន ជាប្រធាននៅឡើយ នៅពេល

ដែលលោកត្រឡប់មកវិញ ស្វាន នេះបាត់ខ្លួនហើយ។ តើលោកបានឮ អៀង សារី និយាយក្នុងពេលកិច្ចប្រជុំនិយាយៗអំពី ស្វាន នេះទេ ហើយនិងនិយាយអំពីជោគវាសនារបស់ ស្វន ហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំ តាមខ្ញុំចាំ អៀង សារី ថា ស្វាន ហ្នឹងក្បត់។

[១៥:៤៩:៤៤]

**ស៖** តើលោកមានបានបញ្ជាក់ពីប្រភេទជនក្បត់ដែរឬទេ?

**ឆ៖** និយាយឲ្យច្បាស់ទៅពេលហ្នឹង ខ្ញុំអត់ដែលនឹកឃើញថា គេថាក្បត់ទៅ ក៏ខ្ញុំអត់ដឹងថាគេយកទៅសម្លាប់អីទេ គ្រាន់តែគេថាអ៊ីចឹងទៅ គ្រាន់ថាវាមានអ៊ីចឹង ក្រែងគេយកទៅកសាង នៅណាអីណា ខ្ញុំក្តាប់អត់បានទេ ព្រោះវា ខ្ញុំអត់ដែលដឹងថា គេមានសម្លាប់ មាន អេស-ទ្វាំងតេអង មានអី ខ្ញុំអត់ -- អង្កាល់ហ្នឹង ខ្ញុំអត់ទាន់ក្តាប់បានអ៊ីចឹងទេបាទ។

**ស៖** តើនៅក្នុងកិច្ចប្រជុំទាំងអស់នោះ លោកមានបានឮ អៀង សារី និយាយអំពីបុគ្គលផ្សេងទៀត ឬក៏ធ្វើការអត្ថាធិប្បាយលើ លាន សេរីរុធ អីជាដើមនោះ?

[១៥:៥០:៤៣]

**ឆ៖** ខ្ញុំ មិនដឹងជាខ្ញុំឮសួរ ឬក៏ខ្ញុំឮសួរ មិត្ត អៀង សារី ខ្ញុំមិនច្បាស់ទេ ប៉ុន្តែគ្រាន់ថា ពេលនោះមានគេចោទថា លាន សេរីរុធ ហ្នឹង ចូល សេ.អ៊ី.អា។ ហើយខ្ញុំៗ វា ចោទពីណាថា សេ.អ៊ី.អា ប៉ុន្តែចោទ លាន សេរីរុធ ហ្នឹង ជា សេ.អ៊ី.អា វាដូចជ្រុលពេក។ ប៉ុន្តែខ្ញុំមិនចាំថា អៀង សារី ថាទេ ប៉ុន្តែក្នុងបរិយាកាសពេលនោះ ខ្ញុំឮសួរគេនិយាយ។ ប៉ុន្តែខ្ញុំមិនដឹងថា អៀង សារី ថា ឬពីណា ខ្ញុំៗភ្លេចហើយបាទ។ ប៉ុន្តែខ្ញុំកាលហ្នឹង ខ្ញុំដឹងថាគេមានចោទ លាន សេរីរុធ ថា លាន សេរីរុធ ហ្នឹងជា សេ.អ៊ី.អា ហើយខ្ញុំ ខ្ញុំដឹងថា លាន សេរីរុធ ហ្នឹង ជាប្អូនជីដូនមួយរបស់ ស្នួង ស៊ីគឿន ហើយដូច្នេះ ខ្ញុំ ហើយជាមិត្តភក្តិរបស់ខ្ញុំផង។ ដូច្នេះ ខ្ញុំៗ វាក្តាប់អត់បាន ក្តាប់ថា មិនដឹងអាទាំងអស់ហ្នឹង មុនខ្ញុំទៅឃើញ អេស-ទ្វាំងតេអង ខ្ញុំមិនដឹងថា គេថាក្បត់ ឬក្បត់ ជួនកាល គ្រាន់គេថាអ៊ីចឹង ហើយយកទៅកសាង ឬក៏ធ្វើអីទៅ ខ្ញុំវាក្តាប់អត់បាន មិនដឹង អត់នឹកឃើញថា គេយកទៅសម្លាប់អី កាលហ្នឹង ខ្ញុំមិនទាន់នឹកឃើញដល់ទេបាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមឲ្យលោកបែងចែករវាងអ្វីដែលលោកបានឮ ថាលោក អៀង សារី និយាយ ហើយនិងអ្វីដែលលោកបានសង្កេតឃើញនៅពេលក្រោយ។ បាទ ចំណុចចុងក្រោយលោកសាក្សី គឺទាក់ទងទៅនឹងវៀតណាម។ តើលោកមានចាំ ថាលោក អៀង សារី បាននិយាយក្នុង

ពេលប្រជុំទាំងអស់ហ្នឹង ឬក៏ប្រជុំក្រោយហ្នឹងទៀតដែរឬទេ? គាត់មានបាននិយាយអ្វីខ្លះដែរឬទេទាក់ទងនឹងវៀតណាម?

[១៥:៥២:៣៧]

**ឆ៖** អត់មានអ្វីបញ្ជាក់ថែមទៀត គ្រាន់តែថា ខ្ញុំក្ដាប់បានពេលនោះ ឮ អៀង សារី គាត់និយាយថា យើងប្រយុទ្ធក្ដៅជាចុងក្រោយបំផុតជាមួយយៀកណាម បាទ ដែលខ្ញុំក្ដាប់បាន។ ប៉ុន្តែខ្ញុំមិនអាចបញ្ជាក់ថែមទៀតទេ ខ្ញុំភ្លេចអស់ បាត់អស់។

**ស៖** នៅក្នុងរយៈពេលនុ៎ង រហូតដល់ពេលដែលលោកចាកចេញទីក្រុងភ្នំពេញ តើលោកនៅតែបន្តធ្វើការនៅបឹងត្របែក ឬក៏យ៉ាងម៉េច?

**ឆ៖** ដល់ថ្ងៃ យប់ថ្ងៃ ល្ងាចថ្ងៃទី៦ មករា ថ្ងៃ៦ ខែ១ ឬក៏ព្រឹកហ្នឹង ខ្ញុំចាំមិនច្បាស់ទេ ដែល សួរ ហុង បានមកប្រាប់ពួកខ្ញុំឲ្យរៀបចំចេញពីបឹងត្របែក។ ហើយទី១ គេប្រាប់ថា ឲ្យយកពួកប្រុសៗទៅសិនទៅមួយរយៈ។ ហើយទៅ យើងខ្ញុំក៏ត្រៀមខ្លួនរត់ ចេញទៅៗ ប៉ុន្តែដល់ជាក់ស្ដែងទៅ ដល់ព្រឹកថ្ងៃ -- មក យប់ថ្ងៃទី៦ មកលានរទេះភ្លើងម្ដង ប៉ុន្តែអត់មានរទេះភ្លើង ក៏យើងត្រឡប់ទៅបឹងត្របែកវិញទៅ។ ដល់ព្រឹក ថ្ងៃទី៧ ខែ១ ហ្នឹង ក៏យើងមកម្ដងទៀត មកម្ដងទៀត មកទាំងអស់ហ្នឹង គេសម្រេចដឹកពួកយើងខ្ញុំហ្នឹង ទាំងគ្រួសារ ទាំងប្ដីទាំងប្រពន្ធហ្នឹង ដឹកទៅ គេតម្រូវដឹកទៅ ដឹកទៅៗព្រំទល់ដែនថៃ។ គេអត់ប្រាប់ច្បាស់ទេ ប៉ុន្តែគ្រាន់ឮសួរអ៊ីចឹង ខ្ញុំមិនដឹងជាអ្នកណាច្បាស់ ប៉ុន្តែគ្រាន់តែថាគេដឹកទៅ ទៅព្រំប្រទល់ដែនថៃ។ ប៉ុន្តែដល់ហើយទៅ ដល់គេដឹកបានបន្តិច ស្រាប់តែខ្ញុំឮសួរ ផ្ទុះនៅភ្នំពេញនោះ បាទ ហើយដល់ហើយទៅ ក៏ដល់ស្ដុកអាចម៍រមាសហ្នឹង ក៏រទេះភ្លើងហ្នឹងក៏ឈប់នៅហ្នឹងទៅ។ ហើយយើងឈប់ចាំនៅនុ៎ងទៅ ចាំរទេះភ្លើងដឹកអី ដឹកពួកយើងខ្ញុំទៀត។ ប៉ុន្តែហើយទៅអត់ឃើញរទេះភ្លើងមក ក៏គេឲ្យពួកយើងខ្ញុំចូលទៅ ចូលៗទៅក្នុង ដើរចូលក្នុងទៅ ឲ្យទៅរស់នៅតាមសហករណ៍ ហើយទៅដល់សហករណ៍គេចែកពួកយើងខ្ញុំ នេះម្ដុំ នោះម្ដុំ តាមសហករណ៍ផ្សេងៗនៅក្នុងៗៗ ជិតក្រុង ជិតរទេះភ្លើងស្ដុកអាចម៍រមាស ខ្ញុំឥឡូវហ្នឹងឈ្មោះភូមិ ឈ្មោះឃុំយ៉ូត ឈ្មោះអីៗខ្ញុំភ្លេចអស់ហើយ គ្រាន់ថាអាហ្នឹងថ្ងៃ៧ ខែ១ អ៊ីចឹងបាទ។

[១៥:៥៦:០០]

**ស៖** បាទសូមអរគុណ។ សំណួរចុងក្រោយ លោកសាក្សីនៅពេលដែលលោកចាកចេញភ្នំពេញចេញពីភ្នំពេញតាមរទេះភ្លើង ហើយលោកបានឆ្លងកាត់តាមសហករណ៍ទាំងអស់។ តើលោក អៀង សារី

នៅជាមួយលោកដែរឬទេ ឬក៏លោក អៀង សារី បានចាកចេញពីទីក្រុងភ្នំពេញបាត់ទៅហើយនៅពេលនោះ?

**ឆ៖** អត់មានអ្នកទទួលខុសត្រូវខ្មែរក្រហមណាម្នាក់នៅជាមួយពួកយើងខ្ញុំទេ សុទ្ធតែពួកយើងខ្ញុំមកពីបរទេសទាំងអស់គ្នាបាទ។ អត់មានអ្នកមុខអ្នកការអី រដ្ឋាភិបាល ឬអ្នកតំណាងអង្គការលើណានៅជាមួយពួកខ្ញុំទេ គឺពួកខ្ញុំមកពីបរទេសទាំងអស់ហ្នឹង នៅជាមួយគ្នាអ៊ីចឹង ប៉ុន្តែចែកគ្នាជាក្រុមៗតាមៗលទ្ធភាពដែលសហករណ៍នៅតំបន់ផ្សេងៗ គេអាចចិញ្ចឹមពួកយើងខ្ញុំបានបាទ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

បាទ សូមអរគុណលោកសាក្សី ដែលបានឆ្លើយតបនឹងសំណួរខ្ញុំទាំងអស់នេះ។ លោកប្រធាន ខ្ញុំចប់ការចោទសំណួរខ្ញុំនេះហើយ។ ហើយខ្ញុំទុកវេទិកាឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅព្រឹកស្អែកនេះលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណៗ សាក្សី។

បាទ ឥឡូវនេះកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលសមល្មមសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី៩ ខែសីហា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តការស្តាប់ចម្លើយសាក្សី អ៊ុង ថុងហឿង ដែលនឹងសួរដេញដោលដោយសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីនៅពេលព្រឹក ហើយនៅពេលរសៀល ហើយនិងបន្តដោយក្រុមមេធាវីការពារក្តី ដែលនឹងចាប់ផ្តើមមុនគេដោយក្រុមមេធាវីការពារក្តីលោក នួន ជា។ សូមភាគី និងសាធារណជនជ្រាប។

[១៥:៥៨:០៨]

លោក អ៊ុង ថុងហឿង ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ ដូច្នេះអង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តសក្ខីកម្មនៅថ្ងៃស្អែកទៀត។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនសាក្សីវិលត្រឡប់ទៅកាន់កន្លែងគាត់ស្នាក់នៅ និងឲ្យអញ្ជើញគាត់មកកាន់ទីកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំង នៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៥៨ នាទី)*